**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# គណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# នីតិកាលទី ៧

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ លោក **សាន់ ចាន់វណ្ណា**

លោក **ហេន ឡុង់ឌី**

ណែនាំដោយ

បណ្ឌិត **អ៊ឹង រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៧ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **សាន់ ចាន់ថណ្ណា** និងឈ្មោះ **ហេន ឡង់ឌី** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៧ (អាហារូបករណ៍) ក្រុមP4B03 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២៣-២០២៤។

**យើងខ្ញុំ សូមថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ**

**លោកឪពុក** និង **អ្នកម្តាយ** ដែលបានផ្តល់កំណើតដល់យើងខ្ញុំ មកកើតជាមនុស្សខ្មែរនៅលើទឹកដីកម្ពុជា ព្រះរាជាណាចក្រអច្ឆរិយ នាសម័យសុខសន្តិភាព និងការអភិវឌ្ឍ។ លោកអ្នកមានគុណមិនត្រឹមតែផ្តល់នូវកំណើតប៉ុណ្ណោះទេ លោកថែមទាំងផ្តល់នូវការថ្នាក់ថ្នមចិញ្ចឹមបីបាច់ថែរក្សា ការឧបត្ថម្ភគាំទ្រជួយទំនុកបម្រុងគ្រប់សព្វបែបយ៉ាងលើជីវភាពរស់នៅ និងការសិក្សាពីបឋមសិក្សា រហូតមកដល់មហាវិទ្យាល័យ។ មហាគុណរបស់លោកអ្នកមានគុណមិនមានអ្វីដែលអាចនឹងផ្ទឹមបានឡើយ លោកគឺជាព្រះដែលមានព្រះជន្មរស់ កូនៗទាំងពីររូបសូមសច្ចាថា នឹងខិតខំដុសខាត់សតិស្មារតីតាមរយៈការសិក្សារៀនសូត្រ ដើម្បីក្លាយខ្លួនទៅជាធនធានដែលកម្ពុជាត្រូវការ និងប្តេជ្ញាចូលរួមការពារសុខសន្តិភាពដែលរាជរដ្ឋាភិបាលបានកសាងឡើងដោយលំបាកនាពេលកន្លងមក។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អតីតនាយករដ្ឋមន្ត្រី និងរដ្ឋបុរសកម្ពុជា ដែលបានស្ថាបនាសុខសន្តិភាព និងការអភិវឌ្ឍជូនប្រជាជាតិខ្មែរមួយនគរ។

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តដឹកនាំប្រទេសកម្ពុជាធានាបាននូវសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកសាកលវិទ្យាធិការរង អស់លោក លោកស្រីដែលជាថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំសម្របសម្រួល និងបង្ហាត់បង្រៀននិស្សិតដោយការយកចិត្តទុកដាក់ និងប្រសិទ្ធភាពខ្ពស់បំផុត។

ជាពិសេស លោក **បណ្ឌិត អ៊ឹង រដ្ឋា** សាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះ លោកបណ្ឌិតបានចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងការណែនាំ និងផ្តល់អនុសាសន៍ដោយយកចិត្តទុកដាក់បំផុត។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមបួងសួង និងប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណ សម្តេច ទ្រង់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បុគ្គលិកគ្រប់ជាន់ថ្នាក់ និស្សិត និងជនរួមជាតិគ្រប់ស្រទាប់វណ្ណៈឱ្យចួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីអាក់ខានឡើយ។

## **អារម្ភកថា**

សារណាមួយក្បាលនេះគឺជាស្នាដៃទីមួយ និងជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងនៅក្នុងការសិក្សារៀនសូត្រថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលបួនឆ្នាំកន្លងមក ជាលទ្ធផលយើងខ្ញុំទទួលបានឱកាស និងលទ្ធភាពក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។ យ៉ាងណាមិញការសម្រេចលទ្ធផលដ៏ល្អមួយនេះ គឺមិនអាចកើតឡើងបានឡើយ បើគ្មានវត្តមាននៃការដឹកនាំ ចង្អុលបង្ហាញ ពីសំណាក់លោក **បណ្ឌិត អ៊ឹម រដ្ឋា** ទេនោះ។ ដោយយល់ឃើញអំពីការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នតាមគន្លងលទ្ធិប្រជាធិបតេយ្យ ដែលបានបន្តថែរក្សានូវសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ ទើបបណ្ដាលចិត្តឱ្យរូបយើងខ្ញុំទាំងពីរ សម្រេចជ្រើសរើសយកនូវការស្រាវជ្រាវសារណាមួយនេះឡើងក្រោមប្រធានបទស្ដីពី "**គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី ៧**" ។

សារណាមួយក្បាលនេះនឹងបានចូលរួមចំណែក ផ្ដល់ជាចំណេះដឹងដល់មិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិតជំនាន់ក្រោយឱ្យបានយល់ដឹងពីទិដ្ឋភាពទូទៅអំពីប្រវត្តិនៃគណៈរដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា ចាប់តាំងពីនីតិកាលទី១ ឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន។ ជាពិសេសយើងខ្ញុំផ្ដោតសំខាន់ទៅលើនីតិកាលទី៧ ដែលជាអាណត្តិថ្មីក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ បានកំពុងបន្តថែរក្សាកេមរតកសន្តិភាព យកចិត្តទុកដាក់ចំពោះជាតិមាតុភូមិ និងមានទស្សនៈវិស័យដ៏វែងឆ្ងាយ ក្នុងការដឹកនាំនាវាកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនស្របតាមគោលនយោបាយដែលបានគ្រោងទុក។

ជាទីអវសាន យើងខ្ញុំទាំងពីររូបសូមខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងឡាំងឡាយជាមុននៅលើផ្នែកណាមួយនៃអត្ថបទ ដោយចេតនាក្ដី ឬអចេតនាក្ដី មិនថាជាកំហុសខុសឆ្គងទៅលើអក្ខរាវិរុទ្ធ កំហុសវេយ្យាករណ៍ ខ្លឹមសារ ឬក៏មានចំណុចខ្វះខាតត្រង់កន្លែងណាមួយនោះ យើងខ្ញុំពិតជាត្រូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ សាស្ត្រាចារ្យ រៀមច្បង និងប្រិយមិត្តអ្នកអានទាំងអស់ ដើម្បីឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើងសម្រាប់មនុស្សជំនាន់ក្រោយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤
**ជំពូកទី ១**
**ប្រវត្តិគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**១.១. នីតិកាលទី១** (**ឆ្នាំ១៩៩៣ - ១៩៩៨**) ........ ៦
១.១.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ........ ៦
១.១.២. ការបង្កើតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ........ ៦
១.១.៣. សមាសភាពគណៈរដ្ឋមន្ត្រី ........ ៨
១.១.៣.១. ករណីពិសេស នាយករដ្ឋមន្ត្រី ២រូប ........ ៩
១.១.៤. ការបង្ក្រាបបទល្មើសច្បាប់ក្នុងឆ្នាំ១៩៩៧ ........ ៩
**១.២. នីតិកាលទី២** (**ឆ្នាំ១៩៩៨ - ២០០៣**) ........ ១០
១.២.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ........ ១០
១.២.២. សមាសភាពគណៈរដ្ឋមន្ត្រី ........ ១១
១.២.៣. នយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាពពេញលេញ ........ ១២
១.២.៤. សមិទ្ធផលសំខាន់ៗ ........ ១៤
**១.៣. នីតិកាលទី៣** (**ឆ្នាំ២០០៣ - ២០០៨**) ........ ១៥
១.៣.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ........ ១៥
១.៣.២. សមាសភាពគណៈរដ្ឋមន្ត្រី ........ ១៥
១.៣.៣. សមិទ្ធផលសំខាន់ៗ ........ ១៧
**១.៤. នីតិកាលទី៤** (**ឆ្នាំ២០០៨ - ២០១៣**) ........ ១៨
១.៤.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ........ ១៨

១.៤.២. សមាសភាពគណៈរដ្ឋមន្ត្រី ........ ១៩
១.៤.៣. សមិទ្ធផលសំខាន់ៗ ........ ២១
**១.៥. នីតិកាលទី៥** (**ឆ្នាំ២០១៣ - ២០១៨**) ........ ២៣
១.៥.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ........ ២៣
១.៥.២. សមាសភាពគណៈរដ្ឋមន្ត្រី ........ ២៦
១.៥.៣. សមិទ្ធផលសំខាន់ៗ ........ ២៨
**១.៦. នីតិកាលទី៦** (**ឆ្នាំ២០១៨ - ២០២៣**) ........ ២៩
១.៦.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ........ ២៩
១.៦.២. សមាសភាពគណៈរដ្ឋមន្ត្រី ........ ២៩
១.៦.៣. សមិទ្ធផលសំខាន់ៗ ........ ៣១

## ជំពូកទី ២
## ការរៀបចំគណៈរដ្ឋមន្ត្រី នីតិកាលទី ៧

**២.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត** ........ ៣៤
**២.២. ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា** ........ ៣៥
២.២.១. របៀបទី១ ........ ៣៥
២.២.២. របៀបទី២ ........ ៣៦
**២.៣. សមាសភាពគណៈរដ្ឋមន្ត្រី** ........ ៣៧
២.៣.១. នាយករដ្ឋមន្ត្រី ........ ៣៧
២.៣.២. ឧបនាយករដ្ឋមន្ត្រី ........ ៣៧
២.៣.៣. ទេសរដ្ឋមន្ត្រី ........ ៣៨
២.៣.៤. រដ្ឋមន្ត្រី ........ ៣៩
**២.៤. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈរដ្ឋមន្ត្រី** ........ ៤០
២.៤.១. នាយករដ្ឋមន្ត្រី ........ ៤០
២.៤.២. ឧបនាយករដ្ឋមន្ត្រី ........ ៤២
២.៤.៣. ទេសរដ្ឋមន្ត្រី ........ ៤២
២.៤.៤. រដ្ឋមន្ត្រី ........ ៤២

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧

**៣.១. របៀបរបបធ្វើការ និងការបែងចែកភារកិច្ច** ........ ៤៤
៣.១.១. នាយករដ្ឋមន្ត្រី ........ ៤៤

៣.១.២. ឧបនាយករដ្ឋមន្ត្រី ............ ៤៤
៣.១.៣. ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកម្មពិសេស ............ ៤៦
**៣.២. កិច្ចប្រជុំគណៈរដ្ឋមន្ត្រី** ............ ៤៨
៣.២.១. កិច្ចប្រជុំលើកទី១ ............ ៤៩
៣.២.២. កិច្ចប្រជុំអន្តរក្រសួង ............ ៤៩
៣.២.៣. កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ............ ៤៩
**៣.៣. កម្មវិធីនយោបាយ** ............ ៥០
៣.៣.១. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ............ ៥០
៣.៣.២. គោលនយោបាយធំៗ ជាអាទិភាព ............ ៥១
៣.៣.៣. គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ ............ ៥១
៣.៣.៤. កម្មវិធីគោលនយោបាយអាទិភាពទាំង ៦ ............ ៥២
**៣.៤. យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** (២០២៣ - ២០២៨) ............ ៥៣
៣.៤.១. បាវចនា, គោលដៅយុទ្ធសាស្ត្រ និងអាទិភាពគន្លឹះនៃយុទ្ធសាស្ត្រ ............ ៥៣
៣.៤.១.១ បាវចនា ............ ៥៣
៣.៤.១.២. គោលដៅយុទ្ធសាស្ត្រ ............ ៥៤
៣.៤.១.៣. អាទិភាពគន្លឹះ ៥ ............ ៥៥
៣.៤.២. រចនាសម្ព័ន្ធ ............ ៥៥
៣.៥.២.១. ស្នូល ............ ៥៥
៣.៤.២.២. បរិស្ថានគ្របដណ្ដប់ ............ ៥៦
៣.៤.២.៣. បញ្ចកោណយុទ្ធសាស្ត្រទាំង ៥ ............ ៥៧
**៣.៥. ការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធក្រសួង ស្ថាប័ន** ............ ៥៩
៣.៥.១. គោលការណ៍នៃការណែនាំរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធ ............ ៥៩
៣.៥.២. ការរៀបចំ ការបង្កើត និងការកែសម្រួលរចនាសម្ព័ន្ធ ............ ៦០
៣.៥.៣. បែបបទ និងនីតិវិធីនៃការពិគ្រោះយោបល់ ............ ៦០
**៣.៦. ការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ** (៥ សីហា ២០២៤) ............ ៦១
**សេចក្ដីសន្និដ្ឋាន** ............ ៦៣
**អនុសាសន៍** ............ ៦៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

កាលពីស្រមោលអតីតកាល កម្ពុជាធ្លាប់បានធ្លាក់ចូលទៅក្នុងការដឹកនាំតាមបែបផ្តាច់ការ ពោលគឺក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឬត្រូវប្រជាជនខ្មែរជាទូទៅសម្តៅថា៖ របបប្រល័យពូជសាសន៍) គឺជាឈ្មោះតំណាងឱ្យរបបផ្តាច់ការនៅប្រទេសកម្ពុជាពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលដឹកនាំដោយពួកខ្មែរក្រហម។ របបផ្តាច់ការនេះត្រូវបានបង្កើតឡើងបន្ទាប់ពីកងកម្លាំងខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពេញពីកងទ័ពសាធារណរដ្ឋរបស់សេនាប្រមុខ លន់ នល់។ របបប្រល័យពូជសាសន៍ខ្មែរក្រហម ប្រជាជនកម្ពុជារស់នៅដោយទទួលរងទុក្ខវេទនា ក្រោមការធ្វើទារុណ្ណកម្ម ការសម្លាប់រង្គាល សង្គ្រាមរ៉ាំរ៉ៃ មិនខុសអ្វីពីការរស់នៅក្នុងគុកឥតជញ្ជាំង អស់រយៈពេលជិតបួនឆ្នាំ ដោយភ័ព្វសំណាងកម្ពុជាបានឆ្លងផុតពីរបបខ្មៅងងឹតនេះ ក្រោមកិច្ចខិតខំប្រឹងប្រែងតស៊ូរំដោះជាតិ និងប្រជាជនកម្ពុជាពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងយុទ្ធមិត្ត បានយកដើមទន់ជីវិតអ្នកស្នេហាជាតិមួយក្រុម ដើម្បីប្តូរយកការរំដោះប្រជាជនកម្ពុជាមួយប្រទេស ហើយឈានឆ្ពោះទៅរកការបិទបញ្ចប់ភ្លើងសង្គ្រាម បិទបញ្ចប់ការបែកបាក់ជាតិ នាំមកនូវការបង្រួបបង្រួមជាតិ ឯកភាពជាតិ សុខសន្តិភាព និងការកសាងការអភិវឌ្ឍប្រទេសឈានមកដល់ការរីកចម្រើនដូចនាពេលបច្ចុប្បន្ន។

យោងតាមមាត្រា៥១ ថ្មី នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាបានចែងថា៖ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យ សេរី ពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ក្នុងន័យនេះអំណាចនីតិប្រតិបត្តិបានឆ្លុះបញ្ចាំងឱ្យឃើញថា ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនក្នុងការបោះឆ្នោតជ្រើសរើសរាជរដ្ឋាភិបាលតាមឆន្ទៈរបស់ខ្លួន។ ជាក់ស្តែងវត្តមាននៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាពិតជាមានពិតប្រាកដមែន គឺចាប់តាំងពីឆ្នាំ១៩៩៣មក កម្ពុជាបានព្យាយាមបង្ហាញមុខមាត់របស់ខ្លួនកាន់តែច្បាស់ទៅកាន់ឆាកអន្តរជាតិថា ខ្លួនគឺជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យ ដែលភស្តុតាងសំខាន់នៃការសំអាងមួយនេះបានស្តែងឡើងតាមរយៈការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលកម្ពុជាបានរៀបចំ និងអនុវត្តធ្វើជាទៀងទាត់រាល់ប្រាំឆ្នាំម្តង មានការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកទល់នឹងបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាមានចំនួន ប្រាំពីរនីតិកាលមកហើយ។

ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអនុវត្តការងាររៀបចំការបោះឆ្នោត អនុលោមតាមច្បាប់ បទបញ្ជា និងនីតិវិធី

នៃការបោះឆ្នោត រួមនឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងបានអនុញ្ញាតឱ្យភាគីពាក់ព័ន្ធនឹងការបោះឆ្នោត បានចូលរួមតាមដានសង្កេតមើលដំណើរការបោះឆ្នោតយ៉ាងទូលំទូលាយ។ ក្នុងនោះ គ.ជ.ប បានទទួលស្គាល់ និងផ្តល់បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ជាច្រើនរូប ក្រៅពីអ្នកសង្កេតការណ៍បោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាច្រើន ចូលរួមតាមដានសង្កេតមើលដំណើរការបោះឆ្នោតផងដែរ។

គណៈរដ្ឋមន្ត្រីជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ គណៈរដ្ឋមន្ត្រីនីតិកាលទី ៧ នៃរដ្ឋសភាកម្ពុជាបានប្រសូត្រឡើងនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា។ គណៈរដ្ឋមន្ត្រីបច្ចុប្បន្នគឺជា បណ្តុំនៃបញ្ញវន្ត ដែលមានការសិក្សាចេះដឹងជ្រៅជ្រះស្នេហាជាតិ ទឹកដី និងប្រជាជន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាលើប្រធានបទ គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ ឱ្យកាន់តែស៊ីជម្រៅ និងមានភាពច្បាស់លាស់ ចំណោទបញ្ហាត្រូវបានលើកឡើងដើម្បីឆ្លើយតបទៅនឹងសំណួរមួយចំនួនដូចខាងក្រោម៖

- តើគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ មកទល់នឹងបច្ចុប្បន្នមានប្រវត្តិយ៉ាងដូចម្តេច?
- តើដំណើរការនៃការបង្កើតគណៈរដ្ឋមន្ត្រី នីតិកាលទី៧នេះ មាននីតិវិធីយ៉ាងណាខ្លះ?
- តើនរណាខ្លះដែលជាសមាសភាពនៃគណៈរដ្ឋមន្ត្រី?
- តើសមាសភាពគណៈរដ្ឋមន្ត្រី មានតួនាទី ភារកិច្ច និងសិទ្ធិអំណាចយ៉ាងដូចម្តេចខ្លះ?
- របៀបរបបនៃការធ្វើការ និងការបែងចែកភារកិច្ចរបស់គណៈរដ្ឋមន្ត្រីប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?
- តើគណៈរដ្ឋមន្ត្រីមានកម្មវិធីនយោបាយយ៉ាងដូចម្តេចខ្លះ នៅក្នុងការដឹកនាំ និងការអភិវឌ្ឍប្រទេសជាតិ?
- តើអ្វីដែលជាសមិទ្ធផលជាប្រវត្តិសាស្ត្រដ៏ធំធេងរបស់គណៈរដ្ឋមន្ត្រីនានីតិកាលទី ៧នេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងក្នុងការរួមចំណែក ធ្វើអោយប្រសើរឡើងនូវការយល់ដឹងអំពីការរៀបចំការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យរបស់រាជរដ្ឋាភិបាលកម្ពុជាកន្លងមក យល់ដឹង និងស្គាល់ថ្នាក់ដឹកនាំសំខាន់ៗ របស់ប្រទេសជាតិនានីតិកាលទី១ រហូតដល់ នីតិកាលទី៧បច្ចុប្បន្ន យល់ដឹងពីតម្លៃនៃការខិតខំប្រឹងប្រែងរបស់គណៈរដ្ឋមន្ត្រីនៅក្នុងការដឹកនាំប្រទេសជាតិ ក៏ដូចជាការរួមចំណែកជាមួយរាជរដ្ឋាភិបាលមួយផ្នែកតូច

នៅក្នុងការអំពាវនាវឱ្យប្រជាជនខ្មែរ នៅតែបន្តគាំទ្រលទ្ធិប្រជាធិតេយ្យសេរីពហុបក្ស ប្តេជ្ញាការពាររបបរាជានិយម ឱ្យបានគង់វង្សស្ថិតស្ថេរជានិរន្តរ៍។ តម្លៃនៃសន្តិភាព ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សុខដុមនីយកម្ម និងការអភិវឌ្ឍរីកចម្រើនទាំងផ្នែកអាណាចក្រ និងពុទ្ធចក្រ ក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។ ដើម្បីឱ្យសន្តិភាព គង់វង្សបន្តដល់កូនចៅជំនាន់ក្រោយ និងដើម្បីជៀសឱ្យឆ្ងាយពីស្រមោលខ្មៅងងឹត ត្រូវជៀសវាងការរួមគំនិត គាំទ្រ និងចូលរួមក្រោមរូបភាពណាមួយក្នុងការធ្វើបដិវត្តន៍ពណ៌បំផ្លាញសុខសន្តិភាព។

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

សារណាស្តីពី គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ ជាប្រធានបទដែលគួរឱ្យចាប់អារម្មណ៍បំផុត និងមានវិសាលភាពគ្របដណ្តប់ទៅលើអង្គនីតិប្រតិបត្តិរួមមាន ការរៀបចំក្បាលម៉ាស៊ីនដឹកនាំប្រទេសជាតិតាមបែបលទ្ធិប្រជាធិបតេយ្យ របៀបរបបធ្វើការងារ និងកម្មវិធីនយោបាយរបស់គណៈរដ្ឋមន្ត្រី។ ដែនកំណត់នៃការស្រាវជ្រាវនេះគឺ ស្រាវជ្រាវតែក្នុងក្របខណ្ឌស្ថាប័ននីតិប្រតិបត្តិចាប់តាំងពី នីតិកាលទី១ ឆ្នាំ១៩៩៣ រហូតមកដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤ និងផ្តោតសំខាន់ទៅលើគណៈរដ្ឋមន្ត្រី នីតិកាលទី៧ បច្ចុប្បន្នតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទខាងលើនេះ បានផ្តល់សារៈសំខាន់ជាច្រើនចំពោះការសិក្សារបស់សិស្ស និស្សិត ការទទួលបាននូវចំណេះដឹងយ៉ាងទូលំទូលាយ និងយល់ដឹងយ៉ាងស៊ីជម្រៅអំពីស្ថាប័ននីតិប្រតិបត្តិរបស់កម្ពុជា នាពេលបច្ចុប្បន្ន សម្រាប់ជាគ្រឹះក្នុងការបន្តគាំទ្រមាគ៌ាដឹកនាំប្រទេសដ៏ល្អថ្លៃថ្លារបស់រាជរដ្ឋាភិបាល ដើម្បីឈានដល់ការសម្រេចបាននូវគោលដៅមហិច្ឆតារបស់រាជរដ្ឋាភិបាល គឺកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។

ការស្រាវជ្រាវនេះ បានជួយឱ្យក្រុមយើងខ្ញុំទទួលបាននូវការពង្រឹងពុទ្ធិចំណេះដឹងបន្ថែមទៀតលើការរៀបចំ និងដំណើរការប្រព្រឹត្តទៅនៃអំណាចនីតិប្រតិបត្តិ ដែលមានរាជរដ្ឋាភិបាលជាអ្នកដោះស្រាយនូវបញ្ហាជាច្រើន ដែលនៅក្នុងនោះមានការទទួលខុសត្រូវលើវិស័យសេដ្ឋកិច្ច ផែនការកម្ម វប្បធម៌ សិក្សាធិការ ហិរញ្ញវត្ថុ ឧបត្ថម្ភដល់ការរស់នៅប្រចាំថ្ងៃ និងសេចក្តីត្រូវការរបស់ប្រជាជន។

លើសពីនេះទៀត ការសិក្សាស្រាវជ្រាវនេះបានបន្សល់ទុកជាឯកសារដ៏សំខាន់បន្ថែមទៀត ដែលបម្រើផលប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយ ក្នុងការសិក្សាស្វែងយល់នូវការវិវត្តន៍របស់រាជរដ្ឋាភិបាលកម្ពុជា។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីប្រសូត្របាននូវលទ្ធផលសារណាមួយក្បាលនេះ យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រមួយចំនួនដូចខាងក្រោម៖

- តម្រូវការព័ត៌មាន៖ ការសិក្សាស្រាវជ្រាវមួយនេះបានដកស្រង់ចេញមកពីលិខិតបទដ្ឋានគតិយុត្ត ដែលរួមមានដូចជា រដ្ឋធម្មនុញ្ញ ព្រះរាជក្រម ព្រះរាជក្រឹត្យ សេចក្តីសម្រេច និងសៀវភៅកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងឯកសារមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជរដ្ឋាភិបាល។
- ការប្រមូលព័ត៌មាន៖ ការស្វែងរកឯកសារនានាដែលទាក់ទងទៅនឹងប្រធានបទខាងលើតាមបណ្ណាបណ្ណាល័យនានា ជាពិសេសបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមបណ្តាគេហទំព័រអេឡិចត្រូនិច ដែលមួយចំនួនធំជាប្រភពគេហទំព័របស់រាជរដ្ឋាភិបាល។
- វិធីសាស្ត្រវិភាគទិន្នន័យ៖ គឺប្រព្រឹត្តទៅតាមរយៈការសិក្សាវែកញែកដោយផ្ចិតផ្ចង់ជម្រាញ់យកតែប្រភពឯកសារណាដែលត្រឹមត្រូវស្របទៅតាមការពិតជាក់ស្តែង ដោយមានការដាក់ចេញនូវយុទ្ធសាស្ត្រវិភាគប្រៀបធៀបទិន្នន័យតែមួយទៅនឹងប្រភពពីរ ឬលើសពីពីរដើម្បីធានាបាននូវខ្លឹមសារដែលត្រឹមត្រូវជូនដល់ប្រិយមិត្តអ្នកអាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យប្រកបដោយគុណភាព ប្រសិទ្ធិភាព និងប្រកបដោយអត្ថន័យខ្លឹមសារយ៉ាងស៊ីជម្រៅ គឺចាំបាច់ត្រូវតែមានការបែងចែករចនាសម្ព័ន្ធនៃខ្លឹមសារឱ្យបានច្បាស់លាស់ប្រាកដប្រជាមួយ ដើម្បីបំពេញតាមលក្ខណៈវិធីសាស្ត្រស្រាវជ្រាវត្រឹមត្រូវរបស់សាកលវិទ្យាល័យបានកំណត់។

រចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទស្តីពី «គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៧» រួមមានដូចខាងក្រោម៖

- **សេចក្តីផ្តើម**៖ ការបង្ហាញត្រួសត្រាយផ្លូវជូនដល់ប្រិយមិត្តអ្នកអានឱ្យបានជ្រាបអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី ១**៖ និយាយអំពីប្រវត្តិគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមាន ៦ផ្នែក ស្មើនឹង ៦ នីតិកាល រួមមាន នីតិកាលទី១ ឆ្នាំ១៩៩៣-១៩៩៨, នីតិកាលទី២ ឆ្នាំ១៩៩៨-២០០៣, នីតិកាលទី៣ ឆ្នាំ២០០៣-២០០៨, នីតិកាលទី៤ ឆ្នាំ២០០៨-២០១៣, នីតិកាលទី៥ ឆ្នាំ២០១៣-២០១៨, និង នីតិកាលទី៦ ឆ្នាំ២០១៨-២០២៣។

- **ជំពូកទី ២៖** រៀបរាប់ពីការរៀបចំគណៈរដ្ឋមន្ត្រី នីតិកាលទី៧ ដែលបានបែកចែកជា ៤ផ្នែកដូចជា ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត, ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា, សមាសភាពគណៈរដ្ឋមន្ត្រី, និងតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈរដ្ឋមន្ត្រី។
- **ជំពូកទី ៣៖** ស្តីអំពី ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នីតិកាលទី៧ ដែលត្រូវបកស្រាយនូវ ៦ផ្នែកគឺ របៀបរបបការងារ និងការបែងចែកភារកិច្ច, កិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី, កម្មវិធីនយោបាយ, យុទ្ធសាស្ត្រ បញ្ចកោណ-ដំណាក់កាលទី១, ការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន, និងការបើក ការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ។
- **សេចក្តីសន្និដ្ឋាន អនុសាសន៍ ឯកសារយោង និងឧបសម្ព័ន្ធ។**

# ជំពូកទី ១

## ប្រវត្តិគណៈរដ្ឋមន្ត្រីនៃ
## ព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ១

# ប្រវត្តិគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

គណៈរដ្ឋមន្ត្រីជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា[1]។

## ១.១. នីតិកាលទី១ (ឆ្នាំ១៩៩៣ - ១៩៩៨)

### ១.១.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត

កិច្ចព្រមព្រៀងទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បាននាំមកនូវការបោះឆ្នោតជាសកលនីតិកាលទី១ និងបានរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា “UNTAC”។ ប្រជាជនកម្ពុជាជាង ៤ លាន នាក់ (ប្រហែល ៩០% នៃអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត) បានចូលរួមនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចាប់ពីថ្ងៃទី២៣ រហូតដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣[2]។

សភាធម្មនុញ្ញកើតពីការបោះឆ្នោតនៅថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ ចាត់ចែងដោយអ៊ុនតាក់តាមប្រព័ន្ធសមាមាត្រមាន ២១ ខេត្ត-ក្រុង ជាមណ្ឌលបោះឆ្នោត ដោយមានគណបក្សនយោបាយ ចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន១៩[3]។

គណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ចំនួន ៤៖

| | | |
|---|---|---|
| ១. | គណបក្សហ៊្វុនស៊ិនប៉ិច | ៥៨ អាសនៈ |
| ២. | គណបក្សប្រជាជនកម្ពុជា | ៥១ អាសនៈ |
| ៣. | គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា | ១០ អាសនៈ |
| ៤. | គណបក្សម្លូលីណាកា | ០១ អាសនៈ[4]។ |

### ១.១.២. ការបង្កើតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

គណបក្សហ៊្វុនស៊ិនប៉ិចរាជានិយមរបស់ **ព្រះអង្គម្ចាស់រណឫទ្ធិ** គណបក្សប្រជាជនកម្ពុជារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** (ប្រជាពលរដ្ឋខ្មែរ មួយភាគធំ ដឹងគុណថ្ងៃ៧មករា និងស្មោះស្ម័គ្រជាមួយបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន

---

[1] មាត្រា១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[2] រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, *សមាសភាពសមាជិករដ្ឋសភា នីតិកាលទី ១ នៃព្រះរាជាណាចក្រកម្ពុជា*, អាចរកបាននៅ https://nac.org.kh/group-article/47 (ចូលទស្សនាថ្ងៃទី ២១ មេសា ២០២៤)។

[3] ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា, *សៀវភៅស្តីពីសភាកម្ពុជា*, (ភ្នំពេញ៖ STC (JSRC) Printing House, ២០២១), ៥២។

[4] ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា, *សៀវភៅស្តីពីសភាកម្ពុជា*, (ភ្នំពេញ៖ STC (JSRC) Printing House, ២០២១), ៥៣។

ដើម្បីប្រយោជន៍ជាតិមាតុភូមិ **សម្តេចតេជោ** ក្នុងការយកជីវិតធ្វើជាដើមទន់រំដោះជាតិ និងប្រជាជនខ្មែរពីរបបប្រល័យពូជសាសន៍ ប៉ុល ពត) និងគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា បានសំឡេងរៀងៗគ្នា។ គណបក្សទាំងប៉ុន្មានខាងលើបានជ្រើសតាំងបានសមាជិកសភា ១២០ រូប ហើយក៏បានចាត់ចែងពង្រាង និងអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយ ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ នៅមុខព្រះបរមរាជវាំងរាជធានីភ្នំពេញនៃប្រទេសកម្ពុជាចាប់តាំងពីព្រឹកព្រលឹម កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទនៃកងខេមរភូមិន្ទមានឯកសណ្ឋានដូចកងខេមរភូមិន្ទសម័យសង្គមរាស្ត្រនិយម ប្រជារាស្ត្រប្រុសស្រីក្នុងរាជធានីភ្នំពេញប្រកបដោយសម្លៀកបំពាក់សមរម្យ ប្រមាណជាង ៣០,០០០ នាក់ (បីម៉ឺននាក់) បានអញ្ជើញជួបជុំគ្នា ដើម្បីប្រារព្ធមីទ្ទីងជាប្រវត្តិសាស្ត្រដ៏ធំមួយ ដើម្បីអបអរសាទររដ្ឋធម្មនុញ្ញថ្មីដែល **សម្តេច នរោត្តម សីហនុ** បានឡាយព្រះហស្តលេខានាព្រឹកថ្ងៃទី២៤ កញ្ញា ឆ្នាំ១៩៩៣ នោះ។ ទ្រង់បានប្រកាសថាៈ ចាប់ពីថ្ងៃទី២៤ ខែកញ្ញា (១៩៩៣) នេះតទៅ យើងហ៊ានអះអាងថា កម្ពុជានឹងបានទទួលនូវរដ្ឋធម្មនុញ្ញមួយប្រកបដោយលទ្ធិប្រជាធិបតេយ្យ សេរីភាពទូលំទូលាយដ៏ប្រពៃបំផុត ហើយមាតុភូមិកម្ពុជា នឹងឈានចូលដោយមោទនភាពក្នុងចំណោមប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដជាងគេក្នុងលោក[5]។

រដ្ឋធម្មនុញ្ញក៏បានបង្កើតឡើងនូវ របបប្រជាធិបតេយ្យ សេរីពហុបក្ស ក្នុងក្របខណ្ឌ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែល **សម្តេចព្រះសីហនុ** បានឡើងគ្រងរាជ្យជាព្រះមហាក្សត្រ។ **សម្តេចតេជោ** គឺជាតួអង្គដ៏សំខាន់ នាំមកវិញនូវរបបរាជានិយមនៅកម្ពុជា។ ជាការចាប់ផ្តើម គឺ **សម្តេចតេជោ** គឺជាអ្នកយាង **សម្តេច នរោត្តម សីហនុ** ចូលមកប្រទេសកម្ពុជា មុនពេលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសទៅទៀត។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ **សម្តេចតេជោ** ជាតួអង្គសំខាន់បំផុត ដែលនាំឱ្យកម្ពុជាចែងអំពីរបបរាជានិយម អាស្រ័យធម្មនុញ្ញ។ បើគ្មានការរួមចំណែកដ៏សំខាន់មិនអាចខ្វះបានរបស់ **សម្តេចតេជោ ហ៊ុន សែន** ទេនោះ របបរាជានិយមនៅកម្ពុជា ប្រហែលជាមិនអាចចារឹកក្នុងរដ្ឋធម្មនុញ្ញនោះឡើយ។ **សម្តេចតេជោ** គឺជាអ្នកការពាររាជបល្ល័ង្កដ៏ពិតប្រាកដ[6]។ **ព្រះអង្គម្ចាស់រណឫទ្ធិ** និង **សម្តេចតេជោ ហ៊ុន សែន** បានក្លាយជានាយករដ្ឋមន្ត្រីទីមួយ និងទីពីររៀងគ្នាក្នុងរាជរដ្ឋាភិបាលកម្ពុជា។ រដ្ឋធម្មនុញ្ញផ្តល់ឲ្យនូវការគោរពសិទ្ធិមនុស្សពេញទីដែលទទួលស្គាល់ដោយអន្តរជាតិ។ ព្រះមហាក្សត្រទ្រង់បានតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋ-

---

[5] គណបក្សប្រជាជនកម្ពុជា, *ប្រវត្តិនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣*, ២៥ កញ្ញា ២០១៩, អាចរកបាននៅ https://www.cpp.org.kh/details/156858 (ចូលទស្សនាថ្ងៃទី១០ ឧសភា ឆ្នាំ២០២៤)។

[6] FRESH NEWS, *បណ្ឌិត គិន ភាៈ មានសមិទ្ធផលសំខាន់ៗចំនួន៩ ដែល* ***សម្តេចតេជោ*** *នាំមកជូនប្រជាជាតិកម្ពុជា ក្នុងឋានៈជានាយករដ្ឋមន្ត្រី ៣៨ឆ្នាំមកនេះ*, ១៤ មករា ២០២៣, អាចរកបាននៅ https://m.freshnewsasia.com/index.php/en/localnews/274165-2023-01-14-04-59-11.html (ចូលទស្សនាថ្ងៃទី០៨ មេសា ២០២៤) ។

មន្ត្រីទី២ តាមមាត្រា១៣៨ នៃរដ្ឋធម្មនុញ្ញ នាយករដ្ឋមន្ត្រីទាំងពីររូប មានសិទ្ធិអំណាច និងបុព្វសិទ្ធិស្មើៗគ្នា ដើម្បីដឹកនាំរាជរដ្ឋាភិបាលដោយឈរលើគោលការណ៍សហព័ទ្ធសម្រេច[7]។

### ១.១.៣. សមាសភាពគណៈរដ្ឋមន្ត្រី

សមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី១ មានដូចជា៖

**I. សហនាយករដ្ឋមន្ត្រី៖**

- នាយករដ្ឋមន្ត្រីទី១ **ព្រះអង្គស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ**
- នាយករដ្ឋមន្ត្រីទី២ **ឯកឧត្តម ហ៊ុន សែន**។

**II. ឧបនាយរដ្ឋមន្ត្រី៖** ១. ព្រះអង្គម្ចាស់ នរោត្តម សិរីវុឌ្ឍ និង ២. ឯកឧត្តម ស ខេង។

**III. ទេសរដ្ឋមន្ត្រី៖** ១. ឯកឧត្តម អ៊ឹង គៀត, ២. ឯកឧត្តម គាត ឈន់ (ទទួលបន្ទុកកិច្ចការពិនិត្យសម្បទា និងអភិវឌ្ឍន៍), ៣. ឯកឧត្តម អ៊ុង ផន (ទទួលបន្ទុកអធិការកិច្ច), ៤. ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ (ទទួលបន្ទុកកិច្ចការវប្បធម៌ វិចិត្រសិល្បៈ), ៥. ឯកឧត្តម ចែម ស្ងួន និង ៦. ឯកឧត្តម សម រង្ស៊ី។

**IV. រដ្ឋមន្ត្រី និងរដ្ឋលេខាធិការតាមបណ្តាក្រសួង ស្ថាប័ន៖**

| | |
|---|---|
| ១. ទីស្តីការគណៈរដ្ឋមន្ត្រី: ឯកឧត្តម សុខ អាន និង ឯកឧត្តម វ៉េង សិរីវុឌ្ឍ | សហរដ្ឋមន្ត្រី |
| ២. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ: ព្រះអង្គម្ចាស់ នរោត្តម សិរីវុឌ្ឍ | រដ្ឋមន្ត្រី |
| ៣. ក្រសួងការពារជាតិ: ឯកឧត្តម ទៀ បាញ់ និង ឯកឧត្តម ទា ចំរ៉ាត់ | សហរដ្ឋមន្ត្រី |
| ៤. ក្រសួងមហាផ្ទៃ: ឯកឧត្តម ស ខេង និង ឯកឧត្តម យូ ហុងគ្រី | សហរដ្ឋមន្ត្រី |
| ៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: ឯកឧត្តម សម រង្ស៊ី | រដ្ឋមន្ត្រី |
| ៦. ក្រសួងព័ត៌មាន: ឯកឧត្តម អៀង មូលី | រដ្ឋមន្ត្រី |
| ៧. ក្រសួងសាធារណៈការ និងដឹកជញ្ជូន: ឯកឧត្តម អ៊ឹង គៀត | រដ្ឋមន្ត្រី |
| ៨. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ: ឯកឧត្តម គង់ សំអុល | រដ្ឋមន្ត្រី |
| ៩. ក្រសួងយុត្តិធម៌: ឯកឧត្តម ចែម ស្ងួន | រដ្ឋមន្ត្រី |
| ១០. ក្រសួងអប់រំ យុវជន និងកីឡា: ឯកឧត្តម អ៊ឹង ហួត | រដ្ឋមន្ត្រី |
| ១១. ក្រសួងពាណិជ្ជកម្ម: ឯកឧត្តម វ៉ា ហួត | រដ្ឋមន្ត្រី |
| ១២. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល: ឯកឧត្តម ពូ សុធីរៈ | រដ្ឋមន្ត្រី |
| ១៣. ក្រសួងផែនការ: ឯកឧត្តម ជា ចាន់តូ | រដ្ឋមន្ត្រី |
| ១៤. ក្រសួងសុខាភិបាល: ឯកឧត្តម ឈា ថាំង | រដ្ឋមន្ត្រី |

[7] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, លេខ ០២/នស/៩៤, ២០ កក្កដា ១៩៩៤, មាត្រា៤។

១៥. ក្រសួងទេសចរណ៍: ឯកឧត្តម វ៉េង សិរីវុឌ្ឍ រដ្ឋលេខាធិការ

១៦. ក្រសួងធម្មការ និងសាសនា: ឯកឧត្តម ហៀង វណ្ណរ័ត្ន រដ្ឋលេខាធិការ

១៧. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍: ឯកឧត្តម សូរ យុន រដ្ឋលេខាធិការ

១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ: ឯកឧត្តម នុត ណារ៉ាង រដ្ឋលេខាធិការ

១៩. ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន: ឯកឧត្តម ស៊ុយ សែម រដ្ឋលេខាធិការ។

❖ រដ្ឋលេខាធិការដ្ឋាន ចំណុះទីស្តីការគណៈរដ្ឋមន្ត្រីៈ

១. រដ្ឋលេខាធិការដ្ឋានបរិស្ថាន: ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋលេខាធិការ

២. រដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ: ឯកឧត្តម ហុង ស៊ុនហួត រដ្ឋលេខាធិការ

៣. រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា: ឯកឧត្តម សាយ បូរី រដ្ឋលេខាធិការ

៤. រដ្ឋលេខាធិការដ្ឋានកិច្ចការនារី: ឯកឧត្តម គៀត សុគន្ធ រដ្ឋលេខាធិការ[8]។

#### ១.១.៣.១. ករណីពិសេស នាយករដ្ឋមន្ត្រី ២រូប

ករណីប្រទេសកម្ពុជា មាននាយករដ្ឋមន្ត្រី ២ រូប នេះជាករណីពិសេសជាប្រវត្តិសាស្ត្រមួយ ហើយបានផ្តល់នូវគតិអប់រំដ៏មានអត្ថន័យយ៉ាងជ្រាលជ្រៅ ថ្នាក់ដឹកនាំបានបន្សល់ទុកនូវគោលគំនិតអប់រំដល់កូនខ្មែរជំនាន់ក្រោយៗថា “**ក្នុងកាលៈទេសៈគ្រោះថ្នាក់ ខ្មែរត្រូវតែរួបរួមសាមគ្គីគ្នា ដើម្បីផលប្រយោជន៍រួមរបស់ជាតិ មិនមែនផលប្រយោជន៍របស់បក្សពួកណាមួយឡើយ**”[9]។ គួរកត់សម្គាល់ថា កម្ពុជាបានរៀបចំការចែករំលែកអំណាចដ៏ពិសេសនេះយ៉ាងត្រឹមត្រូវ និងឈរលើគោលការណ៍រួបរួមសាមគ្គីជាតិ។ ការរៀបចំឱ្យមាននាយករដ្ឋមន្ត្រីពីររូបនេះបានធ្វើឡើងពីសំណាក់រដ្ឋាភិបាលចម្រុះ ដែលបានបង្កើតឡើងបន្ទាប់ពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ ដែលមានគោលបំណងក្នុងការថែរក្សាស្ថេរភាពប្រទេស បន្ទាប់ពីមានជម្លោះជាច្រើនឆ្នាំកន្លងមក។ ដោយឈរលើមូលដ្ឋាននៃការចែករំលែកអំណាចនេះហើយ ទើបធ្វើឱ្យការចែករំលែកអំណាចក្លាយទៅជាពន្លឺ សម្រាប់បំភ្លឺផ្លូវទៅរកមាគ៌ាសុខសន្តិភាពនានីតិកាលទី២។

### ១.១.៤. ការបង្ក្រាបបទល្មើសច្បាប់ក្នុងឆ្នាំ១៩៩៧

នៅដើមខែកក្កដា ឆ្នាំ១៩៩៧ ដែលជាពេលវេលាដែលបានផ្ទុះសង្គ្រាមនៅក្នុងរាជធានីភ្នំពេញ ប៉ែកខាងលិចធ្វើឱ្យកក្រើករាជធានីភ្នំពេញទាំងមូល។ ព្រឹត្តិការណ៍ដែលបានកើតឡើង មិនមែនជាជម្លោះរវាងគណបក្សមួយ និង

---

[8] យល់ដឹងពីកម្ពុជា, *សមាសភាពគណៈរដ្ឋមន្ត្រីនីតិកាលទី១ នៃរដ្ឋសភា*, ១៦ មករា ២០១៩, អាចរកបាននៅ https://www.facebook.com/photo/?fbid=1351878421620141&set=pcb.1351878704953446&locale=th_TH (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២៤)។

[9] ទស្សនៈយល់ឃើញរបស់ លោក ហេន ឡង់ឌី, និស្សិតរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤។

គណបក្សមួយ មិនមែនជាសង្គ្រាមស៊ីវិល មិនមែនជារដ្ឋប្រហារដណ្តើមអំណាច ព្រោះគ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួន គ្មានច្បាប់អាជ្ញាសឹក គ្មានកំណែនទូទៅ តែជាការបង្ក្រាបបទល្មើសច្បាប់ ដែលមានចរិតយោធានយោបាយ និងសន្តិសុខជាតិ ដែលព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងបក្សពួកជ្រុលនិយមបានបង្កឡើង[10]។

ព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ សមាជិករដ្ឋសភាចំនួន៩៨ រូប លើ ៩៩ រូប ដែលបានចូលរួមប្រជុំ បានអនុម័តដោយលើកដៃគាំទ្រការលើកអភ័យឯកសិទ្ធិសភាពីព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ។ រដ្ឋសភាបានសម្រេចកិច្ចការដ៏សំខាន់មួយទៀត ដើម្បីធានានិរន្តរភាពនៃរដ្ឋាភិបាលចម្រុះ ដែលកើតចេញពីការបោះឆ្នោតឆ្នាំ១៩៩៣ ដោយបានធ្វើការបោះឆ្នោតដោយសម្ងាត់ជ្រើសរើសលោក អ៊ឹង ហួត ជានាយករដ្ឋមន្ត្រីទី១ ជំនួសព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ[11]។

## ១.២. នីតិកាលទី២ (ឆ្នាំ១៩៩៨ - ២០០៣)

### ១.២.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត

ចាប់តាំងពីនីតិកាលទី២នេះមក ប្រទេសកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិរៀបចំបោះឆ្នោត (គ.ជ.ប) សម្រាប់រៀបចំការបោះឆ្នោតដោយខ្លួនឯង។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលត្រូវបានប្រកាសឲ្យប្រើក្នុងឆ្នាំ១៩៩៧[12]។ រដ្ឋសភា នីតិកាលទី២ កើតពីការបោះឆ្នោតសកល នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ តាមប្រព័ន្ធសមាមាត្រ មាន ២៣ ខេត្ត ក្រុង ជាមណ្ឌលបោះឆ្នោត (មានក្រុងពីរបង្កើតថ្មី គឺក្រុងកែប និងក្រុងប៉ៃលិន) ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះបោះឆ្នោតចំនួន ៣៩។

គណបក្សមានអាសនៈក្នុងរដ្ឋសភាចំនួន ៣ រួមមាន៖

១. គណបក្សប្រជាជនកម្ពុជា ៦៤ អាសនៈ
២. គណបក្សហ៊្វុនស៊ិនប៉ិច ៤៣ អាសនៈ
៣. គណបក្សសមរង្ស៊ី ១៥ អាសនៈ[13]។

---

[10] រាជបណ្ឌិត្យសភាកម្ពុជា, *ព្រឹត្តិការណ៍ថ្ងៃទី៥-៦ កក្កដា ១៩៩៧*, ០៧ ឧសភា ២០២០, អាចរកបាននៅ https://rac.gov.kh/posts/838 (ចូលទស្សនាថ្ងៃទី២០ មេសា ២០២៤)។

[11] គេហទំព័រខាងលើដដែល។

[12] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប), *សមាសភាព គ.ជ.ប ពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន*, អាចរកបាននៅ https://www.nec.gov.kh/khmer/content/4771 (ចូលទស្សនាថ្ងៃទី១០ ឧសភា ២០២៤)។

[13] ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា, *សៀវភៅស្តីពីសភាកម្ពុជា*, (ភ្នំពេញ៖ STC (JSRC) Printing House, ២០២១), ទំព័រ ៦៥។

អាសនៈសរុប មានចំនួន ១២២ ហើយបានទៅលើគណបក្សប្រជាជនកម្ពុជាច្រើនអាសនៈជាងគេ។ លទ្ធផលនេះបានបង្ហាញថា៖ បក្សប្រជាជនកម្ពុជាឈ្នះឆ្នោត ដោយសំឡេងភាគច្រើន ដោយសារពលរដ្ឋមួយភាគធំនៅតែដឹងគុណថ្ងៃ៧មករា ដោយមិនអាចបំភ្លេចបាន។

### ១.២.២. សមាសភាពគណៈរដ្ឋមន្ត្រី

សមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី២ មានដូចជា៖

I. **នាយករដ្ឋមន្ត្រី៖ សម្តេច ហ៊ុន សែន**។

II. **ឧបនាយករដ្ឋមន្ត្រី៖** ១.ឯកឧត្តម ស ខេង និង ២.ឯកឧត្តម តុល ឡោះ។

III. **ទេសរដ្ឋមន្ត្រី៖** ១.ឯកឧត្តម ទៀ បាញ់, ២.ឯកឧត្តម គាត ឈន់, ៣.ឯកឧត្តម សុខ អាន, ៤.ឯកឧត្តម-ហោ ណាំហុង, ៥.ឯកឧត្តម លី ឡាយស្រេង, ៦.ឯកឧត្តម ឈឹម សៀកឡេង, ៧.ឯកឧត្តម ហុង ស៊ុនហួត និង ៨.ឯកឧត្តម យូ ហុកគ្រី។

IV. **រដ្ឋមន្ត្រី និងរដ្ឋលេខាធិការតាមបណ្តាក្រសួង ស្ថាប័ន៖**

| | | |
|---|---|---|
| ១. | ទីស្តីការគណៈរដ្ឋមន្ត្រី: ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រី |
| ២. | ក្រសួងការពារជាតិ: ឯកឧត្តម ទៀ បាញ់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន | សហរដ្ឋមន្ត្រី |
| ៣. | ក្រសួងមហាផ្ទៃ: ឯកឧត្តម សខេង និង ឯកឧត្តម យូ ហុកគ្រី | សហរដ្ឋមន្ត្រី |
| ៤. | ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច: ឯកឧត្តម ឃុន ហាំង | រដ្ឋមន្ត្រី |
| ៥. | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ: ឯកឧត្តម ហោ ណាំហុង | រដ្ឋមន្ត្រី |
| ៦. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: ឯកឧត្តម គាត ឈន់ | រដ្ឋមន្ត្រី |
| ៧. | ក្រសួងព័ត៌មាន: ឯកឧត្តម លី ឡាយស្រេង | រដ្ឋមន្ត្រី |
| ៨. | ក្រសួងសុខាភិបាល: ឯកឧត្តម ហុង ស៊ុនហួត | រដ្ឋមន្ត្រី |
| ៩. | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល: ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រី |
| ១០. | ក្រសួងផែនការ: ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រី |
| ១១. | ក្រសួងពាណិជ្ជកម្ម: ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ១២. | ក្រសួងអប់រំ យុវជន និងកីឡា: ឯកឧត្តម តុល ឡោះ | រដ្ឋមន្ត្រី |
| ១៣. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ: ឯកឧត្តម ច័ន្ទ សារុន[14] | រដ្ឋមន្ត្រី |
| ១៤. | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ: សម្តេចព្រះរាម នរោត្តម បុប្ផាទេវី | រដ្ឋមន្ត្រី |

[14] ឯកឧត្តម ច័ន្ទ សារុន ជំនួសឯកឧត្តម ឈា សុង នៅខែសីហា ឆ្នាំ២០០១។

១៥. ក្រសួងបរិស្ថាន: ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រី

១៦. ក្រសួងអភិវឌ្ឍន៍ជនបទ: ឯកឧត្តម លីធុជ[15] រដ្ឋមន្ត្រី

១៧. ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា: ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី

១៨. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍: ឯកឧត្តម សូរ យុន រដ្ឋមន្ត្រី

១៩. ក្រសួងធម្មការ និងកិច្ចការសាសនា: ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រី

២០. ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន: លោកជំទាវ មូរ សុខហួរ រដ្ឋមន្ត្រី

២១. ក្រសួងសាធារណៈការ និងដឹកជញ្ជូន: ឯកឧត្តម ឃី តាំងលឹម រដ្ឋមន្ត្រី

២២. ក្រសួងយុត្តិធម៌: ឯកឧត្តម នាវ ស៊ីថុង[16] រដ្ឋមន្ត្រី

២៣. ក្រសួងទេសចរណ៍: ឯកឧត្តម វ៉េង សិរីវុឌ្ឍ រដ្ឋមន្ត្រី

២៤. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់: ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រី

២៥. ក្រសួងធនធានទឹក និងឧតុនិយម: ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រី

❖ រដ្ឋលេខាធិការដ្ឋានចំណុះទីស្ដីការគណៈរដ្ឋមន្ត្រីៈ

១. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ: ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋលេខាធិការ

២. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល: ឯកឧត្តម ប៉ុក សំឯល រដ្ឋលេខាធិការ[17]។

### ១.២.៣. នយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាពពេញលេញ

និយាយពីនយោបាយឈ្នះឈ្នះ យើងប្រាកដជានឹកឃើញភ្លាមដល់ **សម្ដេចតេជោ ហ៊ុន សែន** ដែលជាបិតាស្ថាបនិក និងប្រតិបត្តិករផ្ទាល់ក្នុងបេសកកម្មស្វែងរកសន្តិភាព និងការផ្សះផ្សាជាតិជូនមាតុភូមិកម្ពុជា។ នយោបាយឈ្នះឈ្នះ ដែលជារូបមន្តដ៏ស័ក្តិសិទ្ធិ និងជាស្នាដៃឯករបស់ **សម្ដេចតេជោ ហ៊ុន សែន** បានបញ្ចប់ទាំងស្រុងនូវសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃដែលបានអូសបន្លាយជិត៣ទសវត្សរ៍ និងដែលបានរុញច្រានប្រទេសឱ្យធ្លាក់ចូលក្នុងរបបវាលពិឃាដដ៏មហាប្រល័យ។

ទីបំផុត សន្តិភាពពេញលេញនៅកម្ពុជាត្រូវបានរកឃើញនៅថ្ងៃទី**២៩ ខែធ្នូ ឆ្នាំ១៩៩៨** ដោយស្នាដៃ **«រដ្ឋបុរស»** ខ្មែរឈ្មោះ **តេជោសែន** ដោយប្រើរូបមន្តពិសេសគ្មានពីរឈ្មោះថា **«នយោបាយឈ្នះ-ឈ្នះ»** ដើម្បី

---

[15] ឯកឧត្តម លី ធុជ ជំនួសឯកឧត្តម ឈឹម សៀកឡេង។

[16] ឯកឧត្តម នាវ ស៊ីថុង ជំនួសឯកឧត្តម អ៊ុក វិធុន។

[17] យល់ដឹងពីកម្ពុជា, *សមាសភាពគណៈរដ្ឋមន្ត្រីនីតិកាលទី២ នៃរដ្ឋសភា*, ១៦ មករា ២០១៩, អាចរកបាននៅ https://www.facebook.com/photo?fbid=1351880091619974&set=pcb.1351880321619951&locale=th_TH (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤)។

ប្រែក្លាយសង្គ្រាមឱ្យទៅជាសន្តិភាពដែលសូម្បីតែអង្គការសហប្រជាជាតិបានចំណាយថវិកា ២,០០០ លានដុល្លារ ក៏មិនទាន់អាចរកសន្តិភាពពេញលេញជូនកម្ពុជាបាននៅឡើយ។

ដែលហៅថា នយោបាយឈ្នះ-ឈ្នះគឺជាការបញ្ចប់សង្គ្រាមដោយគ្មានការបង្ហូរឈាម និងគ្មានអ្នករងគ្រោះ ពោលគឺខ្មែរឈ្នះទាំងអស់គ្នា។ អាថ៌កំបាំងនៃនយោបាយឈ្នះឈ្នះត្រូវបាន **សម្ដេចតេជោ** បង្ហាញជាសាធារណៈ រួចហើយដោយវាមានធាតុផ្សំសំខាន់៣គឺៈ **ទី១ៈ ធានាអាយុជីវិត ទី២ៈ ធានាអាជីពនិងមុខរបរ និងទី៣ៈ ធានាកម្មសិទ្ធិឯកជន ជូនដល់គូរជម្លោះ**[18]។ ដោយសារសន្តិភាពទើបកម្ពុជាមានអ្វីៗដូចសព្វថ្ងៃ។ ការបញ្ចប់សង្គ្រាមតាមរូបមន្តពិសេសបែបនេះកម្រកើតមានខ្លាំងណាស់នៅក្នុងពិភពលោកដែលភ្លើងសង្គ្រាមកំពុងបន្តឆាបឆេះនៅច្រើនកន្លែង។

ជាក់ស្តែង ខណៈដែលប្រជាពលរដ្ឋនៃប្រទេសជាច្រើនកំពុងរងទុក្ខដោយសារសង្គ្រាម និងកំពុងស្រែកដង្ហោយរកសន្តិភាព ប្រជាពលរដ្ឋខ្មែរកំពុងជ្រកក្រោមម្លប់ដ៏ត្រជាក់ត្រជុំនៃសន្តិភាព។ ខណៈដែលប្រជាជនរាប់រយលាននាក់លើភពផែនដីកំពុងបួងសួងសុំសន្តិភាព ប្រជាពលរដ្ឋខ្មែរកំពុងនិយាយដោយអំណរថា “**អរគុណសន្តិភាព**”។ ដូច្នេះ ពិភពលោកដែលកំពុងព្យាយាមដោយលំបាកលំបិនបំផុតក្នុងការពន្លត់ភ្លើងសង្គ្រាម ជាពិសេសប្រទេសដែលកំពុងមានសង្គ្រាមដោយផ្ទាល់គួរតែមកសិក្សាពីនយោបាយឈ្នះឈ្នះរបស់កម្ពុជាដែលជារូបមន្តដ៏ស័ក្តិសិទ្ធិ និងល្អឯកក្នុងការបញ្ចប់សង្គ្រាមដោយគ្មានអ្នកចាញ់។

**សម្ដេចតេជោ** បានថ្លែងថា ទោះបីនយោបាយឈ្នះឈ្នះផ្ដួចផ្ដើមដោយសម្ដេច តែវាមិនអាចជោគជ័យឡើយ បើគ្មានការគាំទ្រពី **សម្ដេច ជា ស៊ីម**, **សម្ដេច ហេង សំរិន** និងសមាជិក សមាជិកា គណបក្សប្រជាជនទេនោះ។ **សម្ដេចតេជោ ហ៊ុន សែន** បានថ្លែងអំណរគុណសម្ដេច ជា ស៊ីម សម្ដេច ហេង សំរិន សមាជិក សមាជិកា សម្ដេចក្រុមព្រះ កងកម្លាំងខ្មែរ រួមនឹងជនរួមជាតិទាំងអស់ ដែលបានគាំទ្រដល់ការអនុវត្តន៍នយោបាយឈ្នះ-ឈ្នះនេះ។ **សម្ដេច តេជោ ហ៊ុន សែន** បានបន្តថ្លែងថា នយោបាយឈ្នះឈ្នះនេះ បើមានត្រឹមតែគំនិតហើយគ្មានអ្នកប្រតិបត្តិករទេនោះ គឺមិនអាចទទួលបានជោគជ័យនោះឡើយ។ ត្រង់ចំណុចនេះ គឺសម្ដេចសម្ដៅដល់មនុស្សជំនិតទាំងឡាយ ដែលបានចូលរួមប្រតិបត្តិរហូតនយោបាយឈ្នះ-ឈ្នះទទួលបានជោគជ័យ។

[18] ទីស្តីការគណៈរដ្ឋមន្ត្រី, *នយោបាយឈ្នះ-ឈ្នះ គឺជារូបមន្តបញ្ចប់សង្គ្រាមដ៏ល្អឯករបស់កម្ពុជា ដែលពិភពលោកគួររៀនសូត្រ*, ១ វិច្ឆិកា ២០២៣ ដោយ ឯកឧត្តម ប៉ែន បូណា, អាចរកបាននៅ https://pressocm.gov.kh/archives/86670 (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២៤។

**សម្តេចតេជោ ហ៊ុន សែន** បានចាត់ទុក **សម្តេច ទៀ បាញ់** ជាសេនាងករបស់សម្តេចក្នុងការអនុវត្តទាំងនយោបាយឈ្នះ-ឈ្នះ និងកិច្ចការសំខាន់ៗរបស់ជាតិដទៃទៀត[19]។

### ១.២.៤. សមិទ្ធផលសំខាន់ៗ

រាជរដ្ឋាភិបាលនីតិកាលទី ២ មានសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ដូចជា៖

- បានបំផ្លាញចោលអាវុធចំនួន ១១១,០៥៥ ដើម ដោយកិន និងដុត។
- ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលយ៉ាងខ្លាំងក្លា លើសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន លទ្ធផលបានធ្វើអោយសហរដ្ឋអាមេរិកទទួលស្គាល់ និងប្រកាសលុបឈ្មោះប្រទេសកម្ពុជាចេញពីបញ្ជីខ្មៅ ក្នុងចំណោមបណ្តាប្រទេស ដែលមានចរាចរគ្រឿងញៀនខុសច្បាប់ទៅកាន់សហរដ្ឋអាមេរិក កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១។
- បានបង្កើតតុលាការកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-១៩៧៩។ តុលាការនេះមានឈ្មោះថា **អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ឬហៅថា សាលាក្តីខ្មែរក្រហម) ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
- សម្រេចតម្លើងប្រាក់ខែជូនមន្ត្រីរាជការគិតជាមធ្យម ៤៤ ភាគរយ បន្ថែមប្រាក់គរុកោសល្យជូនគ្រូបង្រៀន និងតម្លើងប្រាក់បំណាច់ពិសេស ជូនចៅក្រមថែមទៀត។
- រាជរដ្ឋាភិបាលបានបន្តអនុវត្តកម្មវិធីកាត់រំសាយកងទ័ព ក្នុងគោលដៅបង្វែរអាទិភាពចំណាយ ពីវិស័យការពារជាតិ និងសន្តិសុខជាតិ ទៅចំណាយសម្រាប់ការអភិវឌ្ឍសង្គមកិច្ច និងសេដ្ឋកិច្ច។
- ប្រកាសលុបចោលសកម្មភាពរោងចក្រអារឈើ និងរោងម៉ាស៊ីនអារឈើនៅទូទាំងប្រទេស ។
- ចាប់ពីឆ្នាំ១៩៩៨ ដល់២០០៣ ការដាំដើមឈើលើផ្ទៃដីតំបន់ព្រៃរិចរិល សម្រេចចំនួន ៥.៦០២ ហិកតា។ ចែកកូនឈើអោយប្រជាពលរដ្ឋ ដាំសរុបបាន ១០,៦២៩,៣០៩ ដើម[20]។
- ព្រះរាជាណាចក្រកម្ពុជា បានកាន់កាប់អាសនៈរបស់ខ្លួន ឡើងវិញនៅអង្គការសហប្រជាជាតិ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៩៨។ និងបានចូលជា**សមាជិកអាស៊ានទី១០ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩**។
- ឆ្នាំ២០០២ : ថ្ងៃទី០៣-០៥ ខែវិច្ឆិកា កម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំកិច្ចកំពូលមហាអនុតំបន់ទន្លេមេគង្គលើកទី១ និងកិច្ចប្រជុំកំពូលអាស៊ានលើកទី៨ អាស៊ាន + ៣ អាស៊ាន +១។

---

[19] គណបក្សប្រជាជនកម្ពុជា, *ប្រសាសន៍សំខាន់ៗរបស់**សម្តេចតេជោ ហ៊ុន សែន** អញ្ជើញជាអធិបតីសម្ពោធវិមានអនុស្សាវរីយ៍ «នយោបាយឈ្នះ-ឈ្នះ» និងអបអរសាទរខួប២០ឆ្នាំ នៃការបិទបញ្ចប់ភ្លើងសង្គ្រាម*, ២៩ ធ្នូ ២០១៨ អត្ថបទដោយ NOU SEYHA, អាចរកបាននៅ https://www.cpp.org.kh/details/106358 (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២៤)។

[20] ទីស្តីការគណៈរដ្ឋមន្ត្រី, *សៀវភៅសមិទ្ធផលសំខាន់ៗដែលសម្រេចបានដោយរាជរដ្ឋាភិបាលកម្ពុជាសំរាប់នីតិកាលទី២ នៃរដ្ឋសភា (១៩៩៨-២០០៣)*, (បោះពុម្ពផ្សាយដោយ៖ នាយកដ្ឋានសរុបនៃទីស្តីការណៈរដ្ឋមន្ត្រី, ២០២៤), ទំព័រ ១៨០។

## ១.៣. នីតិកាលទី៣ (ឆ្នាំ២០០៣ - ២០០៨)

### ១.៣.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត

រដ្ឋសភា នីតិកាលទី៣ កើតពីការបោះឆ្នោតសកល នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ តាមប្រព័ន្ធសមាមាត្រ មាន ២៤ ខេត្ត ក្រុង ជាមណ្ឌលបោះឆ្នោត (មានខេត្តមួយទើបបង្កើតថ្មី គឺឧត្តរមានជ័យ) ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ២៣។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភា ចំនួន៣៖

១. គណបក្សប្រជាជនកម្ពុជា ៧៣ អាសនៈ

២. គណបក្សហ្វ៊ុនស៊ិនប៉ិច ២៦ អាសនៈ

៣. គណបក្សសមរង្ស៊ី ២៤ អាសនៈ

តំណាងរាស្ត្រសរុបចំនួន ១២៣ រូប ក្នុងនោះស្រីមាន ២៤រូប ស្មើនឹង១៩,៥១%[21]។

នៅក្នុងរាជរដ្ឋាភិបាលនីតិកាលទី៣នេះ លទ្ធផលនៃការបោះឆ្នោតទទួលបានជ័យជម្នះមកលើគណបក្សប្រជាជនកម្ពុជាយ៉ាងច្រើនលើសលប់ នេះបញ្ជាក់ឲ្យឃើញពីលទ្ធផលស្វែងរកសន្តិភាពតាមរយៈនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចតេជោ** នានីតិកាលទី២ ទើបប្រជាជនកម្ពុជាកាន់តែដឹងគុណគណបក្សប្រជាជនកម្ពុជា និងមានសន្ទុះនៃការគាំទ្រកើនឡើងជាខ្លាំងក្នុងនីតិកាលទី៣នេះ។

### ១.៣.២. សមាសភាពគណៈរដ្ឋមន្ត្រី

សមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី៣ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ បន្ទាប់ពីមានភាពជាប់គាំងផ្នែកនយោបាយអស់ជិតមួយឆ្នាំ។

សមាសភាពគណៈរដ្ឋមន្ត្រីនីតិកាលទី ៣ មានដូចខាងក្រោម៖

I. **នាយករដ្ឋមន្ត្រី៖ សម្តេច ហ៊ុន សែន**[22]។

II. **ឧបនាយករដ្ឋមន្ត្រី៖**

- ១.ឯកឧត្តម ស ខេង, ២.ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ, ៣.ឯកឧត្តម សុខ អាន, ៤.ឯកឧត្តម-លឺ ឡាយស្រេង, ៥.ឯកឧត្តម ទៀ បាញ់, ៦.ឯកឧត្តម ហោ ណាំហុង និង ៧.ឯកឧត្តម ញឹក ប៊ុនឆៃ (*ចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦*)។

---

[21] ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា, *សៀវភៅស្តីពីសភាកម្ពុជា*, (ភ្នំពេញ៖ STC (JSRC) Printing House, ២០២១), ៧១។

[22] សម្តេច ហ៊ុន សែន ទទួលគោរម្យងារជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/ ១០០៧/៥០៦។

❖ ១.ឯកឧត្តម ស ខេង, ២.ឯកឧត្តម សុខ អាន, ៣.ឯកឧត្តម លី ឡាយស្រេង, ៤.ឯកឧត្តម-ទៀ បាញ់, ៥.ឯកឧត្តម ហោ ណាំហុង, និង ៦.ឯកឧត្តម ញឹក ប៊ុនឆៃ (*ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨*)។

**III.** **ទេសរដ្ឋមន្ត្រី៖** ១.ឯកឧត្តម គាត ឈន់, ២.ឯកឧត្តម យូ ហុកគ្រី (ទទួលបន្ទុកបេសកកម្មពិសេស), ៣.ឯកឧត្តម អ៊ឹម ឈុនលឹម, ៤.ឯកឧត្តម ហុង ស៊ុនហួត (ទទួលបន្ទុកបេសកកម្មពិសេស), ៥.លោកជំទាវ-ម៉ែន សំអន, ៦.ឯកឧត្តម ឃី តាំងលឹម (ទទួលបន្ទុកបេសកកម្មពិសេស), ៧.ឯកឧត្តម ឆាយ ថន, ៨.ឯកឧត្តម វ៉េង សិរីវុឌ្ឍ (ទទួលបន្ទុកបេសកកម្មពិសេស), ៩.ឯកឧត្តម ចម ប្រសិទ្ធ, ១០.ឯកឧត្តម-ម៉ុក ម៉ារ៉េត, ១១.ឯកឧត្តម យុន ហាំង, ១២.ឯកឧត្តម ញឹម វណ្ណដា (ទទួលបន្ទុកបេសកកម្មពិសេស), ១៣.ឯកឧត្តម កុល ផេង, ១៤.ឯកឧត្តម តាវ សេងហួរ, (ទទួលបន្ទុកបេសកកម្មពិសេស) និង ១៥.ឯកឧត្តម-សេរី កុសល (ទទួលបន្ទុកបេសកកម្មពិសេស)។

**IV.** **រដ្ឋមន្ត្រី និងរដ្ឋលេខាធិការតាមបណ្ដាក្រសួង ស្ថាប័ន៖**

| | | |
|---|---|---|
| ១. | ទីស្ដីការគណៈរដ្ឋមន្ត្រី: ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រី |
| ២. | ក្រសួងមហាផ្ទៃ: ឯកឧត្តម ស ខេង[23] និង ស្ដេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ[24] | សហរដ្ឋមន្ត្រី |
| ៣. | ក្រសួងការពារជាតិ: ឯកឧត្តម ទៀ បាញ់[25] និង ឯកឧត្តម ញឹក ប៊ុនឆៃ[26] | សហរដ្ឋមន្ត្រី |
| ៤. | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ: ឯកឧត្តម ហោ ណាំហុង | រដ្ឋមន្ត្រី |
| ៥. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: ឯកឧត្តម គាត ឈន់ | រដ្ឋមន្ត្រី |
| ៦. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ: ឯកឧត្តម ច័ន្ទ សារុន | រដ្ឋមន្ត្រី |
| ៧. | ក្រសួងអភិវឌ្ឍន៍ជនបទ: ឯកឧត្តម លី ឡាយស្រេង | រដ្ឋមន្ត្រី |
| ៨. | ក្រសួងពាណិជ្ជកម្ម: ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ៩. | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល: ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រី |
| ១០. | ក្រសួងផែនការ: ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រី |
| ១១. | ក្រសួងអប់រំ យុវជន និងកីឡា: ឯកឧត្តម កុល ផេង | រដ្ឋមន្ត្រី |

[23] ឯកឧត្តម ស ខេង ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦។

[24] សម្ដេច នរោត្តម សិរីវុឌ្ឍ ត្រូវបានបញ្ចប់តំណែងពីឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦។

[25] ឯកឧត្តម ទៀ បាញ់ ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦។

[26] ឯកឧត្តម ញឹក ប៊ុនឆៃ ត្រូវបានបញ្ចប់តំណែងពី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយរក្សាតំណែងជាឧបនាយករដ្ឋមន្ត្រីដដែល នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦។

១២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា: ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី

១៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់: ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រី

១៤. ក្រសួងបរិស្ថាន: ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រី

១៥. ក្រសួងធនធានទឹក និងឧតុនិយម: ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រី

១៦. ក្រសួងព័ត៌មាន: ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រី

១៧. ក្រសួងយុត្តិធម៌: ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រី

១៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច: លោកជំទាវ ម៉ែន សំអន រដ្ឋមន្ត្រី

១៩. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍: ឯកឧត្តម សូរ យុន រដ្ឋមន្ត្រី

២០. ក្រសួងសុខាភិបាល: ឯកឧត្តម នុត សុខុម រដ្ឋមន្ត្រី

២១. ក្រសួងសាធារណការ និងដឹកជញ្ជូន: ឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រី

២២. ក្រសួងវប្បធម៌ និងវិចត្រសិល្បៈ: អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា សិរីវុឌ្ឍ រដ្ឋមន្ត្រី

២៣. ក្រសួងទេសចរណ៍: ឯកឧត្តម ឡាយ ព្រហស្ស រដ្ឋមន្ត្រី

២៤. ក្រសួងធម្មការ និងសាសនា: ឯកឧត្តម យុន ហាំង រដ្ឋមន្ត្រី

២៥. ក្រសួងកិច្ចការនារី: លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី

២៦. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ: ឯកឧត្តម ញ៉េប ប៊ុនជិន រដ្ឋមន្ត្រី

❖ រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី:

១. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ: ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋលេខាធិការ

២. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល: ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ[27]។

### ១.៣.៣. សមិទ្ធផលសំខាន់ៗ

សមិទ្ធផលសំខាន់ៗ របស់រាជរដ្ឋាភិបាល នីតិកាលទី ៣ មានដូចខាងក្រោម៖

- រាជរដ្ឋាភិបាលរក្សា និងការពារបានយ៉ាងរឹងមាំនូវឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។
- បង្ក្រាបបទល្មើសគ្រឿងញៀន បានចំនួន ១.០៧៨ ករណី។

[27] យល់ដឹងពីកម្ពុជា, *សមាសភាពគណៈរដ្ឋមន្ត្រីនីតិកាលទី៣ នៃរដ្ឋសភា*, ១៨ មករា ២០១៩, អាចរកបាននៅ https://www.facebook.com/photo/?fbid=1353425078132142&set=pcb.1353425388132111&locale=th_TH (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤)។

- នយោបាយការបរទេសកម្ពុជា ទទួលបានសមិទ្ធផលធំៗយ៉ាងច្រើន កេរ្តិ៍ឈ្មោះកម្ពុជាកាន់តែត្រូវបានលើកកម្ពស់លើឆាកអន្តរជាតិ។
- រយៈពេលឆ្នាំ ២០០៤-២០០៧ ចំណូលថវិកាជាតិបានកើនឡើងជាមធ្យមប្រមាណ ២៣.៤ ភាគរយ ក្នុងមួយឆ្នាំៗ[28]។
- បានធ្វើការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានមន្ត្រីរាជការស៊ីវិលពី ៣០០ រៀល នៅឆ្នាំ ២០០៤ ទៅ ៦០០ រៀល នៅឆ្នាំ២០០៧ ក្នុងមួយសន្ទស្សន៍ និងបានបង្កើនប្រាប់បៀវត្សមធ្យមពី ៣០.០០ ដុល្លារ នៅឆ្នាំ ២០០៤ មកដល់ ៥៣.៧ ដុល្លារ នៅឆ្នាំ ២០០៧។
- គិតត្រឹមដំណាច់ឆ្នាំ ២០០៧ បានប្រមូលមកវិញនូវផ្ទៃដីព្រៃឈើគ្រប់ប្រភេទ ដែលកាន់កាប់ខុសច្បាប់មកទុកជាសម្បត្តិរដ្ឋចំនួន ២៤៣,១៨១ ហិកតា[29]។

## **១.៤. នីតិកាលទី៤** ( **ឆ្នាំ២០០៨ - ២០១៣** )

### **១.៤.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត**

ការបោះឆ្នោតជាសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ នៃរដ្ឋសភាបានប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៨។ ដែលមានគណបក្សចូលរួមឈរឈ្មោះបោះឆ្នោតចំនួន ១១គណបក្ស ដែលក្នុងនោះរួមមាន ១)គណបក្សប្រជាជនកម្ពុជា ២)គណបក្សសមរង្ស៊ី ៣)គណបក្សសិទ្ធិមនុស្ស ៤)គណបក្សនរោត្តមរណឫទ្ធិ ៥)គណបក្សហ្វ៊ុនស៊ិនប៉ិច ៦)គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ៧)គណបក្សប្រជាធិបតេយ្យខ្មែរ ៨)គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ ៩)គណបក្សសង្គមយុត្តិធម៌ ១០)គណបក្សខ្មែរសាធារណរដ្ឋ និង១១)គណបក្សខ្មែរឈប់ក្រ។ ក្នុងនោះដែរ គណបក្សប្រជាជនកម្ពុជាដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ទទួលបានសម្លេងគាំទ្រពីសំណាក់ប្រជាជនខ្មែរយ៉ាងច្រើនជាច់គេគួរឱ្យកត់សម្គាល់។

ខាងក្រោមនេះជាសម្លេងឆ្នោតសរុបរបស់គណបក្សនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងនីតិកាលទី៤៖

| | **សម្លេងឆ្នោតបានការសរុប** | **ភាគរយ** |
|---|---|---|
| ១. គណបក្សប្រជាជនកម្ពុជា | ៣,៤៩២,៣៧៤ | ៥៨.១១% |
| ២. គណបក្សសម រង្ស៊ី | ១,៣១៦,៧១៤ | ២១.៩១% |

[28] ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍ស្តីពី សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល៤ឆ្នាំ (២០០៤-២០០៧)*, (ចងក្រង និងរៀបចំបោះពុម្ពផ្សាយដោយនាយកដ្ឋានសរុប៖ ខែឧសភា ឆ្នាំ២០០៨), ទំព័រ ៥៤។

[29] ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍ស្តីពី សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល៤ឆ្នាំ (២០០៤-២០០៧)*, (ចងក្រង និងរៀបចំបោះពុម្ពផ្សាយដោយនាយកដ្ឋានសរុប៖ ខែឧសភា ឆ្នាំ២០០៨), ទំព័រ ៨៥។

| | | |
|---|---|---|
| ៣. គណបក្សសិទ្ធិមនុស្ស | ៣៩៧,៨១៦ | ៦.៦២% |
| ៤. គណបក្សនរោត្តមរណឫទ្ធិ | ៣៣៧,៩៤៣ | ៥.៦២% |
| ៥. គណបក្សហ៊្វុនស៊ិនប៉ិច | ៣០៣,៧៦៤ | ៥.០៥% |
| ៦. គណបក្សសម្ព័ន្ធដើម្បីប្រជាធិតេយ្យ | ៦៨,៩០៩ | ១.១៥% |
| ៧. គណបក្សប្រជាធិបតេយ្យខ្មែរ | ៣២,៣៨៦ | ០.៥៤% |
| ៨. គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ | ២៥,០៦៥ | ០.៤២% |
| ៩. គណបក្សសង្គមយុត្តិធម៌ | ១៤,១១២ | ០.២៣% |
| ១០. គណបក្សខ្មែរសាធារណរដ្ឋ | ១១,៦៩៣ | ០.១៩% |
| ១១. គណបក្សខ្មែរឈប់ក្រ | ៩,៥០១ | ០.១៦%[30]។ |

គណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាចំនួន ៤៖

១. គណបក្សប្រជាជនកម្ពុជា ៩០ អាសនៈ

២. គណបក្សសមរង្ស៊ី ២៦ អាសនៈ

៣. គណបក្សសិទ្ធិមនុស្ស ២ អាសនៈ

៤. គណបក្សនរោត្តមរណឫទ្ធិ ២ អាសនៈ។

តំណាងរាស្ត្រសរុបចំនួន ១២៣ រូប ក្នុងនោះស្ត្រីមាន២៦រូប ស្មើនឹង២១,១៣%[31]។

### ១.៤.២. សមាសភាពគណៈរដ្ឋមន្ត្រី

សមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី ៤ មានដូចជា៖

I. នាយករដ្ឋមន្ត្រី: **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

II. **ឧបនាយករដ្ឋមន្ត្រី**: ១. ឯកឧត្តម ស ខេង, ២. ឯកឧត្តម សុខ អាន, ៣. ឯកឧត្តម ទៀ បាញ់, ៤. ឯកឧត្តម-ហោ ណាំហុង, ៥. លោកជំទាវ ម៉ែន សំអន, ៦. ឯកឧត្តម ប៊ិន ឈិន, ៧. ឯកឧត្តម ញឹក ប៊ុនឆៃ, ៨. ឯកឧត្តម គាត ឈន់ និង ៩. ឯកឧត្តម យឹម ឆៃលី។

III. **ទេសរដ្ឋមន្ត្រី**: ១.ឯកឧត្តម អ៊ឹម ឈុនលឹម, ២. ឯកឧត្តម ឆាយ ថន, ៣. ឯកឧត្តម ចម ប្រសិទ្ធ, ៤. ឯកឧត្តម ម៉ុក ម៉ារ៉េត, ៥. ឯកឧត្តម ញឹម វណ្ណដា (ទទួលបន្ទុកបេសកកម្មពិសេស), ៦. ឯកឧត្តម-

[30] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ប្រ.ក/លេខ ០៩.១៦២/០៨ គ.ជ.ប.អគ្គ.ពស, ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី *សម្លេងឆ្នោតសរុបដែលគណបក្សនយោបាយនីមួយៗទទួលបាននៅទូទាំងប្រទេស សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៤ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨*។ អាចរកបាននៅ https://www.nec.gov.kh/khmer/content/4137 ។

[31] ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា, *សៀវភៅស្តីពីសភាកម្ពុជា*, (ភ្នំពេញ៖ STC (JSRC) Printing House, ២០២១), ៧៧។

តាវ សេងហ៊ួរ (ទទួលបន្ទុកបេសកកម្មពិសេស), ៧. ឯកឧត្តម យុន ហាំង (ទទួលបន្ទុកបេសកកម្មពិសេស), ៨. ឯកឧត្តម លី ធុជ (ទទួលបន្ទុកបេសកកម្មពិសេស), ៩. ឯកឧត្តម កុល ផេង (ទទួលបន្ទុកបេសកកម្មពិសេស), ១០. ឯកឧត្តម ស៊ុន ចាន់ថុល (ទទួលបន្ទុកបេសកកម្មពិសេស), ១១. ឯកឧត្តម-វេង សិរីវុឌ្ឍ (ទទួលបន្ទុកបេសកកម្មពិសេស), ១២. ឯកឧត្តម នុត សុខុម (ទទួលបន្ទុកបេសកកម្មពិសេស), ១៣. ឯកឧត្តម ឱម យ៉ិនទៀង (ទទួលបន្ទុកបេសកកម្មពិសេស), ១៤. ឯកឧត្តម អៀង ម៉ូលី (ទទួលបន្ទុកបេសកកម្មពិសេស), ១៥. ឯកឧត្តម វ៉ា គីមហុង (ទទួលបន្ទុកបេសកកម្មពិសេស) និង ១៦. ឯកឧត្តម យឹម ណុលឡា (ទទួលបន្ទុកបេសកកម្មពិសេស)។

**IV. រដ្ឋមន្ត្រី និង រដ្ឋលេខាធិការតាមបណ្តាក្រសួង ស្ថាប័ន**

| | |
|---|---|
| ១. ទីស្តីការគណៈរដ្ឋមន្ត្រី: ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រី |
| ២. ក្រសួងមហាផ្ទៃ: ឯកឧត្តម ស ខេង | រដ្ឋមន្ត្រី |
| ៣. ក្រសួងការពារជាតិ: ឯកឧត្តម ទៀ បាញ់ | រដ្ឋមន្ត្រី |
| ៤. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ: ឯកឧត្តម ហោ ណាំហុង | រដ្ឋមន្ត្រី |
| ៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: ឯកឧត្តម គាត ឈន់ | រដ្ឋមន្ត្រី |
| ៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ: ឯកឧត្តម ច័ន្ទ សារុន | រដ្ឋមន្ត្រី |
| ៧. ក្រសួងអភិវឌ្ឍន៍ជនបទ: ឯកឧត្តម ជា សុផារ៉ា | រដ្ឋមន្ត្រី |
| ៨. ក្រសួងពាណិជ្ជកម្ម: ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ៩. ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល: ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រី |
| ១០. ក្រសួងផែនការ: ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រី |
| ១១. ក្រសួងអប់រំ យុវជន និងកីឡា: ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋមន្ត្រី |
| ១២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា: ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រី |
| ១៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់: ឯកឧត្តម អ៊ឹម ឈុនលឹម | រដ្ឋមន្ត្រី |
| ១៤. ក្រសួងបរិស្ថាន: ឯកឧត្តម ម៉ុក ម៉ារ៉េត | រដ្ឋមន្ត្រី |
| ១៥. ក្រសួងធនធានទឹក និងឧតុនិយម: ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រី |
| ១៦. ក្រសួងព័ត៌មាន: ឯកឧត្តម ខៀវ កាញារីទ្ធ | រដ្ឋមន្ត្រី |
| ១៧. ក្រសួងយុត្តិធម៌: ឯកឧត្តម អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រី |
| ១៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច: លោកជំទាវ សោម គឹមសួគ៌ | |

| | |
|---|---|
| | រដ្ឋមន្ត្រី |
| ១៩. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍: ឯកឧត្តម សូរ យុន | រដ្ឋមន្ត្រី |
| ២០. ក្រសួងសុខាភិបាល: ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋមន្ត្រី |
| ២១. ក្រសួងសាធារណៈការ និងដឹកជញ្ជូន: ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋមន្ត្រី |
| ២២. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ: ឯកឧត្តម ហ៊ឹម ឆែម | រដ្ឋមន្ត្រី |
| ២៣. ក្រសួងទេសចរណ៍: ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រី |
| ២៤. ក្រសួងធម្មការ និងសាសនា: ឯកឧត្តម មិន ឃិន | រដ្ឋមន្ត្រី |
| ២៥. ក្រសួងកិច្ចការនារី: លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រី |
| ២៦. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ: ឯកឧត្តម វង សូត | រដ្ឋមន្ត្រី |

❖ រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី:

| | |
|---|---|
| ១. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ: ឯកឧត្តម ពេជ្រ ប៊ុនធិន | រដ្ឋលេខាធិការ |
| ២. រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល: ឯកឧត្តម ម៉ៅ ហាវណ្ណាល់ | រដ្ឋលេខាធិការ[32]។ |

### ១.៤.៣. សមិទ្ធផលសំខាន់ៗ

សមិទ្ធផលសំខាន់ៗ របស់រាជរដ្ឋាភិបាល នីតិកាលទី ៤ រួមមានដូចខាងក្រោម៖

I. **អភិបាលកិច្ចល្អ៖** ១. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (បានអនុវត្តនូវច្បាប់ថ្មីមួយ ស្តីពីការប្រឆាំងអំពើពុករលួយ, ការប្រកាសទ្រព្យសម្បត្តិ និងបំណុល)។ ២. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ២០១០ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ និងច្បាប់ជាច្រើនទៀត)[33]។ ៣. កំណែទម្រង់រដ្ឋបាលសាធារណៈ (ដំឡើងប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ ២០%ក្នុងមួយឆ្នាំ, មូលនិធិឃុំ សង្កាត់ជាមធ្យមពី ៩,០០០-១០,០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា)។

II. **ការលើកស្ទួយវិស័យកសិកម្ម៖** ១. ផលិតកម្មដំណាំស្រូវ (មានការកើនឡើងពី ៧,១៧៥-៩,៣០៥ លានតោន), ២. កំណែទម្រង់ជលផល, ៣. កំណែទម្រង់ព្រៃឈើ ការគ្រប់គ្រងបរិស្ថាន ការងារគ្រប់គ្រង

---

[32] គេហទំព័រ Royal Academy of Cambodia, Institute of Humanities and Social Sciences, ដោយ បណ្ឌិត ហែម ឡាច (ថ្ងៃទី១៩ មីនា ២០២០)។ អាចរកបាននៅ https://ihss.rac.gov.kh/2020/03/19 (ចូលទស្សនាថ្ងៃទី២០ មិថុនា ឆ្នាំ២០២៤) ។

[33] ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០០៨-២០១២, ខែឧសភា ឆ្នាំ២០១៣*, ទំព័រទី២, ៤, ១៤, ១៩, ២៦។

គ្រោះមហន្តរាយ, ៤. កំណែទម្រង់ដីធ្លី (ការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ចៈ អនុវត្តបាន១៣០បណ្ណ ស្មើនឹង ១០១,១៧៩ ហិកតា) និងការបោសសម្អាតមីន (សម្រេចបានផ្ទៃដីសរុបប្រមាណជាង ៥៣១ គ.ម.២)។

III. **ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ** ១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ប្រវែងផ្លូវក្រាលកៅស៊ូ ៤,៩៦៩គ.ម ការស្តារផ្លូវលំជនបទក្រាលក្រួសក្រហមប្រវែង ៦៦៨,០៦៨ ក្រាលបេតុង ៤,៨០០គ.ម ផ្លូវលំជនបទក្រាលកៅស៊ូ DBST ២៩,៤២៥គ.ម) ស្ពាន និងផ្លូវដែកដែលបានស្តាបនា (ស្ពានអ្នកលឿង ស្ពានមិត្តភាពកម្ពុជា-ចិន) ការដឹកជញ្ជូននៅកំពុងផែស្វយ័តក្រុងព្រះសីហនុ ការដឹកជញ្ជូននៅកំពងផែស្វយ័តភ្នំពេញ ការដឹកជញ្ជូនតាមផ្លូវអាកាស។ ២. ការអភិវឌ្ឍវិស័យថាមពល ការងារសាងសង់វារីអគ្គិសនី ការសាងសង់រោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម។ ៣. ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ (ស្ថានីយទូរទស្សន៍កើនពី ១៨-២១៣, ស្ថានីយវិទ្យុកើនពី ៦៩-១៣៩, សារព័ត៌មានបោះពុម្ពកើនពី ៦៦៩-៧២១)។

IV. **ការអភិវឌ្ឍវិស័យឯកជន និងការងារៈ** ១. ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ (លំហូរទុនវិនិយោគផ្ទាល់ពីបរទេសមានចំនួន ៣,៥១៨ លានដុល្លារអាមេរិក), ២. ឧស្សាហកម្ម និង សិប្បកម្ម (រោងចក្រដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានចំនួនសរុប៩០៧), ៣. ការបង្កើតការងារ និង ការធានាលក្ខខណ្ឌការងារល្អប្រសើរ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរកការងារឱ្យប្រជាពលរដ្ឋធ្វើចំនួន ២០៥,០៦៨នាក់)។

V. **ការកសាងសមត្ថភាព និងធនធានមនុស្សៈ** ១. ការពង្រឹងគុណភាពវិស័យអប់រំ (សាលាមត្តេយ្យមានចំនួន ២,៨១៣, បឋមសិក្សា ៦,៩១០, មធ្យមសិក្សា ១,៦៤៧ ក្នុងនោះវិទ្យាល័យចំនួន ៤៣៣, ឧត្តមសិក្សា ១០១ ក្នុងនោះគ្រឹះស្ថានឯកជន ៦២)។ ២. ការលើកម្ពស់វិស័យសុខាភិបាល ៣. កិច្ចការពារសាសនា (ព្រះពុទ្ធសាសនា អ៊ីស្លាមសាសនា និងគ្រិស្តសាសនា) ៤. ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធអំណាចដល់ស្ត្រី (សមាមាត្រភាពស្ត្រីជាមន្ត្រីរាជការបានកើនដល់៣៤%, ក្នុងចំណោមអ្នកធ្វើការក្នុងសហគ្រាសសរុបចំនួន ១,៦លាននាក់ មានស្ត្រី ១លាននាក់ គឺស្មើនឹង៦១%[34]។

[34] ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០០៨-២០១២, ខែឧសភា ឆ្នាំ២០១៣*, ទំព័រទី២៦, ២៧, ៣០, ៣១, ៣២។

## ១.៥. នីតិកាលទី៥ (ឆ្នាំ២០១៣ - ២០១៨)

### ១.៥.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត

ការបោះឆ្នោតជាសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភាបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ចាប់ពីម៉ោង៧:០០ ដល់ម៉ោង១៥:០០ រសៀល នៅការិយាល័យបោះឆ្នោតចំនួន ១៩,០០៩ នៅទូទាំងប្រទេស។ បើតាមសៀវភៅសស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ ដែលបានផ្សព្វផ្សាយដោយ គ.ជ.ប កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៣ បង្ហាញថាប្រជាជនដែលចេញទៅបោះឆ្នោតមានអត្រា ៦៩,៦១% ស្មើនឹង ៦,៧៣៥,២៤៤នាក់ ក្នុងចំណោម អ្នកចុះឈ្មោះបោះឆ្នោតចំនួន ៩,៦៧៥,៤៥៣នាក់[35]។ បើតាមវិទ្យាស្ថានដើម្បីប្រជាធិបតេយ្យ និងជំនួយដល់ការ បោះឆ្នោត (The Institute For Democracy And Electoral Assistant) អត្រានេះមានកម្រិតខ្ពស់បើធៀប នឹងប្រទេសមួយចំនួន។

បរិយាកាសនៃការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសុវត្ថិភាព។ ជោគជ័យនៃការ បោះឆ្នោតនេះ ឆ្លុះបញ្ចាំងនូវការអនុវត្តលទ្ធិប្រជាធិតេយ្យក្នុងប្រទេសកម្ពុជា។ ប្រជាជនមានសិទ្ធិពេញលេញក្នុង ការសម្តែងចេញនូវឆន្ទៈរបស់ខ្លួនដោយសេរី នៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត។ ប្រជាពលរដ្ឋបាន ចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោតដើម្បីសម្តែងនូវការគាំទ្រគណបក្សនយោបាយដែលខ្លួនពេញចិត្ត ដោយពុំមានការភ័យខ្លាច។ សកម្មជននៃគណបក្សនយោបាយនីមួយៗ បានធ្វើសកម្មភាពរបស់ខ្លួនដោយសេរី និងពុំមានការគាបសង្កត់ និងការគំរាមកំហែងពីមជ្ឈដ្ឋានណាមួយឡើយ។ ក្នុងដំណើរការបោះឆ្នោតពុំមាន អំពើហិង្សាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ការបោះឆ្នោត ហើយក៏ពុំមានឃើញរបាយកាណ៍ណាមួយអំពីការរំលោភ បំពាន ឬការធ្វើឃាតខាងនយោបាយដល់សមាជិកគណបក្សនយោបាយណាមួយនោះទេ។ ការបោះឆ្នោតបាន ប្រព្រឹត្តទៅក្រោមការឃ្លាំមើលរបស់អ្នកសង្កេតការណ៍អន្តជាតិចំនួន ២៩២នាក់ និងអ្នកសង្កេតការណ៍ជាតិចំនួន ៤០,១៤២នាក់ រួមមានអ្នកសង្កេតការណ៍របស់អង្គការ COMFREL ដែលមានវត្តមាននៅគ្រប់ការិយាល័យ បោះឆ្នោត ដោយបានសង្កេតឃើញជាទូទៅថា ការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ តម្លាភាព គ្មានការគំរាមកំហែង គ្មានអំពើហិង្សា និងអាចទទួលយកបាន។

បើទោះជាយ៉ាងនេះក៏ដោយ គណបក្សប្រឆាំងបានបំពុលបរិយាកាសនៃដំណើរការបោះឆ្នោតនេះជាអាទិ៍ ការឈរជាក្រុមនៅពីមុខការិយាល័យបោះឆ្នោតអុកឡុក និងរំខានអ្នកបោះឆ្នោតដែលមានសម្បុរជ្រះដោយ រើសអើងថាជាយួន និងបញ្ចុះបញ្ចូលប្រជាពលរដ្ឋឱ្យបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិជាដើម។ គណបក្ស

[35] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឆ្នាំ២០១៣, អាចទៅរកបាននៅ https://www.nec.gov.kh/khmer/content/4445 ។

ប្រឆាំងបានប្រព្រឹត្តទង្វើដែលផ្ទុយនឹងច្បាប់បែបនេះ ដើម្បីជាលេសចោទប្រកាន់ គ.ជ.ប សម្រាប់បម្រើគោលដៅចុងក្រោយនៅពេលចាញ់ឆ្នោត[36]។

គណបក្សនយោបាយចូលរួមឈរឈ្មោះបោះឆ្នោតជាបេក្ខជនបោះឆ្នោតចំនួន ៨។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភាចំនួន ២៖

១. គណបក្សប្រជាជនកម្ពុជា ៦៨ អាសនៈ

២. គណបក្សសង្គ្រោះជាតិ ៥៥ អាសនៈ។

តំណាងរាស្ត្រសរុបចំនួន ១២៣ រូប ក្នុងនោះស្ត្រីចំនួន ២៥ រូប ស្មើនឹង ២០,១៣%[37]។

❖ **ការបដិសេធលទ្ធផលបោះឆ្នោតរបស់លោក សម រង្ស៊ី**

មុនការបោះឆ្នោតមួយថ្ងៃ ក្នុងសវនាការជាមួយអ្នកសង្កេតការណ៍អន្តរជាតិនៅស្នាក់ការបក្សរបស់ខ្លួន លោក សម រង្ស៊ី និងលោក កឹម សុខា បានប្រកាសមិនទទួលស្គាល់ គ.ជ.ប ហើយនឹងបដិសេធលទ្ធផលនៃការបោះឆ្នោត ហើយលោក សម រង្ស៊ី បានបញ្ជាក់ថាគណបក្សសង្គ្រោះជាតិអាចនឹងឈ្នះ។ នៅក្នុងសវនាការនោះ ឥស្សរជនជាន់ខ្ពស់ជាអ្នកសង្កេតការណ៍អន្តជាតិមួយរូបបានសួរលោក កឹម សុខាថា "បើមិនទទួលស្គាល់ គ.ជ.ប និងមិនទទួលស្គាល់លទ្ធផលបោះឆ្នោត តើគណបក្សរបស់លោកចូលរួមបោះឆ្នោតធ្វើអ្វី? ហើយបើគណបក្សរបស់លោកឈ្នះវិញ តើលោកនៅតែបដិសេធលទ្ធផលនៃការបោះឆ្នោតដែរឬទេ?" លោកសម រង្ស៊ី និងលោក កឹម សុខា បែជាមិនឆ្លើយតប ហើយបង្វែរការពិភាក្សាលើប្រធានបទផ្សេងវិញ។ ឥរិយាបថបែបនេះនាំឱ្យគេយល់ថា «គណបក្សសង្គ្រោះជាតិ នឹងទទួលយកលទ្ធផលប្រសិនបើខ្លួនឈ្នះ ហើយនឹងមានការបដិសេធប្រសិនបើខ្លួនចាញ់ ដែលនេះមិនបានបង្ហាញពីគោលជំហររបស់អ្នកដែលមានលទ្ធភាពធ្វើជាមេដឹកនាំនោះទេ»។

មួយថ្ងៃបន្ទាប់ពីការបោះឆ្នោត និងបន្ទាប់ពីលទ្ធផលបណ្ដោះអាសន្នក្រៅផ្លូវការត្រូវបានប្រកាសគណបក្សសង្គ្រោះជាតិបានបដិសេធមិនទទួលយកលទ្ធផល និងទាមទារឱ្យបង្កើតគណៈកម្មការចម្រុះស៊ើបអង្កេតភាពមិនប្រក្រតី[38]។ ក្នុងស្មារតីបង្រួបបង្រួមជាតិ និងជំហរទន់ភ្លន់ គណបក្សប្រជាជនកម្ពុជាបានបញ្ជូនតំណាងរបស់ខ្លួនចូលរួមជាអ្នកសង្កេតការណ៍ក្នុងដំណើរស៊ើបអង្កេតនេះ បើទោះបីជាការទាមទាររបស់គណបក្សសង្គ្រោះជាតិជាសំណើដែលរំលោភច្បាប់ និងគោលការណ៍នីតិរដ្ឋក៏ដោយ នេះបានបង្ហាញយ៉ាងច្បាស់ថា បក្សប្រជាជនកម្ពុជាតែងតែប្រកាន់ខ្ជាប់ជានិច្ចនូវស្មារតីបង្រួបបង្រួមជាតិគ្រប់កាលៈទេសៈ។ ក្រុមប្រឹក្សាធម្មនុញ្ញមានចំណាត់ការ

[36] ទីស្ដីការគណៈរដ្ឋមន្ត្រី អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស, *សៀវភៅស ស្ដីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣*, រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣, ទំព័រទី៣។

[37] ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា, *សៀវភៅស្ដីពីសភាកម្ពុជា*, (ភ្នំពេញ៖ STC (JSRC) Printing House, ២០២១), ៨៤។

[38] គេហទំព័រ RFI, ចេញផ្សាយថ្ងៃទី២៩ កក្កដា ២០១៣, អាចរកបាននៅ https://www.rfi.fr/km/cambodia/20130729-cambodia-opposition-reject ។

តាមនីតិវិធី ហើយរកឃើញថាលទ្ធផលនៃការបោះឆ្នោតមិនមានការប្រែប្រួលទេ។ អ្នកសង្កេតការណ៍ទាំងជាតិ និងអន្តរជាតិបានសាទរ និងវាយតម្លៃខ្ពស់ថា ការបោះឆ្នោតពិតជាបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលប្រសូត្រចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋពិតប្រាកដមែន។

❖ **ការបើកកិច្ចប្រជុំលើកដំបូងរបស់រដ្ឋសភា**

បន្ទាប់ពីសម័យប្រជុំដំបូង រដ្ឋសភាអាចបើកសម័យប្រជុំលើកទី១របស់ខ្លួនក្រោមអធិបតីភាពប្រធានបណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតដែលមានអាយុច្រើនជាងគេ ហើយមានសមាជិកប្រាំរូបជាបេក្ខជនជាប់ឆ្នោតមានអាយុតិចជាងគេ ដែលមានវត្តមានក្នុងកិច្ចប្រជុំជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ។ ក្នុងករណីធម្មតា បើមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូលក៏ដោយ សម័យប្រជុំលើកទី១ នេះអាចអនុម័តសុពលភាពនៃអាណត្តិរបស់សមាជិករដ្ឋសភានីមួយៗ បោះឆ្នោតជ្រើសរើសប្រធាន និងអនុ-ប្រធានរដ្ឋសភា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការជំនាញរបស់សមាជិករដ្ឋសភាទាំងអស់ ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូលដូចមានចែងក្នុងមាត្រា៨២ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី២ និងទី៣ និងប្រការ៥ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ មានកិច្ចពិភាក្សាតុមូលបកស្រាយអំពី សម័យប្រជុំលើកដំបូងនៃរដ្ឋសភា ដោយមានការចូលរួមពីសាស្ត្រាចារ្យ និងឥស្សរជនដែលមានចំណេះដឹង និងបទពិសោធន៍អំពីនីតិរដ្ឋធម្មនុញ្ញ គឺឯកឧត្តម ប៉ែន បញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ឯកឧត្តម ឈឹម ផលវរុណ ប្រធានវិទ្យាស្ថានពលរដ្ឋវិទ្យា ឯកឧត្តម ប៊ុន ហ៊ុន ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ឡាំ ជា សាស្ត្រាចារ្យច្បាប់។ កិច្ចពិភាក្សានេះបានបង្ហាញឱ្យឃើញថា សម័យប្រជុំដំបូងក្រោមរាជាធិបតីភាពរបស់ព្រះមហាក្សត្រ អាចប្រព្រឹត្តទៅបានដោយមិនចាំបាច់មានកូរ៉ុមនោះទេ ហើយរដ្ឋសភាអាចបើកសម័យប្រជុំលើកទី១ និងសម័យប្រជុំពេញអង្គរបស់ខ្លួនបន្តបន្ទាប់ទៀត ដោយតម្រូវឱ្យមានកូរ៉ុម ដូចមានចែងក្នុងមាត្រា៨៨ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ។

ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ សមាជិករដ្ឋសភាទាំង៦៨រូបនៃគណបក្សប្រជាជនកម្ពុជា ចូលរួមសម័យប្រជុំដំបូងក្រោមព្រះរាជាធិបតីនៃព្រះមហាក្សត្រ។ បន្ទាប់មក រដ្ឋសភាអាចបើកសម័យប្រជុំលើកទី១ និងសម័យប្រជុំបន្តបន្ទាប់ហើយអាចធ្វើការអនុម័តលើបញ្ហាទាំងឡាយណាដែលទាមទារសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ដោយគោរពតាមកូរ៉ុមដូចមានកំណត់ក្នុងមាត្រា៨៨ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ ដែលរួមមានការបង្កើតរដ្ឋាភិបាលផងដែរ។[39]

[39] ទីស្តីការគណៈរដ្ឋមន្ត្រី អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស, *សៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣*, រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣, ទំព័រទី២៤។

### ១.៥.២. សមាសភាពគណៈរដ្ឋមន្ត្រី

សមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី៥ មានដូចជា៖

I. **នាយករដ្ឋមន្ត្រី: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។**

II. **ឧបនាយករដ្ឋមន្ត្រី**: ១. ឯកឧត្តម ស ខេង ២. ឯកឧត្តម សុខ អាន ៣. ឯកឧត្តម ទៀ បាញ់ ៤. ឯកឧត្តម-គាត ឈន់ ៥. ឯកឧត្តម ហោ ណាំហុង ៦. លោកជំទាវ ម៉ែន សំអន ៧. ឯកឧត្តម ប៊ិន ឈិន ៨. ឯកឧត្តម-យឹម ឆៃលី និង ៩. ឯកឧត្តម កែ គឹមយ៉ាន។

III. **ទេសរដ្ឋមន្ត្រី**: ១. ឯកឧត្តម អ៊ឹម ឈុនលឹម ២. ឯកឧត្តម ឆាយ ថន ៣. ឯកឧត្តម ចម ប្រសិទ្ធ ៤. ឯកឧត្តម-ញឹម វណ្ណដា (ទទួលបន្ទុកបេសកកម្មពិសេស) ៥. ឯកឧត្តម យុន ហាំង (ទទួលបន្ទុកបេសកកម្មពិសេស) ៦. ឯកឧត្តម លី ធុជ (ទទួលបន្ទុកបេសកកម្មពិសេស) ៧. ឯកឧត្តម ច័ន្ទ សារុន (ទទួលបន្ទុកបេសកកម្មពិសេស) ៨. ឯកឧត្តម ស៊ុន ចាន់ថុល ៩. ឯកឧត្តម ឱម យ៉ិនទៀង (ទទួលបន្ទុកបេសកកម្មពិសេស) ១០. ឯកឧត្តម អៀង ម៉ូលី (ទទួលបន្ទុកបេសកកម្មពិសេស) ១១. ឯកឧត្តម វ៉ា គឹមហុង (ទទួលបន្ទុកបេសកកម្មពិសេស) ១២. ឯកឧត្តម យឹម ណុលឡា (ទទួលបន្ទុកបេសកកម្មពិសេស) ១៣. ឯកឧត្តម-សេរី កុសល (ទទួលបន្ទុកបេសកកម្មពិសេស) ១៤. ឯកឧត្តម ហ៊ឹម ឆែម (ទទួលបន្ទុកបេសកកម្មពិសេស) និង ១៥. ឯកឧត្តម ជិន ប៊ុនសៀន (ទទួលបន្ទុកបេសកកម្មពិសេស)។

IV. **រដ្ឋមន្ត្រី និង រដ្ឋលេខាធិការតាមបណ្តាក្រសួង ស្ថាប័ន**

| | | |
|---|---|---|
| ១. | ឯកឧត្តម សុខ អាន និង ឯកឧត្តម ប៊ិន ឈិន | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី |
| ២. | ឯកឧត្តម ស ខេង | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| ៣. | ឯកឧត្តម ទៀ បាញ់ | រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ៤. | ឯកឧត្តម ហោ ណាំហុង និង ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិ-ការអន្តជាតិ |
| ៥. | ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦. | ឯកឧត្តម អ៊ុក រ៉ាប៊ុន និង ឯកឧត្តម វេង សាខុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| ៧. | ឯកឧត្តម ជា សុផារ៉ា និង ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋមន្ត្រីក្រសួងក្រសួងអភិវឌ្ឍន៍ជនបទ |
| ៨. | ឯកឧត្តម ស៊ុន ចាន់ថុល និងឯកឧត្តម ប៉ាន សូរស័ក្តិ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |
| ៩. | ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល[40] |

[40] ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧, ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣, ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី ការបង្កើតក្រសួងរ៉ែ និងថាមពល។

| | |
|---|---|
| ១០. ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រីក្រសួងផែនការ |
| ១១. ឯកឧត្តម ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា |
| ១២. ឯកឧត្តម វង សូត | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា |
| ១៣. ឯកឧត្តម អ៊ឹម ឈុនលឹម និង ឯកឧត្តម ជា សុផារ៉ា | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| ១៤. ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងបរិស្ថាន |
| ១៥. ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម |
| ១៦. ឯកឧត្តម ខៀវ កាញារីទ្ធ | រដ្ឋមន្ត្រីក្រសួងព័ត៌មាន |
| ១៧. ឯកឧត្តម អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ១៨. លោកជំទាវ ម៉ែន សំអន | រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធ-សភា និងអធិការកិច្ច |
| ១៩. ឯកឧត្តម ប្រាក់ សុខុន និង ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២០. ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២១. ឯកឧត្តម ត្រាំ អ៊ីវតឹក និង ឯកឧត្តម ស៊ុន ចាន់ថុល | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២២. លោកជំទាវ ភឿង សកុណា | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ២៣. ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ២៤. ឯកឧត្តម មិន ឃិន និងឯកឧត្តម ហ៊ឹម ឆែម | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា |
| ២៥. លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ២៦. ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២៧. ឯកឧត្តម ពេជ្រ ប៊ុនធិន | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ[41] |

[41] ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦, ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣, ប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការបង្កើតក្រសួងមុខងារសាធារណៈ។

❖ រដ្ឋលេខាធិការរដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រីៈ

១. ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល[42]។

### ១.៥.៣. សមិទ្ធផលសំខាន់ៗ

សមិទ្ធផលសំខាន់ៗ ដែលរាជរដ្ឋាភិបាល នីតិកាលទី៥ សម្រេចបានមានដូចខាងក្រោមៈ

I. **អភិបាលកិច្ចល្អៈ** ១. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ, ២. កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ គិតចាប់ពីឆ្នាំ២០១៣ ដល់ ២០១៧ ចៅក្រមសរុបនៅទូទាំងប្រទេសមាន ១៦៤នាក់ (ស្រី៣៨នាក់) ៣. កំណែទម្រង់រដ្ឋបាលសាធារណៈ (ការគ្រប់គ្រងមុខងារសាធារណៈកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ការងារប្រជាធិបតេយ្យនីយកម្ម សង្គមស៊ីវិល), ៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ (រួមមានលទ្ធផលការងាររបស់កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ លទ្ធផលការងារសំខាន់ៗ របស់នគបាលជាតិនៃក្រសួងមហាផ្ទៃជាដើម)[43]។

II. **ការលើកស្ទួយវិស័យកសិកម្មៈ** ១. ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម (ការជំរុញចលនាភូមិ១ ផលិតផល១) ផលិតកម្មដំណាំស្រូវ (បានកើនឡើងប្រមាណ ៤៦,៤៥% ពីចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧) ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ការនាំចេញផលិតផលកសិកម្ម សហគមន៍កសិកម្ម ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ការអភិវឌ្ឍដំណាំកៅស៊ូ ការងារអភិវឌ្ឍជនបទ) ទិន្នផលស្រូវទាំងប្រាំង និងវស្សា បានកើនពី ៣,១៦៣តោន/ហិកតា ដល់ ៣,២៩៥ តោន/ហិកតា ចាប់ពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៧ កើនប្រមាណជាង ៤,១៧៥%, ២. ការជំរុញផលិតកម្មសត្វ និង សុខភាពសត្វ, ៣. កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម, ៤. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

III. **ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ** ១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង, ២. ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ, ៣. ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី, ៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

[42] FRESH NEWS, *ប្រៀបធៀបបញ្ជីឈ្មោះសមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី៥ និងនីតិកាលទី៦*, ចុះផ្សាយនៅថ្ងៃទី០៦ កញ្ញា ២០១៨, អាចរកបាននៅ https://freshnewsasia.com/index.php/en/localnews/97785-2018-09-06-03-13-02.html , (ចូលទស្សនាថ្ងៃទី ៩ កក្កដា ឆ្នាំ២០២៤) ។

[43] ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០១៣-២០១៧, ខែមេសា ឆ្នាំ២០១៨*, ទំព័រទី២៥, ៣០, ៣៦, ៤៧, ៥៤, និង ៦១។

IV. **ការអភិវឌ្ឍវិស័យឯកជន និងការងារ៖** ១. ការពង្រឹងវិស័យឯកជន និងជំរុញការវិនិយោគ និងធុរកិច្ច ២. ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច និងមធ្យម (គិតត្រឹមឆ្នាំ២០១៧ រោងចក្របានចុះបញ្ជីនៅ ក្រសួងឧស្សាហកម្ម និងសិប្បកម្មមានចំនួន១,៥២២ រោងចក្រ ស្មើនឹង១៣៧%) ៣. ការអភិវឌ្ឍទីផ្សារការងារ (មានការកើនឡើង១៤៣% បើធៀបជាមួយឆ្នាំ២០១៣), ៤. ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ។

V. **ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស៖** ១. ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស (គិតមកដល់ដំណាច់ខែមករា ឆ្នាំ២០១៨ នេះ សំណង់អគារសិក្សាសរុបចំនួន៤,២៤៤ខ្នង និង ២៤,៦២៨ បន្ទប់), ២. ការលើកម្ពស់សុខភាព និងអាហារូបត្ថម្ភ, ៣. ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, ៤. ការអនុវត្តគោនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ (ស្ថិតិស្ត្រីក្នុងតួនាទី កើនពី១៩% ដល់២២%)។[44]

## **១.៦. នីតិកាលទី៦** ( **ឆ្នាំ២០១៨ - ២០២៣** )

### **១.៦.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត**

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៦ ដែលបានប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី២៩ ខែកក្កដា ឆ្នាំ២០១៨។ ការិយាល័យបោះឆ្នោតបានចាប់បើកពីម៉ោង៧.០០ ព្រឹក និងបិទទៅវិញនៅម៉ោង ៣.០០ល្ងាច។ ក្នុងនោះដែរ មានការិយាល័យបោះឆ្នោតសរុបចំនួន ២២,៩៦៧ ការិយាល័យ មានប្រជាពលរដ្ឋដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន ៨,៣៨០,២១៧ នាក់ ហើយក្នុងនោះអ្នកដែលបានទៅបោះឆ្នោតសរុបចំនួន ៦,៩៥៦,៩០០ នាក់ ដែលស្មើនឹង ៨៣,០២ ភាគរយ[45]។

គណបក្សនយោបាយដែលបានចូលរួមឈរឈ្មោះ ជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ នៃរដ្ឋសភាមានចំនួន ២០ គណបក្ស។ គណបក្សដែលឈ្នះឆ្នោត ដែលទទួលបានអាសនៈក្នុងរដ្ឋសភាគឺគណបក្សប្រជាជនកម្ពុជា ដែលទទួលបាន ១២៥ លើ ១២៥ អាសនៈក្នុងរដ្ឋសភាទាំងមូល[46]។

### **១.៦.២. សមាសភាពគណៈរដ្ឋមន្ត្រី**

I. នាយករដ្ឋមន្ត្រី: **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

[44] ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០១៣-២០១៧*, ខែមេសា ឆ្នាំ២០១៨, ទំព័រទី ១០៧, ១៥៥។

[45] គណៈកម្មាធិកាជាតិរៀបចំការបោះឆ្នោត, *តារាងលទ្ធផលផ្លូវការនៃចំនួនអ្នកបានបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨*។

[46] គ.ជ.ប, *លទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨(ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨)*, អាចរកបាននៅ https://www.nec.gov.kh/khmer/category/186។

II. **ឧបនាយករដ្ឋមន្ត្រី**: ១. សម្តេចក្រឡាហោម ស ខេង ២.សម្តេចពិជ័យសេនា ទៀ បាញ់ ៣.ឯកឧត្តម-ហោ ណាំងហុង ៤.លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ៥. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត-ប៊ិន ឈិន ប្រចាំការ ៦. ឯកឧត្តម យឹម ឆៃលី ៧. ឯកឧត្តម កែ គីមយ៉ាន ៨. ឯកឧត្តម ប្រាក់ សុខុន ៩. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ១០. ឯកឧត្តម ជា សុផារ៉ា។

III. **ទេសរដ្ឋមន្ត្រីៈ** ១. ឯកឧត្តម ឆាយ ថន, ២. ឯកឧត្តម ប៉ុល សារឿន (ទទួលបន្ទុកបេសកកម្មពិសេស), ៣. ឯកឧត្តម គន់ គីម (ទទួលបន្ទុកបេសកកម្មពិសេស), ៤. ឯកឧត្តម មាស សុភា (ទទួលបន្ទុកបេសកកម្មពិសេស), ៥. ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ, ៦. ឯកឧត្តម ញឹម វណ្ណដា (ទទួលបន្ទុកបេសកកម្មពិសេស), ៧. ឯកឧត្តម ស៊ុន ចាន់ថុល, ៨. ឯកឧត្តម ឱម យ៉ិនទៀង (ទទួលបន្ទុកបេសកកម្មពិសេស), ៩. ឯកឧត្តម អៀង មូលី (ទទួលបន្ទុកបេសកកម្មពិសេស), ១០. ឯកឧត្តម វ៉ា គឹមហុង (ទទួលបន្ទុកបេសកកម្មពិសេស), ១១. ឯកឧត្តម យឹម ណុលឡា (ទទួលបន្ទុកបេសកកម្មពិសេស), ១២. ឯកឧត្តម ហ៊ឹម ឆែម, ១៣. ឯកឧត្តម ជិន ប៊ុនស៊ាន (ទទួលបន្ទុកបេសកកម្មពិសេស), ១៤. ឯកឧត្តម-ហួ សិទ្ធី (ទទួលបន្ទុកបេសកម្មពិសេស), ១៥. ឯកឧត្តម យុន ហាំង (ទទួលបន្ទុកបេសកកម្មពិសេស), ១៦. ឯកឧត្តម លី ធុជ (ទទួលបន្ទុកបេសកកម្មពិសេស), និង ១៧. ឯកឧត្តម អូស្មាន ហាស្សាន់ (ទទួលបន្ទុកបេសកកម្មពិសេស)។

IV. **រដ្ឋមន្ត្រី និង រដ្ឋលេខាធិការតាមបណ្តាក្រសួង ស្ថាប័ន**:

| | |
|---|---|
| ១. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី |
| ២. សម្តេចក្រឡាហោម ស ខេង | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| ៣. សម្តេចពិជ័យសេនា ទៀ បាញ់ | រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ៤. ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តជាតិ |
| ៥. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៦. ឯកឧត្តម វេង សាខុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| ៧. ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |
| ៨. ឯកឧត្តម ប៉ាន សូរស័ក្តិ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |
| ៩. ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ១០. ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល |
| ១១. ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រីក្រសួងផែនការ |

| | |
|---|---|
| ១២. ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ១៣. ឯកឧត្តម វង សូត | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១៤. ឯកឧត្តម ជា សុផារ៉ា | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១៥. ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងបរិស្ថាន |
| ១៦. ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម |
| ១៧. ឯកឧត្តម ខៀវ កាញារីទ្ធ | រដ្ឋមន្ត្រីក្រសួងព័ត៌មាន |
| ១៨. ឯកឧត្តម អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ១៩. លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ២០. ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២១. ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២២. ឯកឧត្តម ស៊ុន ចាន់ថុល | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២៣. លោកជំទាវ ភឿង សកុណា | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ២៤. ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ២៥. ឯកឧត្តម ហ៊ឹម ឆែម | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា |
| ២៦. លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ២៧. ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២៨. ឯកឧត្តម ពេជ្រ ប៊ុនធិន | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |

❖ រដ្ឋលេខាធិការរដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រីៈ

| | |
|---|---|
| ១. ឯកឧត្តម ម៉ៅ ហាវណ្ណាល់ | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល[47]។ |

### ១.៦.៣. សមិទ្ធផលសំខាន់ៗ

រាជរដ្ឋាភិបាល នីតិកាលទី៦ សម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

១. រាជរដ្ឋាភិបាលរក្សាការពារបានយ៉ាងរឹងមាំនូវ សុខសន្តិភាព ស្ថេរភាពនយោបាយសណ្តាប់ធ្នាប់សាធារណៈទូទាំងប្រទេសជាពិសេសរក្សាបានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងស្ថានភាពដែលសភាពការក្នុងតំបន់ និង

[47] ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះនៅថ្ងៃ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១។

ពិភពលោកកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័សស្មុគស្មាញ និងប្រកបដោយគ្រោះថ្នាក់ជាពិសេស សង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន រួមជាមួយការផ្ទុះឡើងជំងឺកូវីដ១៩ ការប្រែប្រួលអាកាសធាតុដែលបង្កឱ្យមានផលប៉ះពាល់មកដល់សន្តិសុខ និងការលូតលាស់សេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។

២. រាជរដ្ឋាភិបាលបានជំរុញការអនុវត្តជាប់ជាប្រចាំនូវកម្មវិធីកែទម្រង់អភិបាលកិច្ចដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណមានភាពប្រទាក់ក្រឡាគ្នាសម្រេចបានសមិទ្ធផលតាមការគ្រោងទុក ទាំងការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់ប្រព័ន្ធច្បាប់ និងយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងកម្មវិធីកែទម្រង់តាមវិស័យនានាដើម្បីធានាការលើកកម្ពស់អភិបាលកិច្ច និង វិស័យសាធារណៈ ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។

៣. រាជរដ្ឋាភិបាលបានចាត់វិធានការមុតស្រួចក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលាការឆ្លងរាលដាលជាមួយជំងឺកូវីដ១៩ ជាមួយវិធានការស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ១៩ ព្រមទាំងពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធជំនួយសង្គមដើម្បីជួយគាំពារដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយវិបត្តិនៃជំងឺកូវីដ១៩ គ្រួសារក្រីក្រដែលទទួលរងសម្ពាធជាអតិបរមា និងគ្រួសារងាយរងហានិភ័យដែលរងការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ក្នុងរដូវវស្សាកន្លងមក និងកម្មវិធីជំនួយសង្គមមួយចំនួនទៀតសម្រាប់ជាប្រយោជន៍ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះទូទាំងប្រទេស ផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវ និងកិច្ចខិតខំប្រឹងប្រែងខាងលើនេះរាជរដ្ឋាភិបាលបានទប់លំនឹងសេដ្ឋកិច្ច សង្គម និងជីវភាពប្រជាជនឱ្យមានភាពល្អប្រសើរតាមរយៈការស្តារ និងជំរុញសេដ្ឋកិច្ចជាតិឱ្យមានកំណើនឡើងវិញយ៉ាងឆាប់រហ័ស។

៤. ចំពោះការអនុវត្តគោលនយោបាយការបរទេសដែលក្នុងស្ថានភាពពិភពលោកកំពុងតែប្រែប្រួលយ៉ាងឆាប់រហ័ស រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់ ប្រកបដោយភាពបត់បែនទៅនឹងការប្រែប្រួលភូមិសាស្ត្រនយោបាយដោយធានាបានភាពឯករាជ្យ អធិតេយ្យភាព សុខសន្តិភាព ស្ថេរភាពដើម្បីផលប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា ក្នុងក្រខណ្ឌតំបន់កម្ពុជាសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ និងជាប្រវត្តិសាស្រក្នុងតួនាទីជាប្រធានប្តូរវេនអាស៊ានឆ្នាំ២០២២ និងការរៀបចំដោយជោគជ័យ និងជាទីមោទនភាពជាតិដ៏ឧត្តុង្គឧត្តមនូវព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២

និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។ ដោយឡែកក្នុងក្របខណ្ឌអន្តរជាតិកម្ពុជាបាននឹងកំពុងចូលរួមដើរតួនាទីយ៉ាងសកម្មស្មើភាពជាមួយបណ្តាប្រទេសក្នុងកិច្ចការសំខាន់ៗ ក្នុងសកលលោក[48]។

[48] ប្រសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, *ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន*, (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣)។ អាចចូលទស្សនាបាននៅ https://www.youtube.com/live/GKy1jtHiZBQ?si=W9P2jmeDuBc47tBh&t=1932 ។

# ជំពូកទី ២

## ការរៀបចំគណៈរដ្ឋមន្ត្រី នីតិកាលទី ៧

# ជំពូកទី ២

# ការរៀបចំគណៈរដ្ឋមន្ត្រី នីតិកាលទី ៧

## ២.១. ការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត

ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ បានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏ល្អប្រសើរ ស្ងប់ស្ងាត់ គ្មានអំពើហិង្សា និងគ្មានភាពមិនប្រក្រតីណាមួយបានកើតឡើងនោះឡើយ។

លទ្ធផលផ្លូវការ នៃការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ បានបង្ហាញឲ្យដឹងថា មានប្រជាពលរដ្ឋខ្មែរចំនួន ៨ ២១៤ ៤៣០ នាក់ បាននាំគ្នាទៅបោះឆ្នោត នៅក្នុងនោះ មានសំឡេងបានការចំនួន ៧ ៧៧៤ ២៧៦ សំឡេង និងសំឡេងមិនបានការសរុបចំនួន ៤៤០ ១៥៤ សំឡេង។

ក្នុងចំណោមសំឡេងសន្លឹកឆ្នោតទាំងអស់ គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងគាំទ្រខ្ពស់ជាងគេបង្អស់រហូតដល់ ៦ ៣៩៨ ៣១១សំឡេង, គណបក្សហ៊្វុនស៊ិនប៉ិចឈរនៅលំដាប់ទី២ ដោយទទួលបានសំឡេងគាំទ្រ ៧១៦ ៤៩០ សំឡេង, គណបក្សខ្មែររួបរួមជាតិទទួលបាន ១៣៤ ២៨៥ សំឡេង, គណបក្សយុវជនកម្ពុជាទទួលបាន ៩៧ ៤១២ សំឡេង, គណបក្សធម្មាធិបតេយ្យទទួលបាន ៨៤ ០៣០សំឡេង ហើយគណបក្សក្រៅពីនោះទទួលបានសំឡេង បន្តិចបន្តួច[49]។

ការបោះឆ្នោតមួយដែលបានកើតឡើងយ៉ាងល្អក្នុងបរិយាកាស សុខសន្តិភាព និងជោគជ័យដែលឆ្លុះបញ្ចាំងអំពីប្រជាធិបតេយ្យ សេរីពហុបក្សយ៉ាងពិតប្រាកដ។ ការបោះឆ្នោតឆ្នាំ២០២៣នេះ បានប្រព្រឹត្តទៅដោយរលូន និងស្ថិតនៅក្រោមក្រសែភ្នែករបស់អ្នកសង្កេតការណ៍ជាតិ ជិត៩ម៉ឺននាក់ និងអ្នកសង្កេតការណ៍អន្តរជាតិមកពី ៦៥ប្រទេស និងស្ថាប័នអន្តរជាតិ។

គណបក្សនយោបាយចំនួន ១៨ បានចូលរួមប្រកួតប្រជែងយ៉ាងសកម្មដើម្បីដណ្ដើមយកអាសនៈនៅក្នុងរដ្ឋសភា។ លទ្ធផលបង្ហាញថា មានគណបក្សនយោបាយចំនួន២ បានទទួលអាសនៈក្នុងរដ្ឋសភា ក្នុងនោះរួមមានៈ

- **គណបក្សប្រជាជនកម្ពុជា**ឈ្នះដាច់ ដោយទទួលអាសនៈក្នុងរដ្ឋសភាបាន ចំនួន ១២០អាសនៈ

[49] អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី, *គ.ជ.ប បង្ហាញលទ្ធផលផ្លូវការនៃការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដោយគិតជាសំឡេងឆ្នោត*, ថ្ងៃទី៥ សីហា ២០២៣, អាចរកបាននៅ https://pressocm.gov.kh/archives/83511, (ចូលទស្សនានៅថ្ងៃទី ០៥ មិថុនា ២០២៤)។

❖ និង **គណបក្សហ៊្វុនស៊ិនប៉ិច** ទទួលបាន ៥អាសនៈ[50]។

ដូច្នេះរដ្ឋសភាសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧នេះ គឺជារដ្ឋសភាពហុបក្ស ដែលប្រជាពលរដ្ឋខ្មែរបានសម្រេចជ្រើសរើសតាមរយៈសន្លឹកឆ្នោត។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភាឆ្នាំ២០២៣នេះ គឺជាសមិទ្ធផលដ៏ធំធេង និងមានអត្ថន័យយ៉ាងជ្រាលជ្រៅសម្រាប់ព្រះរាជាណាចក្រកម្ពុជាក៏ដូចជាសម្រាប់ប្រជាពលរដ្ឋខ្មែរ។

## ២.២. ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា

ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា អាចធ្វើឡើងតាម ២ របៀប យោងតាមរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។ នីតិវិធីនេះត្រូវបានធ្វើការកែសម្រួលជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន ដែលបានរំលេចក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ កាលពីឆ្នាំ២០២២[51]។

### ២.២.១. របៀបទី១

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធាន រដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាត (៥០% + ១) នៃសមាជិករដ្ឋសភាទាំងមូល។ ប្រធានរដ្ឋសភា ត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិករដ្ឋសភា ដែលមានសញ្ជាតិខ្មែរ តែមួយគត់។ រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុង ឧបសម្ព័ន្ធទី៥ រដ្ឋធម្មនុញ្ញ[52]។

តាមសេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបាន ការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវ បានជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រឬជា

[50] អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី, *ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ជាសមិទ្ធផលដ៏ធំធេងសម្រាប់កម្ពុជា*, ២៧ កក្កដា ២០២៣, អាចរកបាននៅ https://pressocm.gov.kh/archives/83362, (ចូលទស្សនានៅថ្ងៃទី០៥ មិថុនា ២០២៤)។

[51] ឆេង សារី, *នីតិវិធីនៃការបង្កើតរាជរដ្ឋាភិបាលកម្ពុជា*, ខែកក្កដា ឆ្នាំ២០២៣, ទំព័រ ១១។

[52] មាត្រា៨២ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មលើកទី៩ កាលពីឆ្នាំ២០២១។

សមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តួងផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែងមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង[53]។

**២.២.២. របៀបទី២**

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ ថ្មី (មួយ) និង មាត្រា ១១៩ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល[54]។

ការរៀបចំបញ្ជីរាយនាមសមាសភាព ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តដូចតទៅ៖

- បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធាន គណៈ-កម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។
- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភាព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយ ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្តួងផ្តងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។
- ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំជាបន្ទាន់ និងដោយឥតបង្អង់នូវបញ្ជីរាយនាមជាកញ្ចប់មួយដែលមានសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិក

[53] មាត្រា១១៩ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មលើកទី១០ កាលពីឆ្នាំ២០២២។

[54] មាត្រា ៣ ថ្មី (មួយ) នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលត្រូវបានធ្វើវិសោធនកម្មលើកទី១០ កាលពីឆ្នាំ២០២២។

ទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ ព្រឹទ្ធសមាជិករដ្ឋសភាត្រូវដឹកនាំប្រជុំរដ្ឋសភា ដើម្បីបោះឆ្នោតអនុម័តបញ្ជីនេះជាបន្ទាន់។

- ព្រឹទ្ធសមាជិករដ្ឋសភាត្រូវបានជ្រើសរើសដោយកំណត់យកសមាជិករដ្ឋសភា ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិករដ្ឋសភាទាំងអស់។ ក្នុងករណីដែលព្រឹទ្ធសមាជិករដ្ឋសភារូបនេះ មិនអាចអនុវត្តមុខងាររបស់ខ្លួនបាន មុខតំណែងព្រឹទ្ធសមាជិករដ្ឋសភាត្រូវប្រគល់ទៅសមាជិករដ្ឋសភាដ៏ទៃទៀតដែលមានអាយុច្រើនក្នុងលំដាប់បន្តបន្ទាប់[55]។

## ២.៣. សមាសភាពគណៈរដ្ឋមន្ត្រី

សមាសភាពនៃរាជរដ្ឋាភិបាល នីតិកាលទី ៧ មានដូចជា៖

- ❖ នាយករដ្ឋមន្ត្រី
- ❖ ឧបនាយករដ្ឋមន្ត្រី
- ❖ ទេសរដ្ឋមន្ត្រី
- ❖ និង រដ្ឋមន្ត្រី[56]។

### ២.៣.១. នាយករដ្ឋមន្ត្រី

- **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**[57] ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា។ ក្រោយមកនៅក្នុងខែកញ្ញា ឆ្នាំ២០២៣ ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់គោរមងារដ៏ឧត្តុង្គឧត្តមខ្ពង់ខ្ពស់បំផុតជូននាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជា «**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**»[58]។

### ២.៣.២. ឧបនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រីមានចំនួន ១១ រូបរួមមានដូចជា៖

១. ឯកឧត្តម នេត សាវឿន

២. ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន

---

[55] មាត្រា ៤ ថ្មី (មួយ) នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលត្រូវបានធ្វើវិសោធនកម្មលើកទី១០ កាលពីឆ្នាំ២០២២។

[56] ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, មាត្រា៨។

[57] ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

[58] ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១១០ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការត្រាស់បង្គាប់ផ្តល់គោរមងារដ៏ឧត្តុងឧត្តមខ្ពង់ខ្ពស់បំផុតជូននាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជា «**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**» ។

៣. ឯកឧត្តម ស៊ុន ចាន់ថុល
៤. ឯកឧត្តម ហង់ជួន ណារ៉ុន
៥. ឯកឧត្តម សាយ សំអាល់
៦. ឯកឧត្តម ស សុខា
៧. ឯកឧត្តម ទៀ សីហា
៨. ឯកឧត្តម កើត រិទ្ធ
៩. ឯកឧត្តម សុខ ចិន្តាសោភា
១០. ឯកឧត្តម វង្សី វិស្សុត
១១. ឯកឧត្តម ហ៊ុន ម៉ានី[59]។

### ២.៣.៣. ទេសរដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីមានចំនួន ២៣ រូបរួមមានដូចជា៖

១. ឯកឧត្តម គន់ គីម (ទទួលបន្ទុកបេសកកម្មពិសេស)
២. ឯកឧត្តម ហូ សិទ្ធី (ទទួលបន្ទុកបេសកកម្មពិសេស)
៣. ឯកឧត្តម អ៊ុក រ៉ាប៊ុន (ទទួលបន្ទុកបេសកកម្មពិសេស)
៤. ឯកឧត្តម ឱម យ៉ិនទៀង (ទទួលបន្ទុកបេសកកម្មពិសេស)
៥. ឯកឧត្តម អៀង ម៉ូលី (ទទួលបន្ទុកបេសកកម្មពិសេស)
៦. ឯកឧត្តម ថោង ខុន (ទទួលបន្ទុកបេសកកម្មពិសេស)
៧. ឯកឧត្តម ពេជ សោភ័ន (ទទួលបន្ទុកបេសកកម្មពិសេស)
៨. ឯកឧត្តម ព្រុំ សុខា (ទទួលបន្ទុកបេសកកម្មពិសេស)
៩. ឯកឧត្តម សក់ សេដ្ឋា (ទទួលបន្ទុកបេសកកម្មពិសេស)
១០. ឯកឧត្តម អូស្មាន ហាស្សាន់ (ទទួលបន្ទុកបេសកកម្មពិសេស)
១១. ឯកឧត្តម អ៊ី ឈាន (ទទួលបន្ទុកបេសកកម្មពិសេស)
១២. ឯកឧត្តម អ៊ុក ប្រាជ្ញា (ទទួលបន្ទុកបេសកកម្មពិសេស)
១៣. ឯកឧត្តម អ៊ុច បូរិទ្ធ (ទទួលបន្ទុកបេសកកម្មពិសេស)
១៤. ឯកឧត្តម ស្វាយ ស៊ីថា (ទទួលបន្ទុកបេសកកម្មពិសេស)
១៥. ឯកឧត្តម ផៃ ស៊ីផាន (ទទួលបន្ទុកបេសកកម្មពិសេស)

[59] ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល។

| | |
|---|---|
| ១៦. ឯកឧត្តម លី ធុជ | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៧. ឯកឧត្តម ឆែម គាតរិទ្ធី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៨. ឯកឧត្តម ឈៀង យ៉ាណារ៉ា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៩. ឯកឧត្តម សុក ស៊ីផាន់ណា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២០. ឯកឧត្តម កែវ រ៉េមី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២១. ឯកឧត្តម គី តិច | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២២. ឯកឧត្តម ស្រ៊ុ ថាមរុង្គ[60] | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២៣. ឯកឧត្តម ប៉ែន វិបុល[61] | (ទទួលបន្ទុកបេសកកម្មពិសេស)។ |

**២.៣.៤. រដ្ឋមន្ត្រី**

រដ្ឋមន្ត្រី នីតិកាលទី៧ មានចំនួន ៣០ រូបរួមមានដូចជា៖

| | | |
|---|---|---|
| ១. | ឯកឧត្តម វង្សី វិស្សុត | រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី |
| ២. | ឯកឧត្តម ស សុខា | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| ៣. | ឯកឧត្តម ទៀ សីហា | រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ៤. | ឯកឧត្តម សុខ ចិន្ដាសោភា | រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តជាតិ |
| ៥. | ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦. | ឯកឧត្តម ឌិត ទីណា | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៧. | ឯកឧត្តម ឆាយ ឫទ្ធិសែន | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |
| ៨. | លោកជំទាវ ចម និម្មល | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |
| ៩. | ឯកឧត្តម ហែម វណ្ណឌី | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ១០. | ឯកឧត្តម កែវ រតនៈ | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល |
| ១១. | ឯកឧត្តម ប៊ិន ត្រឈៃ | រដ្ឋមន្ត្រីក្រសួងផែនការ |
| ១២. | ឯកឧត្តម ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ១៣. | ឯកឧត្តម ជា សុមេធី | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១៤. | ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១៥. | ឯកឧត្តម អ៊ាង សុផល្លែត | រដ្ឋមន្ត្រីក្រសួងបរិស្ថាន |

[60] ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល។
[61] ព្រះរាជក្រឹត្យដដែល។

| | |
|---|---|
| ១៦. ឯកឧត្តម ថោ ជេដ្ឋា | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម |
| ១៧. ឯកឧត្តម នេត្រ ភក្ត្រា | រដ្ឋមន្ត្រីក្រសួងព័ត៌មាន |
| ១៨. ឯកឧត្តម កើត រិទ្ធ | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ១៩. ឯកឧត្តម ហួត ហាក់ | រដ្ឋមន្ត្រីក្រសួងអធិការកិច្ច |
| ២០. ឯកឧត្តម ជា វ៉ាន់ដេត | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២១. ឯកឧត្តម ឈាង រ៉ា | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២២. ឯកឧត្តម ប៉េង ពោធិ៍នា | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២៣. លោកជំទាវ ភឿង សកុណា | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ២៤. ឯកឧត្តម សុខ សូកេន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ២៥. ឯកឧត្តម ចាយ បូរិន | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា |
| ២៦. លោកជំទាវ អ៊ីង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ២៧. ឯកឧត្តម ហេង សួរ | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២៨. ឯកឧត្តម ហ៊ុន ម៉ានី | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
| ២៩. ឯកឧត្តម ម៉ៅ ហាវណ្ណាល់ | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ៣០. ឯកឧត្តម ឡាំ ជា | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការពារព្រំដែន[62]។ |

## ២.៤. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈរដ្ឋមន្ត្រី

### ២.៤.១. នាយករដ្ឋមន្ត្រី

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខរាជរដ្ឋាភិបាល[63]។

**នាយរដ្ឋមន្ត្រីមានតួនាទី ភារកិច្ច និងសិទ្ធិអំណាចដូចជា៖**

- ទទួលខុសត្រូវរួមលើសមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និង សកម្មភាពរបស់រាជរដ្ឋាភិបាល។
- ជាអ្នកកោះប្រជុំ និង ជាអធិបតីនៃអង្គប្រជុំ

[62] ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

[63] ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, មាត្រា១៣។

- ដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។
- ចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និងសារាចររបស់រាជរដ្ឋាភិបាល។
- លើកសំណើដល់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ។
- លើកសំណើអំពីសេចក្តីព្រាងច្បាប់ និងសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច របស់សមាជិករាជរដ្ឋាភិបាលជូនសភាអនុម័ត ។
- ត្រួតពិនិត្យការងារសកម្មភាពអំពើប្រព្រឹត្ត និងទំនួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាលហើយមានសិទ្ធិ ផ្លាស់សមាជិករដ្ឋាភិបាលតាមនីតិវិធី ។
- លើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងនៅតាមក្រសួង ស្ថាប័ននានា ដោយព្រះរាជក្រឹត្យ។
- លើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចខាងក្រោម៖
  - ទេសាភិបាល ទេសាភិបាលរងធានាគារជាតិនៃកម្ពុជា
  - អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
  - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
  - ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល
  - ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
  - អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
  - អគ្គស្នងការនគរបាលជាតិ[64]។
- តែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាដូចតទៅ៖
  - អគ្គនាយករង/ ប្រធាននាយកដ្ឋាន
  - អគ្គាធិការរង/ អធិការក្រសួង
  - សាកលវិទ្យាធិការរង/ ព្រឹទ្ធបុរស
  - អភិបាលរងរាជធានី/ ខេត្ត, អភិបាលក្រុង/ ស្រុក/ ខណ្ឌ

[64] ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, មាត្រា២៣។

- មន្ត្រីការទូត
- វរសេនីយ៍ឯក និង ថ្នាក់ប្រហាក់ប្រហែលឡើងទៅ[65]។

### ២.៤.២. ឧបនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមលើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។ ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រីលើវិស័យនានា តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។ កិច្ចការដែលទាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ[66]។

### ២.៤.៣. ទេសរដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមលើរដ្ឋមន្ត្រី។ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសជួយនាយករដ្ឋមន្ត្រីលើកិច្ចការក្នុងវិស័យនានា ដឹកនាំអាជ្ញាធរ គណៈកម្មាធិការ ឬក្រុមប្រឹក្សាដែលចំណុះឱ្យរាជរដ្ឋាភិបាល និងទទួលបន្ទុកអនុវត្តការងារនានាតាមការប្រគល់របស់នាយករដ្ឋមន្ត្រី[67]។

### ២.៤.៤. រដ្ឋមន្ត្រី

រដ្ឋមន្ត្រីជា សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រងក្រសួងចំនួន ២៨ និងរដ្ឋលេខាធិការដ្ឋានចំនួន ២។

**រដ្ឋមន្ត្រីមានតួនាទី ភារកិច្ច និងសិទ្ធិអំណាចដូចជា៖**

- ដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន។
- ដឹកនាំ គ្រប់គ្រងក្រសួង និងអង្គភាពចំណុះក្នុងក្របខណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់។
- លើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ។
- តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ។

---

[65] សាស្ត្រាចារ្យ ហៀង សាង, *សៀវភៅនីតិរដ្ឋបាលទូទៅ,* (ភ្នំពេញ៖ រោងពុម្ពស៊ីហេង, បោះពុម្ពលើកទី៦ ឆ្នាំ២០២១), ទំព័រ ២៧។

[66] ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, មាត្រា៣០។

[67] សេចក្តីសម្រេចលេខ ៦១សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

– ចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ[68]។

[68] ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, មាត្រា៤៧។

# ជំពូកទី ៣
# ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
# នីតិកាលទី ៧

# ជំពូកទី ៣

# ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧

## ៣.១. របៀបរបបធ្វើការ និងការបែងចែកភារកិច្ច

នៅក្នុងផ្នែកនេះនិយាយអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ចជូន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ។

### ៣.១.១. នាយករដ្ឋមន្ត្រី

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ទទួលបន្ទុកដឹកនាំការងាររួមរបស់គណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ហារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ព្រមទាំងទទួលបន្ទុកដោយឡែកក្នុងទំនាក់ទំនងផ្ទាល់ជាមួយព្រះមហាក្សត្រ សម្រាប់កិច្ចការរបស់រាជរដ្ឋាភិបាល និងដឹកនាំបញ្ជាផ្ទាល់លើបញ្ជាការដ្ឋានអង្គរក្ស បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

### ៣.១.២. ឧបនាយករដ្ឋមន្ត្រី

១. **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រីអវត្តមាន, ជួយនាយករដ្ឋមន្ត្រីលើវិស័យសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ, ក្នុងក្របខណ្ឌអន្តរក្រសួង ជួយនាយករដ្ឋមន្ត្រីក្នុងការសម្របសម្រួលដឹកនាំកម្លាំងគ្រប់ប្រភេទ ដើម្បីការងារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ, ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងពេលនាយករដ្ឋមន្ត្រីអវត្តមាន, ជួយតម្រង់ទិសដៅដល់អាជ្ញាធរ គណៈកម្មាធិការ ក្រុមប្រឹក្សាដែលចំណុះឱ្យរាជរដ្ឋាភិបាលតាមការប្រគល់សិទ្ធិរបស់នាយករដ្ឋមន្ត្រី ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

២. **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រី និងឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន អវត្តមាន, ជួយនាយករដ្ឋមន្ត្រីលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៣. **ឯកឧត្តម ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារ ទាក់ទាញការវិនិយោគឯកជន និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ទទួលបន្ទុកជាសហប្រធានខាងភាគីកម្ពុជា នៃគណៈកម្មការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ដើម្បីអនុវត្តកិច្ចសហ-

ប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ, ជួយនាយករដ្ឋមន្ត្រីលើការងារគមនាគមន៍ដឹកជញ្ជូន និងភស្តុភារកម្ម ទាំងការដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស និងជាប្រធានក្រុមប្រឹក្សាជាតិភស្តុភារកម្ម ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៤. **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យអប់រំ យុវជន និងកីឡា ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៥. **ឯកឧត្តមបណ្ឌិត សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ជាប្រធានអាជ្ញាធរជាតិដោះស្រាយដីធ្លី ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៦. **ឯកឧត្តមបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើកិច្ចការមហាផ្ទៃ, ដឹកនាំសម្របសម្រួលការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ការជួញដូរមនុស្ស និងការបង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ, ការបំផ្លាញចោលអាវុធ និងជាសេនាធិការជួយនាយករដ្ឋមន្ត្រី លើការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៧. **ឯកឧត្តម ទៀ សីហា** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យការពារជាតិ, ដឹកនាំកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៨. **ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យយុត្តិធម៌ និងការងារជាមួយតុលាការ និងអង្គការអយ្យការ, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការដឹកនាំសម្របសម្រួលការអនុវត្តនយោបាយព្រហ្មទណ្ឌ, ជួយនាយករដ្ឋមន្ត្រីលើការដឹកនាំសម្របសម្រួលការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ, ជួយនាយក-រដ្ឋមន្ត្រីលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៩. **ឯកឧត្តម សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកលើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ផ្តល់យោបល់ជូននាយករដ្ឋមន្ត្រី អំពីក្របខណ្ឌគោលនយោបាយក្រៅប្រទេស, ការសម្របសម្រួលបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ និងទទួលសិទ្ធិពី

នាយករដ្ឋមន្ត្រីក្នុងការពិនិត្យ និងសម្រេចលើសំណើសុំកូន និងការសុំលាសញ្ជាតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

១០. **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ សម្របសម្រួលកិច្ចការសម្រាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តា ឧបនាយករដ្ឋមន្ត្រី, ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដាន និងសម្របសម្រួលទាក់ទងនឹងកិច្ចការ ដែលនៅសេសសល់របស់តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម, ដឹកនាំផ្ទាល់ក្រុមប្រឹក្សាអ្នកច្បាប់ ព្រមទាំងជួយនាយករដ្ឋមន្ត្រី ក្នុងកិច្ចការងារទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា និងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ, ដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន[៦៧]។

១១. **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

### ៣.១.៣. ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

១. **ឯកឧត្តមសង្គហបណ្ឌិត គន់ គីម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការអតីតយុទ្ធជន និងជនពិការ, ជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២. **ឯកឧត្តម ហូ សិទ្ធី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជានាយកខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៣. **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ, ជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៤. **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៥. **ឯកឧត្តម អៀង ម៉ូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

[៦៧] ប្រការ៣ នៃសេចក្តីសម្រេចលេខ ៦១សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

៦. **ឯកឧត្តម ថោង ខុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជំរុញការអភិវឌ្ឍចលនាកីឡា និងដឹកនាំគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៧. **ឯកឧត្តម ពេជ សោភ័ន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកលើការពង្រឹងលើវិស័យអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់នាយករដ្ឋមន្ត្រី។

៨. **ឯកឧត្តម ព្រំ សុខា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៩. **ឯកឧត្តម សក់ សេដ្ឋា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១០. **ឯកឧត្តម អូស្មាន ហាស្សាន់** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារចលនាមូស្លីម និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១១. **ឯកឧត្តម អ៊ី ឈាន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារទាក់ទងនឹងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់នាយករដ្ឋមន្ត្រី។

១២. **ឯកឧត្តម អ៊ុក ប្រាថ្នា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារសង្គម និង វប្បធម៌ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៣. **ឯកឧត្តម អ៊ុច បូររិទ្ធ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការសម្របសម្រួលកិច្ចការទំនាក់ទំនងកិច្ចការបរទេស ក្នុងគណបក្សនយោបាយ និងអង្គការមហាជន ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៤. **ឯកឧត្តម ស្វាយ ស៊ីថា** ទេសរដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើកិច្ចការព័ត៌មាន និងសាធារណមតិព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៥. **ឯកឧត្តមសន្តិបណ្ឌិត ឆៃ ស៊ីណារិទ្ធ** ទេសរដ្ឋមមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារសេវាប្រមូល និងវិភាគព័ត៌មានផ្នែកសន្តិសុខ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៦. **ឯកឧត្តមបណ្ឌិត លី ធុជ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានគណៈកម្មាធិការជាតិអេស្កាប់, ជាអនុប្រធានទី១ នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៧. **ឯកឧត្តមបណ្ឌិត ឆែម គាតវិទ្ធី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៨. **ឯកឧត្តមបណ្ឌិត ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី២ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទទួលបន្ទុកលើការងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៩. **ឯកឧត្តមបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារទំនាក់ទំនងជាមួយអង្គការអន្តជាតិ ក្នុងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ជាអាទិ៍ ASEM BRICS និងអង្គការសហប្រតិបត្តិការសៀងហៃ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២០. **ឯកឧត្តម កែវ រ៉េមី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការសម្របសម្រួលដឹកនាំកិច្ចការសិទ្ធិមនុស្សរបស់កម្ពុជា និងទទួលបន្ទុកជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២១. **ឯកឧត្តមបណ្ឌិត គី តិច** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការដឹកនាំ និងគ្រប់គ្រងក្រុមមេធាវីរាជរដ្ឋាភិបាល ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី[70]។

២២. **ឯកឧត្តម ស្រ៊ី ថាមរុង្គ** ទទួលបន្ទុកបេសកកម្មពិសេស។

២៣. **ឯកឧត្តម ប៉ែន វិបុល** ទទួលបន្ទុកបេសកកម្មពិសេស។

## ៣.២. កិច្ចប្រជុំគណៈរដ្ឋមន្ត្រី

ការប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី ជាទូទៅអាចប្រជុំជាដំណាក់កាលដូចតទៅៈ

- ❖ កិច្ចប្រជុំលើកទី១
- ❖ កិច្ចប្រជុំអន្តរក្រសួង
- ❖ និង កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រីត្រូវតែផ្ញើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប[71]។

[70] ប្រការ៦ នៃសេចក្តីសម្រេចលេខ ៦១សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

[71] មាត្រា២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។

### ៣.២.១. កិច្ចប្រជុំលើកទី១

កិច្ចប្រជុំលើកទី១ គឺជាកិច្ចប្រជុំដែលធ្វើឡើងដោយការចូលរួមមកពីតំណាងក្រសួង និងស្ថាប័ននានារបស់រដ្ឋ ជាមួយបណ្តាក្រុមប្រឹក្សា មានក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

កិច្ចប្រជុំ គឺដំណើរការ និងប្រព្រឹត្តទៅលើការពិនិត្យ និងកែសម្រួលលើទិដ្ឋភាពទាំងទម្រង់ ទាំងខ្លឹមសារគតិយុត្តនានារួមទាំងផលប៉ះពាល់ផ្នែកច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

កិច្ចប្រជុំលើកទី១ ត្រូវដឹកនាំប្រជុំជាសហប្រធាន ដែល១រូបមកពីក្រុមប្រឹក្សាអ្នកច្បាប់ ១រូបមកពីក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។

គ្រប់លិខិតបទដ្ឋានគតិយុត្តនានា សេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងគោលនយោបាយទាំងឡាយ របស់រាជរដ្ឋាភិបាលដែលបានបញ្ជូនមកពីបណ្តាក្រសួង និងស្ថាប័នរដ្ឋនានាត្រូវឆ្លងកាត់ការប្រជុំត្រួតពិនិត្យនៃកិច្ចប្រជុំលើកទី១ នេះជាមុនសិន។

ក្រោយពីប្រជុំត្រួតពិនិត្យ និងផ្តល់យោបល់លើកិច្ចប្រជុំលើកទីមួយនេះ ទើបលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ ព្រមទាំងគោលនយោបាយទាំងឡាយរបស់រាជរដ្ឋាភិបាល ត្រូវដាក់បញ្ជូនទៅក្នុងកិច្ចប្រជុំអន្តរក្រសួងបន្តទៅទៀត។

### ៣.២.២. កិច្ចប្រជុំអន្តរក្រសួង

ការប្រជុំអន្តរក្រសួង ត្រូវបានដឹកនាំអង្គប្រជុំដោយនាយករដ្ឋមន្ត្រីផ្ទាល់ ឬដោយឧបនាយករដ្ឋមន្ត្រីណាម្នាក់តាមរយៈការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រីដើម្បីដឹកនាំការងារ ប៉ុន្តែអាចប្រគល់តួនាទីទៅឱ្យរដ្ឋលេខាធិការ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឬអគ្គលេខាធិការរាជរដ្ឋាភិបាលដឹកនាំការប្រជុំនោះក៏បាន។

ការប្រជុំអន្តរក្រសួងនេះ ត្រូវមានការចូលរួមពីសាមីក្រសួង ពីក្រសួងពាក់ព័ន្ធ ពីតំណាងក្រុមប្រឹក្សាអ្នកច្បាប់ និងពីតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងនាយកដ្ឋានជំនាញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ការប្រជុំនេះដំណើរការប្រព្រឹត្តទៅដូចជាការប្រជុំតាមជំនាញបច្ចេកទេសដែរ ប៉ុន្តែត្រូវមានការចូលរួមពីសំណាក់តំណាងក្រសួង ស្ថាប័ននានា ដែលមានលក្ខណៈទូលំទូលាយជាងកិច្ចប្រជុំធម្មតា ហើយធ្វើការពិនិត្យកែសម្រួល និងផ្តល់យោបល់ទើបដាក់ចូលទៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

### ៣.២.៣. កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

ការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីផ្ទាល់ កិច្ចប្រជុំនេះត្រូវធ្វើឡើងនៅទីស្តីការគណៈរដ្ឋមន្ត្រីដែលមានសមាសភាពអ្នកចូលរួម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។

កិច្ចប្រជុំពេញអង្គបានរៀបចំតាមរបៀបវារៈ ដោយអគ្គលេខាធិការរបស់រាជរដ្ឋាភិបាលដែលបានអនុញ្ញាតពីនាយករដ្ឋមន្ត្រី។ បន្ទាប់មករបៀបវារៈនេះត្រូវផ្ញើជូនសមាជិករាជរដ្ឋាភិបាលទាំងអស់ ព្រមទាំងអ្នកពាក់ព័ន្ធទាំងឡាយដែលជាប់ទាក់ទងទៅនឹងបញ្ហាដែលមានចែងក្នុងរបៀបវារៈ។

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល ត្រូវចូលរួមប្រជុំគ្រប់កិច្ចប្រជុំនានារបស់គណៈរដ្ឋមន្ត្រី និងជាអ្នករៀបចំធ្វើរបាយការណ៍សង្ខេបខ្លឹមសារនៃសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីជារបាយការណ៍សង្ខេប និងឯកសារវិភាគផ្តល់យោបល់គ្រប់បែបយ៉ាង ដែលឯកសារទាំងនេះត្រូវតម្កល់ទុកនៅទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គលេខាធិការមួយរូបរួមទាំង អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាលជាអ្នកដឹកនាំអគ្គលេខាធិការដ្ឋានដែលជាសេនាធិការបម្រើឱ្យរាជរដ្ឋាភិបាល ដើម្បីបំពេញសកម្មភាពផ្សេងៗក្នុងការសម្របសម្រួលការងាររបស់រាជរដ្ឋាភិបាលក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋសភា និងការងារបច្ចេកទេសនានាព្រមទាំងការងាររដ្ឋបាលទាំងឡាយ តាមការទទួលការងារផ្ទាល់ពីនាយករដ្ឋមន្ត្រី។ អគ្គលេខាធិការរាជរដ្ឋាភិបាលទាមទារឱ្យមានសម្ថភាពខ្ពស់ក្នុងការបំពេញសកម្មភាពទាំងផ្នែកបច្ចេកទេស ទាំងផ្នែកនយោបាយ។

សេចក្តីជូនដំណឹងជាផ្លូវការ ដែលត្រូវបានផ្តល់យោបល់ និងតែងតាំងរួចហើយត្រូវបានអ្នកនាំពាក្យនៃរាជរដ្ឋាភិបាលធ្វើអត្ថាធិប្បាយនៅពេលប្រជុំគណៈរដ្ឋមន្ត្រីបានបញ្ចប់ភ្លាម ហើយត្រូវធ្វើការផ្សព្វផ្សាយ។

ក្រោយពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានត្រួតពិនិត្យ និងសម្រេចចប់សព្វគ្រប់ហើយ លិខិតបទដ្ឋានគតិយុត្តទាំងឡាយនោះ ត្រូវយកទៅអនុវត្តភ្លាមតែម្តងក្រោយពីនាយករដ្ឋមន្ត្រីបានចុះហត្ថលេខា។ ប៉ុន្តែប្រសិនបើលិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាត្រូវបញ្ជូនទៅតាមនីតិវិធីច្បាប់បន្តទៀត[72]។

## ៣.៣.កម្មវិធីនយោបាយ

### ៣.៣.១. គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលប្តេជ្ញាពុះពារសម្រេច ឱ្យបាននូវគោលដៅធំៗជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

១- ការពារសន្តិភាព ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងការពាររាល់សមិទ្ធផលនៃសង្គមជាតិឱ្យបានគង់វង្សស្ថិតស្ថេរ។

២- កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរី ពហុបក្ស ដ៏ជឿនលឿន និងរឹងមាំសប្បាយរស់នៅយ៉ាងសុខដុមរមនា ប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ និងមានការគោរពសិទ្ធិមនុស្ស។

[72] សាស្ត្រាចារ្យ ជុំ អ៊ីម, *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា*, (បោះពុម្ពលើកទី១ ឆ្នាំ២០១២ ដោយរោងពុម្ពសុខចេង), ទំព័រ ១៦៨។

៣- កសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលធានាការផ្ដល់ការគាំពារដល់ប្រជាជន ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច ហានិភ័យសុខភាពសាធារណៈ និងភាពងាយរងគ្រោះផ្សេងៗ ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌនៃការងារ និងការរស់នៅ។

៤- ជំរុញការអនុវត្ត «កម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥» និងកាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិបរមា។

៥- បន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសទាំងអស់នៅលើសកលលោក និងអង្គការអន្តរជាតិនានា ហើយចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ និងពិភពលោក។[73]

### ៣.៣.២. គោលនយោបាយធំៗ ជាអាទិភាព

ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រខាងលើនេះ រាជរដ្ឋាភិបាលកំណត់បណ្ដាគោលនយោបាយធំៗជាអាទិភាព ដូចខាងក្រោម៖

១- ការពារសន្តិភាព ស្ថិរភាពនយោបាយ និងរាល់សមិទ្ធផលសង្គមជាតិឱ្យរឹងមាំស្ថិតស្ថេរគង់វង្ស។

២- លើកកម្ពស់ជីវភាពប្រជាជនគ្រប់រូប ទាំងខាងសម្ភារៈ និងស្មារតីឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ។

៣- ការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពប្រជាជន និងពង្រឹងនីតិរដ្ឋ។

៤- ពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ ជារដ្ឋបាលប្រជាជន និងបម្រើផលប្រយោជន៍ប្រជាជន។

៥- បន្តជំរុញការកែទម្រង់ដើម្បីអភិបាលកិច្ចល្អ[74]។

### ៣.៣.៣. គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ

រាជរដ្ឋាភិបាលបន្តផ្ដោតការយកចិត្តទុកដាក់លើគោលនយោបាយជាអាទិភាព ដូចជា៖

១- ការគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ។

២- ការពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍ។

៣- ការអភិវឌ្ឍវិស័យឯកជន។

៤- ការអភិវឌ្ឍឧស្សាហកម្ម សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យម។

៥- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ។

---

[73] សៀវភៅ *«កម្មវិធីនយោបាយ» របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨*, ខែសីហា ឆ្នាំ២០២៣, ទំព័រទី១។

[74] សៀវភៅ *«កម្មវិធីនយោបាយ» របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨*, ខែសីហា ឆ្នាំ២០២៣, ទំព័រទី៦។

៦- ការអភិវឌ្ឍវិស័យកសិកម្ម ការអភិវឌ្ឍជនបទ ការជំរុញពាណិជ្ជកម្ម ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន និងការអភិវឌ្ឍទេសចរណ៍។

៧- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

៨- ការគ្រប់គ្រងធនធានទឹក និង ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។

៩- ការអភិវឌ្ឍទឹកស្អាត។

១០- ការអភិវឌ្ឍថាមពលអគ្គិសនី។

១១- ការអភិវឌ្ឍធនធានរ៉ែ។

១២- ការអភិវឌ្ឍវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកទេស និងព័ត៌មាន។

១៣- ការអភិរក្ស និងការអភិវឌ្ឍវប្បធម៌ និងសាសនា។

១៥- ការអភិវឌ្ឍការងារ និងប្រព័ន្ធគាំពារសង្គម។

១៤- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

១៦- ការលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ ការអភិវឌ្ឍយុវជន និងកីឡា។

១៧- ការពារជាតិ ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម។

១៨- ការពង្រឹង ពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ជំរុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក[75]។

### ៣.៣.៤. កម្មវិធីគោលនយោបាយអាទិភាពទាំង ៦

រាជរដ្ឋាភិបាលបានដាក់ចេញកម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ ដែលត្រូវចាប់ផ្តើមអនុវត្តភ្លាមនៅក្នុងឆ្នាំ២០២៣ ដូចខាងក្រោម៖

- **កម្មវិធីទី១:** ការផ្តល់ការថែទាំសុខភាព ឆ្ពោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល។
- **កម្មវិធីទី២:** ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស។
- **កម្មវិធីទី៣:** ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិ ជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន។
- **កម្មវិធីទី៤:** ការដាក់ចេញ និង ការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ។

---

[75] សៀវភៅ *«កម្មវិធីនយោបាយ» របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨*, ខែសីហា ឆ្នាំ២០២៣, ទំព័រ ៣៩។

- **កម្មវិធីទី៥:** ការដាក់ចេញនូវយន្តការសម្របសម្រួល និង ការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមទៅក្នុងសេដ្ឋកិច្ច សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ។
- **កម្មវិធីទី៦:** ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាព កសិកម្មនៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងជួយដល់គ្រួសារៗ កសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន និងការរៀបចំឱ្យមានសមាគមកសិករ នៅតាមទីជនបទ។

## ៣.៤. យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ (២០២៣ - ២០២៨)

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា នៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញ និងក្រោមម្លប់ដ៏ត្រជាក់នៃអង្គ ព្រះមហាក្សត្រ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះរាជាណាចក្រកម្ពុជា[76]។ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ រៀបចំឡើង ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ យុទ្ធសាស្ត្របញ្ចកោណ គឺជាយុទ្ធសាស្ត្រសម្លឹងទៅមុខសម្រាប់រយៈពេល ២៥ ឆ្នាំ ដែលត្រូវបានគិតគូរ ដាក់ចេញ និងអនុវត្ត ៥ ដំណាក់កាល បន្តបន្ទាប់ និងត្រូវបានតម្រង់ និងសម្របសម្រួលទៅតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៃនីតិកាលនីមួយៗ នៃរដ្ឋសភា។ ដំណាក់កាលនីមួយៗ នឹងត្រូវបានកែសម្រួល ដោយផ្អែកលើបរិការណ៍ជាក់ស្តែង នៅក្នុងប្រទេស, តំបន់ និងពិភពលោក ព្រមទាំងបទពិសោធន៍នៃការអនុវត្តពីដំណាក់កាលមុនៗ ដោយសម្លឹងទៅមុខ ឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅនៃការកសាងជាតិស្របតាម ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ។

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា និង យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ នឹងរួមគ្នាបំពេញតួនាទីជាក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ ២០២៣-២០២៨ ផែនការអភិវឌ្ឍតាមវិស័យ និងផែនការពាក់ព័ន្ធផ្សេងទៀត ដែលមានសូចនាករ និងក្របខណ្ឌពេលច្បាស់លាស់[77]។

### ៣.៤.១. បាវចនា, គោលដៅយុទ្ធសាស្ត្រ និងអាទិភាពគន្លឹះនៃយុទ្ធសាស្ត្រ

#### ៣.៤.១.១ បាវចនា

បាវចនា ៥ រួមមាន៖ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។

---

[76] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា*, ខែសីហា ឆ្នាំ២០២៣, ទំព័រ៦។

[77] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា*, ខែសីហា ឆ្នាំ២០២៣, ទំព័រ៥។

### ៣.៤.១.២. គោលដៅយុទ្ធសាស្ត្រ

គោលដៅយុទ្ធសាស្ត្រ ៥ រួមមានដូចខាងក្រោម៖

១. ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយភាពធន់ និងវិបត្តិនានា តាមរយៈ ការជំរុញសម្ទុះនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតចន្លល់ថ្មីៗនៃកំណើន; ការលើកកម្ពស់ការប្រគួតប្រជែង; និង រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប, ធានាស្ថិរភាពអត្រាប្តូរប្រាក់, ខិតខំបង្កើនទុនបម្រុងជាប្រចាំ, និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រួមបញ្ចូលទាំងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព។

២. បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណភាព, ជាពិសេស សម្រាប់យុវជន, តាមរយៈការពង្រឹងគុណភាពអប់រំ និង ការបណ្តុះបណ្តាលជំនាញ, ទាំងជំនាញរឹង និង ជំនាញទន់, ឱ្យស្របនឹងតម្រូវការ ក្នុងទីផ្សារការងារ, ការកែលម្អលក្ខខណ្ឌការងារប្រកបដោយជាសុកភាព; ការលើកកម្ពស់ផលិតភាព; ការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និង ធុរកិច្ច; និង ការជំរុញ និង ការទាក់ទាញការវិនិយោគ, ទាំងការវិនិយោគក្នុងស្រុក និង ការវិនិយោគផ្ទាល់ពីបរទេស។

៣. សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាទាបជាង ១០% និង បន្តឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា តាមរយៈ វិធានការបង្រួមវិសមភាពសេដ្ឋកិច្ច; ការអភិវឌ្ឍ និង កសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំ និង សង្គតិភាព; ការកាត់បន្ថយបន្ទុកជីវភាពប្រជាជន; និង ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព, ប្រសិទ្ធភាព និង បរិយាបន្ន។

៤. ពង្រឹងសមត្ថភាព អភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ; បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន; និង បន្តកិច្ចប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច, ការវិនិយោគ និង ពាណិជ្ជកម្ម។

៥. ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន ទៅនឹងការប្រែប្រួលអាកាសធាតុដោយធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ និង ពង្រឹងភាពធន់នៃប្រជាសាស្ត្រ; លើកកម្ពស់សមភាពយេនឌ័រ; គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព; បង្កើនហិរញ្ញប្បទានចីរភាព និង បៃតង នៅក្នុងបណ្តុំកម្ចីសរុប ដើម្បីបង្កើតលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកការវិនិយោគបៃតង និង សេដ្ឋកិច្ចបៃតង; ជំរុញការវិនិយោគសាធារណៈ ដែលមានភាពធន់នឹងអាកាសធាតុ និង មានការបញ្ចេញ

កាបូនទាប; និង ធានាចីរភាពបរិស្ថាន ព្រមទាំងត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ[78]។

**៣.៤.១.៣. អាទិភាពគន្លឹះ ៥**

ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកន្លងមករាជរដ្ឋាភិបាលបានកំណត់យកអាទិភាពគន្លឹះ ចំនួន៤ រួមមាន មនុស្ស ផ្លូវ ទឹក និង ភ្លើង ដើម្បីជំរុញការអភិវឌ្ឍប្រទេស។ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** កំណត់យកអាទិភាពគន្លឹះចំនួន៥ ដោយបន្ថែមបច្ចេកវិទ្យា និងបន្តយក **មនុស្ស** ជាអាទិភាពទី១ ហើយ**ផ្លូវ ទឹក ភ្លើង** និង **បច្ចេកវិទ្យា** ជាអាទិភាពបន្តបន្ទាប់តាមលំដាប់។ ជារួម អាទិភាពគន្លឹះទាំង ៥ ក្នុងទម្រង់ «បញ្ចកោណយុទ្ធសាស្ត្រ» ត្រូវបានរៀបចំ ដូចខាងក្រោម៖

- បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស
- បញ្ចកោណទី២៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតភាពប្រកួតប្រជែង
- បញ្ចកោណទី៣៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ
- បញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន
- បញ្ចកោណទី៥៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល[79]។

**៣.៤.២. រចនាសម្ព័ន្ធ**

រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រនេះមាន៖

១. **ស្នូល**នៃយុទ្ធសាស្ត្រគឺៈ ការកែទម្រង់ និង ការពង្រឹងអភិបាលកិច្ច។

២. **បរិស្ថានគ្របដណ្តប់**សម្រាប់ធានាបរិយាកាសអំណោយផល ដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល។

៣. **បញ្ចកោណយុទ្ធសាស្ត្រ**សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និង វឌ្ឍនភាពសង្គម។

**៣.៥.២.១. ស្នូល**

ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ផ្តោតលើការកែទម្រង់ និង ការពង្រឹងអភិបាលកិច្ច, និង ការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំ, ការគ្រប់គ្រង និង ការចាត់ចែងការងារប្រទេសជាតិ, ពិសេស ការធានានិរន្តភាពតួនាទី និង ដំណើរការរដ្ឋបាលសាធារណៈដោយយកចិត្តទុកដាក់លើផលប្រយោជន៍ប្រជាជន, ព្រមជាមួយនឹងការកសាង និង ការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។

[78] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា*, ខែសីហា ឆ្នាំ២០២៣, ទំព័រ ៣១។

[79] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា*, ខែសីហា ឆ្នាំ២០២៣, ទំព័រ ៣៣។

**ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ មានមុំចំនួន ៥ រួមមានដូចខាងក្រោម៖**

- មុំទី១. ការពង្រឹង និង ការកែទម្រង់ស្ថាប័ន៖

គោលដៅយុទ្ធសាស្ត្រ គឺកសាងរដ្ឋបាលសាធារណៈ ដែលមានសម្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។

- មុំទី២. ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ៖

គោលដៅជាយុទ្ធសាស្ត្រ គឺកសាងធនធានមនុស្ស ប្រកបដោយសមត្ថភាព, ជំនាញ, ឆន្ទៈម្ចាស់ការ និង ក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតួនាទី និង ការទទួលខុសត្រូវ។

- មុំទី៣. ការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ៖

គោលដៅយុទ្ធសាស្ត្រ គឺលើកម្ពស់ និងការពង្រឹងភាពស្អាតស្អំ, ភាពសុចរិត និង ជំនឿទុកចិត្តចំពោះរដ្ឋបាលសាធារណៈ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយ ប្រសិទ្ធភាព, បរិយាបន្ន និង ចីរភាព។

- មុំទី៤. ការលើកកម្ពស់ និង ការពង្រឹង ប្រសិទ្ធភាពនៃច្បាប់ និង ប្រព័ន្ធយុត្តិធម៌៖

គោលដៅយុទ្ធសាស្ត្រ គឺការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌ក្នុងសង្គម, និង ការពង្រឹងជំនឿទុកចិត្តពីសាធារណជនមកលើវិស័យយុត្តិធម៌ដែលជាកត្តារួមចំណែកដ៏សំខាន់ក្នុងការធានាថែរក្សាស្ថិរភាពសង្គម, សណ្តាប់ធ្នាប់សាធារណៈ និង ភាពសុខដុមរមនា ក្នុងសង្គមជាតិ។

- មុំទី៥. ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច៖

គោលដៅជាយុទ្ធសាស្ត្រ គឺពង្រឹងជំនឿទុកចិត្តរបស់តួអង្គពាក់ព័ន្ធមកលើវិស័យឯកជន និង ធុរកិច្ចតាមរយៈការជំរុញឱ្យមានអភិបាលកិច្ចល្អ ក្នុងវិស័យឯកជន និង ធុរកិច្ច[80]។

### ៣.៤.២.២. បរិស្ថានគ្របដណ្តប់

បរិស្ថានគ្របដណ្តប់កំណត់នូវក្របខណ្ឌពេញលេញ និង គ្រប់ជ្រុងជ្រោយ ដើម្បីធានាការសម្រេចបាននូវអាទិភាពគោលនយោបាយនៃ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។

**បរិស្ថានគ្របដណ្តប់មានមុំចំនួន ៥ ដូចខាងក្រោម៖**

- មុំទី១. ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ៖

គោលដៅយុទ្ធសាស្ត្រ គឺបន្តការពារឱ្យបានជាដាច់ខាត នូវសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈដែលកត្តាទាំងនេះជាបុរេលក្ខណៈមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

- មុំទី២. ការប្រកាន់ភ្ជាប់នូវគោលនយោបាយឯករាជ្យ, ផ្អែកលើច្បាប់ និង ឈ្លាសវៃ៖

---

[80] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា,* ខែសីហា ឆ្នាំ២០២៣, ទំព័រ៣៥ -៤១។

គោលដៅយុទ្ធសាស្ត្រ គឺការបន្តពង្រឹងការអនុវត្តនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ ក្នុងកិច្ចការពារ និង ក្នុងការជំរុញបង្កើនផលប្រយោជន៍ស្នូលរបស់ជាតិ; និង កសាងមិត្តភាព និង កិច្ចសហប្រតិបត្តិការប្រសើរជាមួយប្រទេសទាំងអស់នៅលើសកលលោក និង អង្គការអន្តរជាតិនានា; ព្រមទាំងចូលរួមយ៉ាងសកម្មចំពោះបុព្វហេតុសន្តិភាព, ស្ថិរភាព, សន្តិសុខ និង វិបុលភាព ក្នុងតំបន់ និង សកលលោក ស្របតាមអភិក្រម **"រក្សាចាស់, បង្កើតថ្មី"**។

- មុំទី៣. ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាលក្ខណចាំបាច់ សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន, ភាពធន់ និង ចីរភាព។

- មុំទី៤. ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន និង ស័ក្តិសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ការបន្តលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ និង ការបន្តពង្រឹងភាពជាដៃគូជាមួយគ្រប់តួអង្គអភិវឌ្ឍន៍ គឺជាភាពចាំបាច់សម្រាប់បង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយបរិយាបន្ន, ភាពធន់ និង ចីរភាព។

- មុំទី៥. ការបន្តធ្វើសមាហរកម្មស៊ីជម្រៅ ទៅក្នុងតំបន់ និងសកលលោក

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចស៊ីជម្រៅ ទៅក្នុងតំបន់ និង សកលលោក បង្កើតកាលានុវត្តភាពក្នុងការជំរុញ និង គាំទ្រ ពាណិជ្ជកម្មអន្តរជាតិ និង ការទាក់ទាញការវិនិយោគ, ក៏ដូចជាការចូលរួមកាន់តែជ្រៅ ទៅក្នុងខ្សែសង្វាក់តម្លៃ និង ការផ្គត់ផ្គង់ នៃតំបន់ និង ជាសកល សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ប្រកបដោយចីរភាព[81]។

### ៣.៤.២.៣. បញ្ចកោណយុទ្ធសាស្ត្រទាំង ៥

❖ **បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស:**

- មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មុំទី២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- មុំទី៣. ការលើកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន
- មុំទី៤. ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង

[81] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា,* ខែសីហា ឆ្នាំ២០២៣, ទំព័រ៤២-៥០។

- មុំទី៥. ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌, សមធម៌ និង បរិយាបន្ន។

❖ **បញ្ចកោណទី២៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតភាពប្រកួតប្រជែង:**

- មុំទី១. ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច
- មុំទី២. ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើតប្រសិទ្ធិភាពនៃវិស័យដឹកជញ្ជូន និង ឡូជិស្ទីក, វិស័យ ថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល
- មុំទី៣. ការកែលម្អបរិយាកាសធុរកិច្ច និង ការវិនិយោគ
- មុំទី៤. ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស
- មុំទី៥. ការធ្វើនវានុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ។

❖ **បញ្ចកោណទី៣៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ**:

- មុំទី១. ការអភិវឌ្ឍទីផ្សារការងារ
- មុំទី២. ការលើកម្ពស់សហគ្រាសធុន តូច និង មធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និង ការអភិវឌ្ឍសេដ្ឋកិច្ច ក្រៅប្រព័ន្ធ
- មុំទី៣. ការពង្រឹងភាពជាដៃគូសាធារណៈ និងវិស័យឯកជន
- មុំទី៤. ការពង្រឹងការប្រកួតប្រជែង
- មុំទី៥. ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

❖ **បញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន**:

- មុំទី១. ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធនប្រជាសាស្ត្រ និង ការលើកកម្ពស់ សមភាពយេនឌ័រ
- មុំទី២. ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព
- មុំទី៣. ការលើកស្ទួយកសិកម្ម និង ការអភិវឌ្ឍជនបទ
- មុំទី៤. ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម
- មុំទី៥. ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំង ការលើកកម្ពស់សេដ្ឋកិច្ចបៃតង។

❖ **បញ្ចកោណទី ៥ ៖ ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល:**

- មុំទី១. ការកសាងរដ្ឋាភិបាលឌីជីថល និង ពលរដ្ឋឌីជីថល

- មុំទី២. ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីថល, ពាណិជ្ជកម្មឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តឌីជីថល
- មុំទី៣. ការកសាង និង ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- មុំទី៤. ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល
- មុំទី៥. ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ[82]។

## ៣.៥. ការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

### ៣.៥.១. គោលការណ៍នៃការណែនាំរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធ

- ការពង្រឹង និងការរៀបចំឱ្យបានរៀបរយនូវរចនាសម្ព័ន្ធដែលមានស្រាប់៖ ក្រសួង ស្ថាប័នត្រូវពិនិត្យ និងរៀបចំរចនាសម្ព័ន្ធដែលមានស្រាប់ឱ្យបានរៀបរយ ដោយប្រើឱ្យអស់នូវលទ្ធភាព និងសក្តានុពលក្នុងការកែលម្អការអនុវត្តមុខងារដែលជាសមត្ថកិច្ចរបស់ខ្លួន ការរៀបចំរចនាសម្ព័ន្ធឱ្យបានសមស្របក្នុងការគាំទ្រអនុវត្តមុខងារ និងការរៀបចំលំហូរការងារក្នុងក្រសួង ស្ថាប័ន ព្រមទាំងការកំណត់គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការបំពេញការងារ។
- រក្សាចំនួនអង្គភាព៖ ការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន មិនត្រូវនាំឱ្យមានការបង្កើតចំនួនអង្គភាព ទោះក្នុងកម្រិតណាមួយក៏ដោយ ឬបន្ថែមទម្ងន់បែបបទ និងនីតិវិធីដែលមានស្រាប់នៅតាមអង្គភាពរបស់ក្រសួង ស្ថាប័នឡើយ។ ក្រសួង ស្ថាប័ន ត្រូវពិនិត្យឡើងវិញរចនាសម្ព័ន្ធមានស្រាប់ដែលមិនឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីធ្វើការកែសម្រួលឬច្របាច់បញ្ចូលគ្នាឬលុបចោល។
- ការរក្សានូវកម្រិតឋានៈអង្គភាព៖ ការរៀបចំ និងកែសម្រួលរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួង ស្ថាប័ន មិនត្រូវធ្វើការដំឡើងកម្រិតឋានៈអង្គភាព ដែលជាហេតុនាំឱ្យមានការកើនរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។
- ការធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្ស និងថវិកា៖ ការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ត្រូវអនុវត្តដើម្បីធានាឱ្យបាននូវការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស និងថវិកាប្រកបដោយប្រសិទ្ធិភាពខ្ពស់។

[82] សៀវភៅ *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១», រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា,* ខែសីហា ឆ្នាំ២០២៣, ទំព័រ៣១-៣៣។

### ៣.៥.២. ការរៀបចំ ការបង្កើត និងការកែសម្រួលរចនាសម្ព័ន្ធ

- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន រួមទាំងការបង្កើត និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ត្រូវអនុវត្តដោយផ្អែកលើលក្ខណៈនៃការពិនិត្យឡើងវិញជារួមនូវមុខងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងរចនាសម្ព័ន្ធដែលមានស្រាប់រួមទាំងរចនាសម្ព័ន្ធចំណុះក្រសួង រដ្ឋលេខាធិការដ្ឋាន និងរចនាសម្ព័ន្ធរបស់ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈ-កម្មាធិការ គណៈកម្មការ និងយន្តការនានា ដែលក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុក។
- ការបង្កើត និងកែសម្រួលក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ ឬអង្គភាពថ្មីដើម្បីបំពេញបេសកកម្ម និងមុខងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្រសួង ស្ថាប័ននោះត្រូវប្រើប្រាស់រចនាសម្ព័ន្ធគ្រប់គ្រងដែលមានស្រាប់របស់ក្រសួង ស្ថាប័ន ធ្វើជាលេខាធិការដ្ឋាន ដោយមិនត្រូវបង្កើតឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងអចិន្ត្រៃយ៍ថ្មីឡើយ លើកលែងស្ថាប័ន ក្រុមប្រឹក្សា គណៈ-កម្មាធិការ និងយន្តការនានាដែលត្រូវបង្កើតអនុលោមបទបញ្ញត្តិដែលមានកំណត់ក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័នត្រូវធ្វើការពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីធានាឱ្យការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មានដំណើការប្រកដោយប្រសិទ្ធភាពខ្ពស់ ឆ្លើយតបនឹងខ្លឹមសារនៃសារាចរស្តីពីការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

### ៣.៥.៣. បែបបទ និងនីតិវិធីនៃការពិគ្រោះយោបល់

- ក្រសួង ស្ថាប័នត្រូវលើកសំណើនៃការរៀបចំ និងកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនមកក្រសួងមុខងារសាធារណៈដើម្បីពិគ្រោះយោបល់អនុលោមបទបញ្ញត្តិដែលមានកំណត់ក្នុងអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- បន្ទាប់ពីបានឆ្លងការពិគ្រោះយោបល់ខាងលើរួច សំណើរបស់ក្រសួង ស្ថាប័នត្រូវដាក់ឆ្លងកិច្ចប្រជុំនានាដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទទួលបានការពិនិត្យ និងផ្តល់យោបល់ពីគ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន
- ទីស្តីការគណៈរដ្ឋមន្ត្រី លើកសំណើដែលបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់រួចរាល់ ជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច[83]។

[83] សារាចរលេខ ០៨ សរ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

## ៣.៦. ការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ (៥ សីហា ២០២៤)

គម្រោងព្រែកជីកហ្វូណនតេជោ គឺជាគំនិតផ្តួចផ្តើមប្រកបដោយចក្ខុវិស័យដ៏វែងឆ្ងាយបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ហើយបាននឹងកំពុងអនុវត្តដោយរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីបន្សល់ទុកជាកេរមរតកប្រវត្តិសាស្ត្រសម្រាប់កូនចៅជំនាន់ក្រោយរាប់ពាន់ឆ្នាំទៅមុខ។ គម្រោងព្រែកជីកហ្វូណនតេជោនឹងផ្តល់ផលប្រយោជន៍ដ៏មហាសាលដល់សង្គម-សេដ្ឋកិច្ចកម្ពុជា ដូចជា ពង្រីកការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ ចំណេញចម្ងាយផ្លូវ ពេលវេលា និងថ្លៃដឹកជញ្ជូនប្រកបដោយភាពប្រកួតប្រជែងត្រង់ទៅសមុទ្របង្កើនវិសាលភាពនៃប្រព័ន្ធស្រោចស្រព និងរំដោះទឹកជំនន់ ជួយពង្រឹងនិងបង្កើនផលិតភាពនៃការដាំដុះនៅភាគនិរតីទទួលបានផលពីការនេសាទ និងពីវារីវប្បកម្ម ព្រមទាំងជំរុញវិស័យទេសចរណ៍ និងវិនិយោគ ជាពិសេសការបង្កើតតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម និងការកែច្នៃនាំចេញ។ គម្រោងនេះ ត្រូវបានប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេស សូម្បីខ្មែរមាននិន្នាការប្រឆាំងរាជរដ្ឋាភិបាលកម្ពុជា កំពុងរស់នៅក្រៅប្រទេសក៏បានគាំទ្រយ៉ាងច្រើនកុះករ។

ដើម្បីអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានធ្វើការណែនាំដូចតទៅ៖

១. ប្រកាសថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ជាថ្ងៃអបអរសាទរផ្លូវការនៃព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ។

២. គ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និងឯកជន ព្រមទាំងជនរួមជាតិគ្រប់រូបទូទាំងព្រះរាជាណាចក្រកម្ពុជា រួមគ្នាធ្វើការវាយគង ជួង រគាំង ទូងស្គរ ទះប៉ោត និងគោះត្រឡោក តាមគ្រប់មធ្យោបាយដែលខ្លួនមាន នាវេលាម៉ោង៩:០០នាទីព្រឹក នៅគ្រប់ទីកន្លែងសាធារណៈសំខាន់ៗ ទីស្តីការក្រសួង ស្ថាប័នថ្នាក់ជាតិ អង្គភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រប់វត្តអារាម មណ្ឌលវិបស្សនា អាស្រម សាលាបុណ្យ វិហារសាសនា ស្នាក់ការស៊ូរ៉ាវ សាលារៀនរដ្ឋនិងឯកជន និងទីប្រជុំសហគមន៍ យ៉ាងច្រើនកុះករ ភ្លៀវភ្លា និងអធិកអធម ជាទីមោទនៈ។

៣. គ្រប់រដ្ឋបាលរាជធានី ខេត្ត រៀបចំទីកន្លែងយ៉ាងសមរម្យ សម្រាប់រៀបចំពិធីអបអរសាទរ ដោយរៀបចំឱ្យមានការអុជកាំជ្រួច នាវេលាម៉ោង ១៩:០០នាទីយប់។

៤. ក្រសួងព័ត៌មាន ណែនាំឱ្យប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជន ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីអត្ថប្រយោជន៍នៃគម្រោងព្រែកជីកហ្វូណនតេជោ និងទស្សនីយភាពអបអរសាទរនានាពាក់ព័ន្ធនឹងការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ[84]។

❖ **លក្ខណៈសម្បត្តិរបស់ព្រែកជីកហ្វូណនតេជោះ**

ទី១- ត្រូវបានតភ្ជាប់ប្រព័ន្ធដៃទន្លេមេគង្គ និងផ្លូវសមុទ្រ ប្រវែងសរុបប្រមាណ ១៨០ គីឡូម៉ែត្រ។

ទី២- គ្រោងចំណាយថវិកាសរុបប្រមាណ ១ ៧០០ លានដុល្លារអាមេរិក ជាប្រភេទគម្រោងវិនិយោគ BOT (Build-Operate-Transfer)។

ទី៣- ទីតាំងគឺចាប់ពីព្រែកតាកែវ ឆ្លងកាត់ព្រែកតាឯក ចូលតាមព្រែកតាហ៊ីង និងបន្តរហូតដល់សមុទ្រខេត្តកែប។

ទី៤- ឆ្លងកាត់ខេត្តចំនួន ៤ រួមមាន ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប។

ទី៥- តាមការប៉ាន់ស្មាន មានចំនួនប្រជាជនសរុបប្រមាណ ១លាន៦សែននាក់ រស់នៅអមសងខាងព្រែកជីកនេះ និងទទួលផលពីព្រែកជីកនេះ។

ទី៦- ព្រែកជីកនេះ មានទទឹងខាងលើ ១០០ម៉ែត្រ ទទឹងខាងក្រោម ៨០ម៉ែត្រ និងជម្រៅ ៥,៤ម៉ែត្រ (បញ្ជាក់៖ ជម្រៅនាវា ៤,៧ម៉ែត្រ)[85]។

---

[84] សារាចរលេខ ១០ សរ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤។

[85] នគរវត្ត, *ឈ្វេងយល់អំពី ព្រែកជីកហ្វូណនតេជោ!*, ប្រភពឯកឧត្តម គួច វ៉េងស្រ៊ុន, អាចរកបាននៅ http://nokorwatnews.com/archives/1117294, (ចូលទស្សនាថ្ងៃទី ២៥ កក្កដា ឆ្នាំ២០២៤)។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវកន្លងមកលើប្រធានបទស្តីពី "**គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧**" រួចមកសង្កេតឃើញថា ប្រទេសកម្ពុជាបានឆ្លងកាត់ការដឹកនាំរបស់រាជរដ្ឋាភិបាលចំនួន ៧ នីតិកាលរួចមកហើយ បើគិតចាប់តាំងពីឆ្នាំ១៩៩៣ មក។ ដោយនីតិកាលទី១ ការរៀបចំការបោះឆ្នោតត្រូវបានជួយជ្រុំជ្រែងដោយ "អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា" នៅថ្ងៃទី ២៣-២៨ ខែឧសភា ក្រោយការបោះឆ្នោតជាលទ្ធផលរបបសហនាយករដ្ឋមន្ត្រីត្រូវបានកើតឡើង និងបានចាត់ចែងពង្រាង និងអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ នីតិកាលទី២ កម្ពុជាបានបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយខ្លួនឯង ហើយបានរៀបចំការបោះឆ្នោតជាសកលនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ជាលទ្ធផលគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាល។

ការរៀបចំបោះឆ្នោតដោយអ៊ុនតាក់មិនបានបញ្ចប់សង្គ្រាមនៅកម្ពុជាទេ ផ្ទុយទៅវិញ បានបន្សល់នូវប្រទេសមួយ មានតំបន់គ្រប់គ្រង២ ប៉ុន្តែ ក្រោមយុទ្ធសាស្ត្រឌីហ្វីដ និងគោលនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចតេជោ ហ៊ុន សែន** ទើបកម្ពុជាអាចរកភព នៃសន្តិភាពឃើញ គឺការបញ្ចប់សង្គ្រាមទាំងស្រុង ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ។ ដោយគុណបំណាច់ដ៏ធំធេងនៃស្មារតីស្នេហាជាតិមាតុភូមិ ក្នុងការស្វែងរកសុខសន្តិភាពជូនប្រជាជនរបស់សម្តេចតេជោ បែបនេះហើយទើបធ្វើឱ្យប្រជាពលរដ្ឋខ្មែរគោរពដឹងគុណ និងបានបន្តបោះឆ្នោតគាំទ្រជូនគណបក្សប្រជាជនកម្ពុជា ចាប់តាំងពីនីតិកាលទី៣ រហូតមកដល់នីតិកាលទី៧ បច្ចុប្បន្ននេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៧ ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងជាកូនប្រុសច្បងដ៏មានឥទ្ធិពលម្នាក់របស់សម្តេចតេជោ។

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧នេះ កើតឡើងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដែលបានប្រព្រឹត្តទៅដោយរលូន និងស្ថិតក្រោមក្រសែភ្នែករបស់អ្នកសង្កេតការណ៍ជាតិជិត៩ម៉ឺននាក់ និងអ្នកសង្កេតការណ៍អន្តរជាតិមកពី ៦៥ប្រទេស និងស្ថាប័នអន្តរជាតិ។ ដោយមានការចូលរួមប្រកួតប្រជែងពីគណបក្សនយោបាយចំនួន ១៨ ជាលទ្ធផលបង្ហាញថាមានតែគណបក្សចំនួនពីរប៉ុណ្ណោះដែលទទួលអាសនៈក្នុងរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជាឈ្នះដាច់ ដោយទទួលអាសនៈក្នុងរដ្ឋសភាបាន ចំនួន ១២០អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ៥អាសនៈ ។

សមាសភាពរាជរដ្ឋាភិបាលនា នីតិកាលទី ៧ រួមមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី អមដោយឧបនាយករដ្ឋមន្ត្រីចំនួន ១១ រូប ទេសរដ្ឋមន្ត្រីចំនួន ២៣ រូប និងរដ្ឋមន្ត្រីតាមបណ្តាក្រសួង ស្ថាប័នចំនួន ៣០ រូប។ ជារួមនាយករដ្ឋមន្ត្រីមានភារកិច្ចដឹកនាំការងាររួមរបស់គណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ព្រមទាំងទទួលបន្ទុកដោយឡែកក្នុងការទំនាក់ទំនងផ្ទាល់ជាមួយព្រះមហាក្សត្រ សម្រាប់កិច្ចការរបស់រាជរដ្ឋាភិបាល និងដឹកនាំបញ្ជាផ្ទាល់លើ

បញ្ជាការរដ្ឋានអង្គរក្ស, បញ្ជាការរដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ រីឯឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រីលើវិស័យនានា តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។ ចំណែកឯទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសជួយនាយករដ្ឋមន្ត្រីលើកិច្ចការនានា និងទទួលបន្ទុកអនុវត្តការងារនានាតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។ ម្យ៉ាងទៀត រដ្ឋមន្ត្រីមានតួនាទីភារកិច្ចក្នុងការដឹកនាំក្រសួង ស្ថាប័ន និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន។

ជាការពិតជាក់ស្តែងណាស់ កម្ពុជាបច្ចុប្បន្ន ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ កំពុងតែស្ថិតនៅលើមាគ៌ានៃការអភិវឌ្ឍប្រកបដោយក្តីសង្ឃឹម។ នៅក្នុងឆ្នាំ២០៥០ ខាងមុខ រាជរដ្ឋាភិបាលមានមហិច្ឆតាចង់លើកស្ទួយមោទនភាពជាតិ ឱ្យឈានឡើងដូចសម័យអង្គរ និងមានវិបុលភាពឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដែលត្រូវអនុវត្តជា៥ ដំណាក់កាលបន្តបន្ទាប់។ ជាការចាប់ផ្តើមនៃមាគ៌ានេះ រាជរដ្ឋាភិបាល នីតិកាលទី៧ បានដាក់ចេញ "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១" ដើម្បីសម្រេចនូវគោលដៅមហិច្ឆតារបស់ខ្លួន។ រាជរដ្ឋាភិបាលបានសម្រេចកំណត់យកនូវ **អាទិភាពគន្លឹះ ចំនួន ៥** សម្រាប់ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ នេះគឺ៖ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**។

សរុបសេចក្តីមក រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ពិតជាបានប្រសូត្រឡើង និងបានដឹកនាំគ្រប់គ្រងប្រទេសកម្ពុជាក្រោមរូបភាពនៃលទ្ធិប្រជាធិបតេយ្យយ៉ាងពិតប្រាកដមែន។ មិនត្រឹមតែប៉ុណ្ណោះរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្ពង់ខ្ពស់នៅក្នុងការការពារសន្តិភាព និងការអភិវឌ្ឍជាតិមាតុភូមិកម្ពុជា។ ជាភស្តុតាងដែលយើងជាពលរដ្ឋមើលឃើញច្បាស់នឹងភ្នែកនៃសមិទ្ធផលការអភិវឌ្ឍដ៏ធំធេងមួយគឺ គម្រោងព្រែកជីកហ្វូណនតេជោ ដែលត្រូវបានបើកការដ្ឋានសាងសង់នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ដែលជាគំនិតផ្តួចផ្តើមប្រកបដោយចក្ខុវិស័យដ៏វែងឆ្ងាយបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ហើយបាននឹងកំពុងអនុវត្តដោយរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីបន្សល់ទុកជាកេរមរតកប្រវត្តិសាស្ត្រសម្រាប់កូនចៅជំនាន់ក្រោយរាប់ពាន់ឆ្នាំទៅមុខ។ ដោយយោងតាមការដឹកនាំតាមបែបលទ្ធិប្រជាធិបតេយ្យ ស្មារតីស្នេហាជាតិដែលបានស្ថាបនាសុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ របស់រាជរដ្ឋាភិបាល ហេតុដូច្នេះហើយ ទើបប្រជាជនកម្ពុជាមិនអាចខ្វះបានឡើយនូវវត្តមានរបស់រាជរដ្ឋាភិបាល ដែលមកពីគណបក្សប្រជាជនកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទខាងលើដោយយកចិត្តទុកដាក់រួមមក យើងខ្ញុំបានសង្កេតឃើញថា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាកន្លងមក ប្រទេសជាតិមានការអភិវឌ្ឍលើគ្រប់វិស័យគួរឱ្យកត់សម្គាល់យ៉ាងពិតប្រាកដមែន បើប្រៀបធៀបកាលពីអំឡុង ៣ ទសវត្សមុន។ យ៉ាងណាមិញ នៅក្នុងនីតិកាលទី៧នេះ រាជរដ្ឋាភិបាលមានការបែងចែក និងរៀបចំគោលនយោបាយក្នុងការអភិវឌ្ឍសង្គមយ៉ាងច្បាស់លាស់ មានចក្ខុវិស័យដ៏វែងឆ្ងាយ និងមានការយកចិត្តទុកដាក់ខ្ពស់លើការកែទម្រង់លើវិស័យមុខងារសាធារណៈ ដើម្បីពង្រឹងធនធានមនុស្សក្នុងការចូលរួមដំណើរអភិវឌ្ឍប្រទេសជាតិជាមួយរាជរដ្ឋាភិបាល។ ក្នុងន័យនេះដើម្បីចូលរួមជំរុញការអភិវឌ្ឍផែនការ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នេះ ក្នុងការគ្រប់គ្រង និងការដឹកនាំឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវសូមលើកយកអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- រាជរដ្ឋាភិបាលគប្បីបន្តខិតខំប្រឹងប្រែងការពារធានាឱ្យបាននូវសុខសន្តិភាពជាតិ ដែលដើរតួនាទីយ៉ាងសំខាន់ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍនសង្គម-សេដ្ឋកិច្ចកម្ពុជា
- គប្បីបន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសជិតខាង ក្នុងការរួមរស់ដោយសន្តិសហវិជ្ជមាន, បន្តពង្រឹង និងពង្រីកនូវចំណងមិត្តភាពជាមួយសកលលោកដើម្បីទាក់ទាញអ្នកវិនិយោគទុនបរទេសមកបណ្តាក់ទុននៅកម្ពុជា
- នៅបន្តជំរុញ និងយកចិត្តទុកដាក់លើវិស័យអប់រំដើម្បីបណ្តុះបណ្តាលធនធានមនុស្សរបស់កម្ពុជាប្រកបដោយគុណភាព គុណធម៌ សីលធម៌ ភាពថ្លៃថ្នូរ និងភាពជាគំរូ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- គប្បីបន្តធ្វើការណែនាំដល់ក្រសួង ស្ថាប័ននានា ក្នុងការកែសម្រួល ការអនុវត្តតួនាទីភារកិច្ចឱ្យចំគោលដៅ ជៀសវាងការបំពេញ និងការអនុវត្តមុខងារជាន់គ្នាដែលនាំឱ្យមានភាពរអាក់រអួល
- មួយវិញទៀត បន្តយកចិត្តទុកដាក់បន្ថែមទៀតលើវិស័យបច្ចេកវិទ្យា ជាពិសេសពង្រឹង និងអភិវឌ្ឍន៍ការប្រើប្រាស់បច្ចេកវិទ្យាដល់ថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយ រាជរដ្ឋាភិបាលឌីជីថល ប្រជាជនឌីជីថល។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីសន្តិភាព និងការអភិវឌ្ឍជូនប្រជាជាតិរបស់ខ្លួន។ ជាទស្សនៈផ្ទាល់ខ្លួនក្នុងនាមជាអ្នកស្រាវជ្រាវយល់ឃើញថា ការដែលប្រទេសជាតិមួយមានរាជរដ្ឋាភិបាលដឹកនាំតាមបែបលទ្ធិប្រជាធិបតេយ្យដូចកម្ពុជាសព្វថ្ងៃនេះ ជាមហាភ័ព្វសំណាងខ្លាំងណាស់សម្រាប់

ប្រជាជនខ្មែរ។ ដូចនេះដើម្បីបន្តជីវភាពរស់នៅក្នុងរបបលទ្ធិប្រជាធិបតេយ្យ និងដើម្បីឱ្យប្រជាជាតិខ្មែរកាន់តែខ្លាំងនោះ ក្នុងនាមយើងជាពលរដ្ឋខ្មែរគប្បីធ្វើខ្លួនជាពលរដ្ឋល្អដូចខាងក្រោម៖

- ត្រូវនិយាយថាទេចំពោះការចូលរួមក្រោមរូបភាពណាមួយក្នុងការធ្វើបដិវត្តន៍ពណ៌ ព្រោះវានឹងនាំមកនូវការបែកបាក់សាមគ្គីជាតិ មិនផ្តល់ផលប្រយោជន៍អ្វីទាល់តែសោះដល់សង្គមជាតិ
- តែត្រូវទៅចូលរួមបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ដើម្បីធ្វើជាម្ចាស់ជោគវាសនាប្រទេសជាតិ
- ត្រូវខិតខំរៀនសូត្រ ព្រោះការសិក្សារៀនសូត្រគឺជាអាវុធដ៏មុតស្រួចបំផុត ក្នុងការប្រយុទ្ធតស៊ូជាមួយនឹងភាពក្រីក្រ និងភាពទុច្ចរិត
- រក្សាទំនៀមទម្លាប់ប្រពៃណី និងវប្បធម៌ឱ្យបានគង់វង្សស្ថិតស្ថេរ
- ចូលរួមគោរព និងអនុវត្តច្បាប់ជាតិឱ្យបានគ្រប់ៗគ្នា
- គោរព និងការពារសិទ្ធិមនុស្ស លើកកម្ពស់សិទ្ធិនារី ព្រោះ «នារីជា មាតានៃពិភពលោក»
- ចូលរួមសម្អាតបរិស្ថាន រក្សាអនាម័យ និងការពារសុខភាពផ្ទាល់ខ្លួន
- ត្រូវខិតខំស្វែងរកទ្រព្យសម្បត្តិ កាលបើមានទ្រព្យស្តុកស្តម្ភហើយ ត្រូវចេះចែករំលែកដល់អ្នកដែលក្រីក្រ ពីព្រោះថាមនុស្សយើងនេះ មិនអាចយកអ្វីទៅបានទាំងអស់នៅថ្ងៃចុងបញ្ចប់នៃជីវិត
- ត្រូវផ្តល់ក្តីសេចក្តីស្រឡាញ់ មេត្តា ករុណា ដល់បណ្តាជនទាំងឡាយនៅជុំវិញខ្លួន ក៏ព្រោះថាយើងចង់បានសេចក្តីសុខប៉ុនណា គេក៏ចង់បានប៉ុណ្ណោះដែរ
- ត្រូវសម្លាប់សត្រូវដោយ ប្រែទៅជាមិត្ត។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ❖ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- ❖ ច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា ៨២ ថ្មី មាត្រា ១០៦ ថ្មី (មួយ) មាត្រា១៩៩ ថ្មី និង មាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ, លេខ នស/រកម/១១២១/០១៦ , ប្រកាសឱ្យប្រើនៅ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១។
- ❖ ច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា ១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ, លេខ នស/រកម/០៨២២/ ០០៧, ប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២។
- ❖ ច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, លេខ ០២/នស/៩៤, ប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤។
- ❖ ច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, លេខ នស/រកម/០៦១៨/០១២, ប្រកាសឱ្យប្រើ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។
- ❖ ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- ❖ ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១១០ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការត្រាស់បង្គាប់ផ្ដល់ គោរមងារដ៏ឧត្ដុងឧត្ដមខ្ពង់ខ្ពស់បំផុតជូននាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជា «**សម្ដេចមហាបវរធិបតី**»។
- ❖ ព្រះរាជក្រឹត្យលេខ  នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញ បន្ថែមសមាសភាពរាជរដ្ឋាភិបាល។
- ❖ សេចក្ដីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។
- ❖ សារាចរលេខ ០៨ សរ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធ របស់ក្រសួង ស្ថាប័ន។
- ❖ សារាចរលេខ ១០ សរ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ ស្ដីពីការអបអរសាទរការបើកការដ្ឋានសាងសង់ ព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤។

## ២. សៀវភៅ


- ទីស្តីការគណៈរដ្ឋមន្ត្រី. ២០០៤. *សមិទ្ធផលសំខាន់ៗដែលសំរេចបានដោយរាជរដ្ឋាភិបាលកម្ពុជាសំរាប់នីតិកាលទី២ នៃរដ្ឋសភា (១៩៩៨-២០០៣)*, ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការណៈរដ្ឋមន្ត្រី។
- ទីស្តីការគណៈរដ្ឋមន្ត្រី. ២០០៨. *របាយការណ៍ស្តីពី សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល ៤ឆ្នាំ (២០០៤-២០០៧)*. ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការគណៈរដ្ឋមន្ត្រី។
- ទីស្តីការគណៈរដ្ឋមន្ត្រី. ២០១៣. *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០០៨-២០១២*. ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការគណៈរដ្ឋមន្ត្រី។
- ទីស្តីការគណៈរដ្ឋមន្ត្រី. ២០១៨. *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០១៣-២០១៧*. ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការគណៈរដ្ឋមន្ត្រី។
- ទីស្តីការគណៈរដ្ឋមន្ត្រី អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស. ២០១៣. *សៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣*។
- រាជរដ្ឋាភិបាល. ២០២៣. *«កម្មវិធីនយោបាយ» របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨*។
- រាជរដ្ឋាភិបាល. ២០២៣. *«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»*។
- សាស្ត្រាចារ្យ ជុំ អ៊ឹម. ២០១២. *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា*. ភ្នំពេញ៖ បោះពុម្ពលើកទី១ ដោយរោងពុម្ពសុខចេង។
- សាស្ត្រាចារ្យ ហៀង សាង. ២០២១. *នីតិរដ្ឋបាលទូទៅ*. ភ្នំពេញ៖ បោះពុម្ពលើកទី៦ ដោយរោងពុម្ពស៊ីហេង។
- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា. ២០២១. *សៀវភៅស្តីពីសភាកម្ពុជា*, ភ្នំពេញ៖ STC (JSRC) Printing House។


## ៣. គេហទំព័រ


- គណបក្សប្រជាជនកម្ពុជា, *ប្រសាសន៍សំខាន់ៗរបស់* ***សម្តេចតេជោ ហ៊ុន សែន*** *អញ្ជើញជាអធិបតីសម្ពោធវិមានអនុស្សាវរីយ៍ «នយោបាយឈ្នះ-ឈ្នះ» និងអបអរសាទរខួប២០ឆ្នាំ នៃការបិទបញ្ចប់ភ្លើងសង្គ្រាម*, ២៩ ធ្នូ ២០១៨ អត្ថបទដោយ NOU SEYHA, អាចរកបាននៅ https://www.cpp.org.kh/details/106358 (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២៤)។
- គណបក្សប្រជាជនកម្ពុជា, *ប្រវត្តិនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣*, ២៥ កញ្ញា ២០១៩, អាចរកបាននៅ https://www.cpp.org.kh/details/156858 (ចូលទស្សនាថ្ងៃទី១០ ឧសភា ឆ្នាំ២០២៤)។

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប), *សមាសភាព គ.ជ.ប ពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន*, អាចរកបាននៅ https://www.nec.gov.kh/khmer/content/4771 (ចូលទស្សនាថ្ងៃទី១០ ឧសភា ២០២៤)។
- ទីស្តីការគណៈរដ្ឋមន្ត្រី, ***នយោបាយឈ្នះ-ឈ្នះ*** *គឺជារូបមន្តបញ្ចប់សង្គ្រាមដ៏ល្អឯករបស់កម្ពុជា ដែលពិភពលោកគួររៀនសូត្រ*, ១ វិច្ឆិកា ២០២៣ ដោយ ឯកឧត្តម ប៉ែន បូណា, អាចរកបាននៅ https://pressocm.gov.kh/archives/86670 (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២៤។
- យល់ដឹងពីកម្ពុជា, *សមាសភាពគណៈរដ្ឋមន្ត្រីនីតិកាលទី១ នៃរដ្ឋសភា*, ១៦ មករា ២០១៩, អាចរកបាននៅ https://www.facebook.com/photo/?fbid=1351878421620141&set=pcb.1351878704953446&locale=th_TH (ចូលទស្សនាថ្ងៃទី១៣ ឧសភា ២០២៤)។
- រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, *សមាសភាពសមាជិករដ្ឋសភា នីតិកាលទី ១ នៃព្រះរាជាណាចក្រកម្ពុជា*, អាចរកបាននៅ https://nac.org.kh/group-article/47 (ចូលទស្សនាថ្ងៃទី ២១ មេសា ២០២៤)។
- រាជបណ្ឌិត្យសភាកម្ពុជា, *ព្រឹត្តិការណ៍ថ្ងៃទី៥-៦ កក្កដា ១៩៩៧*, ០៧ ឧសភា ២០២០, អាចរកបាននៅ https://rac.gov.kh/posts/838 (ចូលទស្សនាថ្ងៃទី២០ មេសា ២០២៤)។
- អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី, *ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ជាសមិទ្ធផលដ៏ធំធេងសម្រាប់កម្ពុជា*, ២៧ កក្កដា ២០២៣, អាចរកបាននៅ https://pressocm.gov.kh/archives/83362, (ចូលទស្សនានៅថ្ងៃទី០៥ មិថុនា ២០២៤)។
- អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី, *គ.ជ.ប បង្ហាញលទ្ធផលផ្លូវការនៃការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដោយគិតជាសំឡេងឆ្នោត*, ថ្ងៃទី៥ សីហា ២០២៣, អាចរកបាននៅ https://pressocm.gov.kh/archives/83511, (ចូលទស្សនានៅថ្ងៃទី ០៥ មិថុនា ២០២៤)។
- FRESH NEWS, *បណ្ឌិត គិន ភា៖ មានសមិទ្ធផលសំខាន់ៗចំនួន៩ ដែល* ***សម្តេចតេជោ*** *នាំមកជូនប្រជាជាតិកម្ពុជា ក្នុងឋានៈជានាយករដ្ឋមន្ត្រី ៣៨ឆ្នាំមកនេះ*, ១៤ មករា ២០២៣, អាចរកបាននៅ https://m.freshnewsasia.com/index.php/en/localnews/274165-2023-01-14-04-59-11.html (ចូលទស្សនាថ្ងៃទី០៨ មេសា ២០២៤) ។
- FRESH NEWS, *ប្រៀបធៀបបញ្ជីឈ្មោះសមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី៥ និងនីតិកាលទី៦*, ថ្ងៃទី០៦ កញ្ញា ២០១៨, អាចរកបាននៅ https://freshnewsasia.com/index.php/en/localnews/97785-2018-09-06-03-13-02.html, (ចូលទស្សនាថ្ងៃទី៩ កក្កដា ឆ្នាំ២០២៤) ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## I. ឧបសម្ព័ន្ធទី១ ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### ១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

### ២. ច្បាប់

២.១. ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា ៨២ ថ្មី មាត្រា ១០៦ ថ្មី (មួយ) មាត្រា ១៩៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ និង មាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ, លេខ នស/រកម/១១២១/០១៦ , ប្រកាសឱ្យប្រើនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១។

២.២. ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ, លេខ នស/រកម/០៨២២/០០៧, ប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២។

២.៣. ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, លេខ នស/រកម/០៦១៨/០១២, ប្រកាសឱ្យប្រើថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

### ៣. ព្រះរាជក្រឹត្យ

៣.១. ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

៣.២. ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១១០ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការ ត្រាស់បង្គាប់ផ្តល់គោរមងារដ៏ឧត្តុងឧត្តមខ្ពង់ខ្ពស់បំផុតជូននាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជា «**សម្តេចមហាបវរធិបតី**» ។

៣.៣. ព្រះរាជក្រឹត្យលេខ  នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការ តែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល។

### ៤. សេចក្តីសម្រេច

៤.១. សេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបប ការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

### ៥. សារាចរ

៥.១. សារាចរលេខ ០៨ សរ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

៥.២. សារាចរលេខ ១០ សរ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤។

## II. ឧបសម្ព័ន្ធទី២ សៀវភៅ


១. ទីស្តីការគណៈរដ្ឋមន្ត្រី. ២០០៤. សមិទ្ធផលសំខាន់ៗដែលសំរេចបានដោយរាជរដ្ឋាភិបាលកម្ពុជាសំរាប់នីតិកាលទី២ នៃរដ្ឋសភា (១៩៩៨-២០០៣). ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការណៈរដ្ឋមន្ត្រី។

២. ទីស្តីការគណៈរដ្ឋមន្ត្រី. ២០០៨. របាយការណ៍ស្តីពី សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល៤ឆ្នាំ (២០០៤-២០០៧). ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការគណៈរដ្ឋមន្ត្រី។

៣. ទីស្តីការគណៈរដ្ឋមន្ត្រី. ២០១៣. *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ២០០៨-២០១២.* ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការគណៈរដ្ឋមន្ត្រី។

៤. ទីស្តីការគណៈរដ្ឋមន្ត្រី. ២០១៨. *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ២០១៣-២០១៧.* ភ្នំពេញ៖ នាយកដ្ឋានសរុបនៃទីស្តីការគណៈរដ្ឋមន្ត្រី។

៥. ទីស្តីការគណៈរដ្ឋមន្ត្រី អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស. ២០១៣. *សៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣*។

៦. រាជរដ្ឋាភិបាល. ២០២៣. «*កម្មវិធីនយោបាយ*» របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភាសម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨។

៧. រាជរដ្ឋាភិបាល. ២០២៣. «*យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១*»។

៨. សាស្ត្រាចារ្យ ជុំ អ៊ីម.២០១២. *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ៖ បោះពុម្ពលើកទី១ ដោយរោងពុម្ពសុខចេង។

៩. សាស្ត្រាចារ្យ ហៀង សាង. ២០២១. *សៀវភៅនីតិរដ្ឋបាលទូទៅ.* ភ្នំពេញ៖ បោះពុម្ពលើកទី៦ ដោយរោងពុម្ពស៊ីហេង។

១០. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា. ២០២១. *សៀវភៅស្តីពីសភាកម្ពុជា*. ភ្នំពេញ៖ STC (JSRC) Printing House។

## III. ឧបសម្ព័ន្ធទី៣ រូបភាព

១. **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** (រដ្ឋបុរសកម្ពុជា)

២. សមាសភាពគណៈរដ្ឋមន្ត្រីនីតិកាលទី ៧

៣. គំនូរបំប្រួញស្តីពី "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល់ទី១"

៤. ការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ។

# ឧបសម្ព័ន្ធទី ១

## ឯកសារច្បាប់

## និងលិខិតបទដ្ឋានគតិយុត្ត

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# អារម្ភកថា

❖❖❖❖

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រ ឡាយព្រះ-ហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។ រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និងសេចក្តី សម្រេចទាំងឡាយ នៃស្ថាប័ននានា របស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

មកដល់ចុងឆ្នាំ២០១៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន ធ្វើវិសោធនកម្មចំនួន ៨លើក )ដូចមានក្នុងកំណត់សំគាល់ភ្ជាប់ (ដែលមាន ដូចខាងក្រោម៖

**១**-ច្បាប់ស្តីពីការកែប្រែមាត្រា២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ-កម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ នាសម័យ ប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី១។ ការកែប្រែ នេះដើម្បីផ្តល់សិទ្ធិដល់ ប្រមុខរដ្ឋស្តីទីចុះហត្ថលេខាលើព្រះរាជក្រម ឬព្រះរាជក្រឹត្យ នៅពេល ព្រះមហាក្សត្រអវត្តមាន ដោយព្រះរាជសារប្រគល់សិទ្ធិ ។

**២**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័ត នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាល ទី២ ។ វិសោធនកម្មនេះ ដើម្បីបង្កើតឱ្យមានស្ថាប័នព្រឹទ្ធសភា ។

៣-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាល ទី២ ចែងអំពី “ ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ”
និងកែតម្រូវកំហុសបច្ចេកទេសនូវមាត្រា១៩ថ្មី ត្រង់លេខមាត្រា
យោងពីមាត្រា១០០ចាស់ ទៅមាត្រា១១៩ថ្មី ។

៤-ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាល ទី៣ ។
ច្បាប់ធម្មនុញ្ញបន្ថែមនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈ
នូវដំណើការល្អប្រសើរ នៃស្ថាប័នជាតិ
ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជា-ធិបតេយ្យ
សេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់។

៥-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១១ថ្មី
នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៣
បានកែប្រែកូរ៉ុមនៃការប្រជុំរដ្ឋសភា៖

-កូរ៉ុមប្រាំពីរភាគដប់ សម្រាប់ការអនុម័តយកមតិភាគច្រើន ពីរភាគបី ឬយកមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

-កូរ៉ុមប្រាំមួយភាគដប់ សម្រាប់ការអនុម័តយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**៦**-ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី)មួយ (មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣។ ច្បាប់ធម្មនុញ្ញនេះសំដៅកែសម្រួលសម្លេង បោះឆ្នោត ពីសម្លេង ពីរភាគបីមកជា មតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមប្រជុំដើម្បី ៖

- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកគណៈ-កម្មការនានានៃរដ្ឋសភា
- បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល និងអនុម័តញត្តិបន្ទោសទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល
- បោះឆ្នោតជ្រើសរើប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកគណៈ-កម្មការនានានៃព្រឹទ្ធសភា
- អនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភា ។

**៧**-ច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណា-

ចក្រកម្ពុជាអនុម័ត នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ចែងអំពីការបែងចែកទឹកដីនៃព្រះរាជាណាចក្រ- កម្ពុជា ជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**៨**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ថ្មី ដល់ជំពូក ទី១៦ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ដោយបញ្ញត្តិអំពីអង្គការរៀបចំការបោះឆ្នោតជាស្ថាប័នធម្មនុញ្ញ ។

ច្បាប់រដ្ឋធម្មនុញ្ញដែលបោះពុម្ពផ្សាយលើកនេះ មាន១៦០មាត្រា ដែលចែកចេញជា១៧ ជំពូក មាន បុព្វកថា អំពីអធិបតេយ្យ អំពីព្រះមហាក្សត្រ អំពីសិទ្ធិ និងករណីកិច្ច របស់ប្រជាពលរដ្ឋខ្មែរ អំពីរបបនយោបាយ អំពីសេដ្ឋ- កិច្ច អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច អំពីរដ្ឋសភា អំពីព្រឹទ្ធសភា អំពីសមាជរដ្ឋសភា និងព្រឹទ្ធសភា អំពីរាជរដ្ឋាភិបាល អំពីអំណាចតុលាការ អំពីក្រុមប្រឹក្សាធម្មនុញ្ញ អំពីការគ្រប់គ្រងរដ្ឋបាល អំពីសមាជជាតិ អំពីអង្គការរៀបចំការបោះឆ្នោត អំពីអានុភាពការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ អំពីអន្តរ- ប្បញ្ញត្តិ ភ្ជាប់ដោយឧបសម្ព័ន្ធចំនួន៧ ។

ខ្ញុំសូមថ្លែងអំណរគុណដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាដែលបានចូលរួមខិតខំប្រមូលចងក្រង ធ្វើបច្ចុប្បន្នភាពច្បាប់រដ្ឋធម្មនុញ្ញនេះ និងសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដែលជួយគាំទ្រនូវការបោះពុម្ពរដ្ឋធម្មនុញ្ញនេះ ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា កម្រងរដ្ឋធម្មនុញ្ញនេះ នឹងជួយដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ក្នុងការសិក្សាស្វែងយល់ អំពីកម្រងខ្លឹមសារនៃរដ្ឋធម្មនុញ្ញនេះឲ្យកាន់តែល្អប្រសើរឡើង។

រាជធានីភ្នំពេញ,ថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០១៥

**អគ្គលេខាធិការ**

ឡេង ប៉េងឡុង

*ឧបសម្ព័ន្ធទី ៦*

# សច្ចាប្រណិធាន
# ទូលព្រះបង្គំ
# យើងខ្ញុំ
# នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល
# សូមធ្វើសច្ចាប្រណិធាន
# នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
# និងទេវតារក្សាស្វេតច្ឆត្រ
# ដូចតទៅ :

*-ក្នុងពេលប្រតិបត្តិការតាមមុខតំណែងខ្លួន និងក្នុងការបំពេញ បេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំ គ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំសូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោន៍ជាតិ សម្រាប់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ឬសម្រាប់បក្សពួក ឬសម្រាប់ភាគីរៀងៗ ខ្លួនឡើយ ។*

*- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បី ការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវៈ*

*• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា*

*• អធិបតេយ្យភាពជាតិពេញបរិបូរណ៍*

*• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ ដល់ ១៩៦៩*

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹតភាព និងភាពមិនចូលបក្សសម្ព័ន្ធ សម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាមួយក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំមិនបម្រើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហិង្សាគ្រប់បែបយ៉ាង។

ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុ-បក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

## ២. ច្បាប់

២.១. ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា ៨២ ថ្មី មាត្រា ១០៦ ថ្មី (មួយ) មាត្រា ១៩៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ, លេខ- នស/រកម/១១២១/០១៦ , ប្រកាសឱ្យប្រើនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១។

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ៤១០

**ព្រះរាជក្រម**

នស/រកម/១១២១/ ០១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ

# នៃគណៈរដ្ឋមន្ត្រី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ច្បាប់នេះមានគោលបំណងធានាប្រសិទ្ធភាពការងាររបស់គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការនីតិប្រតិបត្តិដូចបានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ ._**

ច្បាប់នេះមានគោលដៅកំណត់អំពីសមាសភាព សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ ._**

ច្បាប់នេះមានវិសាលភាពអនុវត្តទៅលើអង្គការនីតិប្រតិបត្តិ ។

## ជំពូកទី ២
## សមត្ថកិច្ច និងសមាសភាពគណៈរដ្ឋមន្ត្រី

**មាត្រា៤ ._**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ចកំណត់និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិនិងអង្គការតុលាការ ។

**មាត្រា៥ ._**

រាជរដ្ឋាភិបាលដឹកនាំកិច្ចការទូទៅរបស់រដ្ឋស្របតាមកម្មវិធីនយោបាយរបស់ខ្លួន ។

**មាត្រា៦ ._**

រាជរដ្ឋាភិបាលត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

**មាត្រា៧ ._**

រាជរដ្ឋាភិបាលគ្រប់គ្រង ដឹកនាំ បញ្ជា ប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់ រួមទាំងកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងកម្លាំងប្រដាប់អាវុធផ្សេងៗទៀត ក្នុងការធ្វើសកម្មភាពរបស់ខ្លួន ។

**មាត្រា៨ ._**

សមាសភាពនៃរាជរដ្ឋាភិបាលមាន ៖

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី
- ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី ។

**មាត្រា៩ ._**

នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលឯទៀតអាចជ្រើសរើសយកក្នុងចំណោមសមាជិករដ្ឋសភា ឬក្រៅសមាជិករដ្ឋសភា ប៉ុន្តែត្រូវជាសមាជិកគណបក្សមានតំណាងនៅក្នុងរដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្ត ។

**មាត្រា១០ ._**

មុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ការធ្វើអាជីវកម្មគ្រប់ប្រភេទ ឬការកាន់មុខតំណែងជាថ្នាក់ដឹកនាំ ឬគណៈគ្រប់គ្រង ឬសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនសហគ្រាស ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា១១ ._**

នៅពេលផុតនីតិកាលរបស់រដ្ឋសភាឬពេលផ្លាស់ប្តូររាជរដ្ឋាភិបាល រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

**មាត្រា១២ ._**

នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលនៅក្នុងមុខតំណែង ត្រូវទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញភារកិច្ចដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## គណៈរដ្ឋមន្ត្រី សមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល

**មាត្រា១៣ ._**

គណៈរដ្ឋមន្ត្រីទទួលខុសត្រូវរួមចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល ។

នាយករដ្ឋមន្ត្រី ជាប្រមុខរាជរដ្ឋាភិបាល ដឹកនាំ បញ្ជារាល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

**មាត្រា១៤ ._**

នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ។

អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រីមានអង្គប្រជុំធំ និងអង្គប្រជុំពិនិត្យស្រាវជ្រាវ ។

រាល់អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ត្រូវមានកំណត់ហេតុ ។

**មាត្រា១៥ ._**

អង្គប្រជុំធំ គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។

នាយករដ្ឋមន្ត្រីអាចអញ្ជើញអ្នកពាក់ព័ន្ធនានាចូលរួមក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី តាមការចាំបាច់ ។

នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា១៦ ._**

នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់កោះប្រជុំនិងធ្វើជាអធិបតីនៃអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចកិច្ចការតាងនាមរាជរដ្ឋាភិបាលឡើយ ។

**មាត្រា១៧ ._**

នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនណាម្នាក់ជាអ្នកចរចា និងចុះហត្ថលេខា ។

បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៨ ._**

នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និងសារាចររបស់រាជរដ្ឋាភិបាល ។ លិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពទូទៅរបស់រាជរដ្ឋាភិបាល ត្រូវចុះក្នុងរាជកិច្ច ។

**មាត្រា១៩ ._**

នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំរដ្ឋសភា ដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

នាយករដ្ឋមន្ត្រីលើកសំណើជូនរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់ ។

**មាត្រា២០ ._**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ ដើម្បីបញ្ចប់មុខតំណែងសមាជិករាជរដ្ឋាភិបាលដោយព្រះរាជក្រឹត្យ ។

**មាត្រា២១ ._**

នាយករដ្ឋមន្ត្រីលើកសំណើផ្លាស់ប្តូរ និងជំនួសសមាជិករាជរដ្ឋាភិបាលជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្ត ។ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ សមាជិករាជរដ្ឋាភិបាលនោះត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា២២ ._**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងនៅតាមក្រសួង ស្ថាប័ននានា ដោយព្រះរាជក្រឹត្យ ។

**មាត្រា២៣ ._**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចខាងក្រោម ៖

- ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
- [illegible]ភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- [illegible]គ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការនគរបាលជាតិ

មុខតំណែង និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពីថ្នាក់ឧត្តមសេនីយ៍ឡើង ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា២៤ ._**

នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ ដែលមិនមានចែងក្នុងមាត្រា២៣ លើកលែងតែមន្ត្រីដែលមានចែងក្នុងកថាខណ្ឌទី២ មាត្រា៤៦ នៃច្បាប់នេះ ។

**មាត្រា២៥ ._**

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់គោរមងារដល់ឥស្សរជន វរជន ឬសប្បុរសជនណាមួយ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២៦ ._**

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់ ឬអាចផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិ ឥស្សរជន វរជន ឬសប្បុរសជន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២៧ ._**

នាយករដ្ឋមន្ត្រី អាចលើកសំណើផ្តល់ងារកិត្តិយសជាប្រតិភូរាជរដ្ឋាភិបាលដល់ឥស្សរជនណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា២៨ ._**

ក្នុងករណីពិសេស ឬប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិដើម្បីដោះស្រាយកិច្ចការចាំបាច់និងបន្ទាន់ រួចហើយត្រូវរាយការណ៍សុំការអនុម័តពីអង្គការនីតិប្បញ្ញត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា២៩ ._**

ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រី១(មួយ)រូប ទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។

**មាត្រា៣០ ._**

ឧបនាយករដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមលើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ។

ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី ។ កិច្ចការដែលទាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៣១ ._**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រងក្រសួង ហៅថា រដ្ឋមន្ត្រី ។

សមាជិករាជរដ្ឋាភិបាលដែលមិនដឹកនាំក្រសួង ត្រូវទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា៣២ ._**

នាយករដ្ឋមន្ត្រី និងសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មានខុទ្ទកាល័យរបស់ខ្លួនមួយនិងមានទីប្រឹក្សា ជំនួយការ លេខាធិការដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

**មាត្រា៣៣ ._**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត ។

នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្ត និងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសសមាជិករាជរដ្ឋាភិបាលតាមបែបបទនិងនីតិវិធីជាធរមាន ។

## ជំពូកទី ៤
## ទីស្តីការគណៈរដ្ឋមន្ត្រី

**មាត្រា៣៤ ._**

ត្រូវបានបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៣៥ ._**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា៣៦ ._**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣៧ ._**

ទីស្តីការគណៈរដ្ឋមន្ត្រីអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

**មាត្រា៣៨ ._**

ការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រីត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៥
## ការបង្កើតក្រសួង

**មាត្រា៣៩ .–**

ការបង្កើតក្រសួងត្រូវកំណត់ដោយច្បាប់ ។

ក្រសួងនីមួយៗត្រូវអនុវត្តសមត្ថកិច្ចស្របតាមច្បាប់ដែលបង្កើតក្រសួងនោះ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់នាយកដ្ឋានឡើង ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងក្រសួងពីរ ឬច្រើន គណៈរដ្ឋមន្ត្រីត្រូវពិនិត្យ និងសម្រេច ។

**មាត្រា៤០ .–**

រដ្ឋមន្ត្រីដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន ។

**មាត្រា៤១ .–**

រដ្ឋមន្ត្រីមានភារកិច្ចដឹកនាំ គ្រប់គ្រងក្រសួង និងអង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់ ។

**មាត្រា៤២ .–**

នៅពេលដែលរដ្ឋមន្ត្រីណាម្នាក់អវត្តមាន ឬមានភារកិច្ចមិនអាចដឹកនាំ គ្រប់គ្រងក្រសួងបានជាបណ្តោះអាសន្ន រដ្ឋលេខាធិការប្រចាំការដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់នេះ ត្រូវទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ក្រសួង ក្នុងឋានៈជារដ្ឋមន្ត្រីស្តីទី រហូតដល់មានវត្តមានរដ្ឋមន្ត្រីនៃក្រសួងសាមី ។ ក្នុងករណីដែលរដ្ឋលេខាធិការប្រចាំការ មិនអាចបំពេញតួនាទីជារដ្ឋមន្ត្រីស្តីទីបាន រដ្ឋមន្ត្រីអាចចាត់តាំងរដ្ឋលេខាធិការផ្សេងទៀតជារដ្ឋមន្ត្រីស្តីទី ។

រដ្ឋមន្ត្រីស្តីទីមិនមែនជាសមាជិករាជរដ្ឋាភិបាល ហើយត្រូវអនុវត្តសិទ្ធិអំណាចតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី ។

ក្នុងករណីដែលមានកិច្ចការចាំបាច់តាមរដ្ឋធម្មនុញ្ញ និងច្បាប់តម្រូវឱ្យរដ្ឋមន្ត្រីជាអ្នកបំពេញតួនាទីនោះ នាយករដ្ឋមន្ត្រីចាត់តាំងសមាជិករាជរដ្ឋាភិបាលណាម្នាក់ ដើម្បីបំពេញកិច្ចការនោះជំនួសឱ្យរដ្ឋមន្ត្រីដែលអវត្តមាន ។

តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទីត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៤៣ .–**

ក្រសួងនីមួយៗមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីនៃក្រសួងសាមី ។

**មាត្រា៤៤ .–**

ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ក្រសួង ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

**មាត្រា៤៥ .–**

ក្រសួងនីមួយៗអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

**មាត្រា៤៦ ._**

រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រដ្ឋមន្ត្រីមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រាជរដ្ឋាភិបាល អាចចេញអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួងដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា៤៧ ._**

រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ ។

ប្រកាស សេចក្តីសម្រេច សារាចរ ឬសេចក្តីណែនាំរបស់ក្រសួង មិនអាចចែងអំពីកិច្ចការដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ ។

## ជំពូកទី ៦

## ការបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា

**មាត្រា៤៨ ._**

រាជរដ្ឋាភិបាលអាចលើកសំណើបង្កើត ឬអាចបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា តាមការចាំបាច់ ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

**មាត្រា៤៩ ._**

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ មិនមានក្របខ័ណ្ឌមន្ត្រីរាជការដោយឡែករបស់ខ្លួនឡើយ ។ មន្ត្រីរាជការដែលបំពេញការងារនៅក្នុងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ត្រូវជ្រើសយកពីក្របខ័ណ្ឌមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី និង/ឬក្រសួងពាក់ព័ន្ធ លើកលែងតែមានកំណត់ក្នុងច្បាប់ដោយឡែក ។

ប្រធានស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា មានសិទ្ធិលើកសំណើតែងតាំង ឬមានសិទ្ធិតែងតាំង ផ្លាស់ប្តូរមន្ត្រីរាជការរបស់ខ្លួន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ មានសមត្ថកិច្ចដូចមានកំណត់នៅក្នុងច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៥០.‒**

នាយករដ្ឋមន្ត្រីអាចចាត់តាំងសមាជិករាជរដ្ឋាភិបាល១(មួយ)រូប ឱ្យទទួលដឹកនាំ គ្រប់គ្រងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើងស្របតាមមាត្រា៤៨ នៃច្បាប់នេះ ។

# ជំពូកទី ៧

## រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា និងជំនួយការ

**មាត្រា៥១.‒**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើអគ្គនាយកឡើងទៅ ។

**មាត្រា៥២.‒**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា និងជំនួយការនាយករដ្ឋមន្ត្រី បំពេញភារកិច្ចតាមការប្រគល់ពីនាយករដ្ឋមន្ត្រី ។

**មាត្រា៥៣.‒**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ដែរ ។

នៅពេលណាដែលរាជរដ្ឋាភិបាលចប់អាណត្តិ ឬលាលែង ឬត្រូវបានទម្លាក់ដោយរដ្ឋសភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ដូចមានចែងក្នុងមាត្រា៣២ មាត្រា៣៧ មាត្រា៤៥ និងមាត្រា៥២ នៃច្បាប់នេះ ក៏ត្រូវអស់តំណែងដែរ ។

**មាត្រា៥៤.‒**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការនៅក្នុងមុខតំណែង ទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញភារកិច្ច ។

ប្រាក់បំណាច់មុខងារនៃរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

# ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា៥៥.‒**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៣

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៥៦ ._**

ច្បាប់នេះត្រូវយកទៅអនុវត្តចាប់ពីនីតិកាលទី៦ នៃរដ្ឋសភាតទៅ ។

**មាត្រា៥៧ ._**

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ និងច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា៥៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៩ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨

នសរកម.១៨០៦.៦៤៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ហត្ថលេខា**
**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

លេខៈ៦៧១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

## ៣. ព្រះរាជក្រឹត្យ

៣.១. ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

**ព្រះរាជក្រឹត្យ**

**នស/រកត/០៨២៣/**១៩៨១

**ស្តីពី**

**ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៧៧២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : បញ្ចប់តំណែងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានតែងតាំងសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា និងតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដែលមានសមាសភាព ដូចតទៅ៖

**I-នាយករដ្ឋមន្ត្រី**

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត**

**II-ឧបនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម នេត សាវឿន
២- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន
៣- ឯកឧត្តម ស៊ុន ចាន់ថុល
៤- ឯកឧត្តម ហង់ជួន ណារ៉ុន
៥- ឯកឧត្តម សាយ សំអាល់
៦- ឯកឧត្តម ស សុខា
៧- ឯកឧត្តម ទៀ សីហា
៨- ឯកឧត្តម កើត រិទ្ធ

៩- ឯកឧត្តម សុខ ចិន្តាសោភា

១០-ឯកឧត្តម វង្សី វិស្សុត

**III-ទេសរដ្ឋមន្ត្រី**

| | |
|---|---|
| ១- ឯកឧត្តម គន់ គីម | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២- ឯកឧត្តម ហូ សិទ្ធី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៣- ឯកឧត្តម អ៊ឹក រ៉ាប៊ុន | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៤- ឯកឧត្តម ឱម យ៉ិនទៀង | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៥- ឯកឧត្តម អៀង ម៉ូលី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៦- ឯកឧត្តម ថោង ខុន | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៧- ឯកឧត្តម ពេជ សោភ័ន | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៨- ឯកឧត្តម ព្រុំ សុខា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៩- ឯកឧត្តម សក់ សេដ្ឋា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១០-ឯកឧត្តម អូស្មាន ហាស្សាន់ | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១១-ឯកឧត្តម អ៊ី ឈាន | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១២-ឯកឧត្តម អ៊ុក ប្រាថ្នា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៣-ឯកឧត្តម អ៊ុច បូរិទ្ធ | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៤-ឯកឧត្តម ស្វាយ ស៊ីថា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៥-ឯកឧត្តម ផៃ ស៊ីណារិទ្ធ | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៦-ឯកឧត្តម លី ធុជ | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៧-ឯកឧត្តម ឆែម គាតរិទ្ធី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៨-ឯកឧត្តម ឈៀង យ៉ាណារ៉ា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៩-ឯកឧត្តម សុក ស៊ីផាន់ណា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២០-ឯកឧត្តម កែវ រ៉េមី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ២១-ឯកឧត្តម គី តិច | (ទទួលបន្ទុកបេសកកម្មពិសេស) |

**IV-រដ្ឋមន្ត្រី**

| | |
|---|---|
| ១- ឯកឧត្តម វង្សី វិស្សុត | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី |
| ២- ឯកឧត្តម ស សុខា | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| ៣- ឯកឧត្តម ទៀ សីហា | រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ៤- ឯកឧត្តម សុខ ចិន្តាសោភា | រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ៥- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦- ឯកឧត្តម ឌិត ទីណា | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៧- ឯកឧត្តម ឆាយ ឫទ្ធិសែន | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| ៨- លោកជំទាវ ចម និម្មល | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |
| ៩- ឯកឧត្តម ហែម វណ្ណឌី | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ១០-ឯកឧត្តម កែវ រតនៈ | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល |
| ១១-ឯកឧត្តម ប៊ិន ត្រឈៃ | រដ្ឋមន្ត្រីក្រសួងផែនការ |
| ១២-ឯកឧត្តម ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ១៣-ឯកឧត្តម ជា សុមេធី | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១៤-ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១៥-ឯកឧត្តម អ៊ាង សុផល្លែត | រដ្ឋមន្ត្រីក្រសួងបរិស្ថាន |
| ១៦-ឯកឧត្តម ថោ ជេដ្ឋា | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម |
| ១៧-ឯកឧត្តម នេត្រ ភក្ត្រា | រដ្ឋមន្ត្រីក្រសួងព័ត៌មាន |
| ១៨-ឯកឧត្តម កើត រិទ្ធ | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ១៩-ឯកឧត្តម ហួត ហាក់ | រដ្ឋមន្ត្រីក្រសួងអធិការកិច្ច |
| ២០-ឯកឧត្តម ជា វ៉ាន់ដេត | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២១-ឯកឧត្តម ឈាង រ៉ា | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២២-ឯកឧត្តម ប៉េង ពោធិ៍នា | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២៣-លោកជំទាវ ភឿង សកុណា | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ២៤-ឯកឧត្តម សុខ សូកេន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ២៥-ឯកឧត្តម ចាយ បូរិន | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា |
| ២៦-លោកជំទាវ អ៊ឹង កន្থាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ២៧-ឯកឧត្តម ហេង សួរ | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២៨-ឯកឧត្តម ហ៊ុន ម៉ានី | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
| ២៩-ឯកឧត្តម ម៉ៅ ហាវណ្ណាល់ | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ៣០-ឯកឧត្តម ឡាំ ជា | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។ |

**មាត្រា២** : ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ព្រ៖រថ. ២៣០៨. ១៩៩៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣*

៣.២. ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១១០ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការត្រាស់បង្គាប់ផ្តល់គោរមងារដ៏ឧត្តុងឧត្តមខ្ពង់ខ្ពស់បំផុតជូននាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជា «**សម្តេចមហាបវរធិបតី**» ។



**ព្រះរាជក្រឹត្យ**

នស/រកត/០៩២៣/២១១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់**ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់ របស់ប្រជារាស្ត្រ បានចូលរួមដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ កសាងបាននូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ សេដ្ឋកិច្ចជាតិ ការអភិវឌ្ឍជាតិ លើគ្រប់វិស័យ ការពារលិទ្ធប្រជាធិបតេយ្យ និងមានស្ថិរភាពសន្តិសុខសង្គមបានល្អប្រសើរ ព្រមទាំងរក្សានិងការពារបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។
- បានទ្រង់យល់ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្វាមីភក្តិចំពោះរាជបល្ល័ង្ក ការពារ និងគោរពព្រះពុទ្ធសាសនា ការពារយុត្តិធម៌សង្គម ដើម្បីនិរន្តរភាពរាជានិយម នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រោសព្រះរាជទានគោរមងារ**

**ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

**ជា**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

ចស់ល-២៣០៩.២១២៧

**នរោត្តម សីហមុនី**

ធ្វើនៅថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០២៣

៣.៣. ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល។

# ព្រះរាជក្រឹត្យ

នស/រកត/០២២៤/២០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៧៧២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល៖

១.ឯកឧត្តម **ហ៊ុន ម៉ានី** ជា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

២.ឯកឧត្តម **ស្រ៊ី ថាមរុទ្ធ** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៣.ឯកឧត្តម **ម៉ែន ទិបុល** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស) ។

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣រស. ២៤០២.២០៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២៤*

## ៤. សេចក្តីសម្រេច

៤.១. សេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦១ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ច**
**របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**ប្រការ១ :** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម។

**ប្រការ២ :** នាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងាររួមរបស់គណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ព្រមទាំងទទួលបន្ទុកដោយឡែកក្នុងទំនាក់ទំនងផ្ទាល់ជាមួយព្រះមហាក្សត្រ សម្រាប់កិច្ចការរបស់រាជរដ្ឋាភិបាល និងការដឹកនាំបញ្ជាផ្ទាល់លើបញ្ជាការដ្ឋានអង្គរក្ស, បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

**ប្រការ៣ :** ឧបនាយករដ្ឋមន្ត្រី ៖

១-ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទីពេលនាយករដ្ឋមន្ត្រីអវត្តមាន, ជួយនាយករដ្ឋមន្ត្រីលើវិស័យសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ, ក្នុងក្របខណ្ឌអន្តរក្រសួង ជួយនាយករដ្ឋមន្ត្រីក្នុងការសម្របសម្រួលដឹកនាំកម្លាំងគ្រប់ប្រភេទ ដើម្បីការងារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ, ទទួលសិទ្ធិពី

នាយករដ្ឋមន្ត្រីក្នុងការបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងពេលនាយករដ្ឋមន្ត្រីអវត្តមាន, ជួយតម្រង់ទិសដល់អាជ្ញាធរ គណៈកម្មាធិការ ក្រុមប្រឹក្សាដែលចំណុះឱ្យរាជរដ្ឋាភិបាល តាមការប្រគល់សិទ្ធិរបស់នាយករដ្ឋមន្ត្រី ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

២-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រី និងឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** អវត្តមាន, ជួយនាយករដ្ឋមន្ត្រីលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជាប្រធានគណៈកម្មការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៣-ឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារទាក់ទាញការវិនិយោគឯកជន និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ទទួលបន្ទុកជាសហប្រធានខាងភាគីកម្ពុជា នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ, ជួយនាយករដ្ឋមន្ត្រីលើការងារគមនាគមន៍ដឹកជញ្ជូន និងភស្តុភារកម្ម ទាំងការដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស និងជាប្រធានក្រុមប្រឹក្សាជាតិភស្តុភារកម្ម ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៤-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យអប់រំ យុវជន និងកីឡា ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៥-ឯកឧត្តមបណ្ឌិត **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៦-ឯកឧត្តមបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើកិច្ចការមហាផ្ទៃ, ដឹកនាំសម្របសម្រួលការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ការជួញដូរមនុស្ស និងការបង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ, ការបំផ្លាញចោលអាវុធ និងជាសេនាធិការជួយនាយករដ្ឋមន្ត្រី លើការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៧-ឯកឧត្តម **ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យការពារជាតិ, ដឹកនាំកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៨-ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យយុត្តិធម៌ និងការងារជាមួយអង្គការតុលាការ និងអង្គការអយ្យការ, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការដឹកនាំសម្របសម្រួលការអនុវត្តនយោបាយព្រហ្មទណ្ឌ, ជួយនាយករដ្ឋមន្ត្រីលើការដឹកនាំសម្របសម្រួលការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ, ជួយនាយករដ្ឋមន្ត្រីលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

៩-ឯកឧត្តម **សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ផ្តល់យោបល់ជូននាយករដ្ឋមន្ត្រី អំពីក្របខណ្ឌគោលនយោបាយក្រៅប្រទេស, ការសម្របសម្រួលការបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និងសម្រេចលើសំណើសុំកូន និងការសុំលាសញ្ជាតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

១០-ឯកឧត្តម **វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ សម្របសម្រួលកិច្ចការសម្រាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី, ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដាន និងសម្របសម្រួលទាក់ទងនឹងកិច្ចការដែលនៅសេសសល់របស់តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម, ដឹកនាំផ្ទាល់ក្រុមប្រឹក្សាអ្នកច្បាប់ ព្រមទាំងជួយនាយករដ្ឋមន្ត្រី ក្នុងការងារទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា និងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ, ដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ព្រមទាំងទទួលបន្ទុកអនុវត្តការងារពិសេស ឬបេសកកម្មពិសេសផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៤** : នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីស្តីទី។

**ប្រការ៥** : ឧបនាយករដ្ឋមន្ត្រីមួយរូបៗ អាចមានទីប្រឹក្សា ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ, ២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ, និងជំនួយការ ៥ រូប ក្នុងនោះ ១ រូប មានឋានៈស្មើ អគ្គនាយក, ២ រូប មានឋានៈស្មើ អគ្គនាយករង និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**ប្រការ៦** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ៖

១-ឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការអតីតយុទ្ធជន និងជនពិការ, ជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២-ឯកឧត្តម **ហូ សិទ្ធី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជានាយកខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៣-ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ, ជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៤-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៥-ឯកឧត្តម **វៀង ម៉ូលី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៦-ឯកឧត្តមបណ្ឌិត **ថោង ខុន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជំរុញការអភិវឌ្ឍចលនាកីឡា និងដឹកនាំគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៧-ឯកឧត្តម **ពេជ សោភ័ន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកលើការពង្រឹងការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៨-ឯកឧត្តម **ព្រុំ សុខា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

៩-ឯកឧត្តម **សក់ សេដ្ឋា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១០-ឯកឧត្តម **អូស្មាន ហាស្សាន់** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារចលនាមូស្លីម និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១១-ឯកឧត្តម **អ៊ី ឈាន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារទាក់ទងនឹងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន និងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១២-ឯកឧត្តម **អ៊ុក ប្រាថ្នា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើកិច្ចការសង្គម និងវប្បធម៌ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៣-ឯកឧត្តម **អ៊ុច បូររិទ្ធ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការសម្របសម្រួលកិច្ចការទំនាក់ទំនងបរទេស ក្នុងផ្នែកគណបក្សនយោបាយ និងអង្គការមហាជន ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៤-ឯកឧត្តម **ស្វាយ ស៊ីថា** ទេសរដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើកិច្ចការព័ត៌មាន និងសាធារណមតិ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៥-ឯកឧត្តមសន្តិបណ្ឌិត **នៃ ស៊ីណារិទ្ធ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារសេវាប្រមូល និងវិភាគព័ត៌មានផ្នែកសន្តិសុខ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៦-ឯកឧត្តមបណ្ឌិត **លី ធុជ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានគណៈកម្មាធិការជាតិអេស្កាប់, ជាអនុប្រធានទី១នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៧-ឯកឧត្តមបណ្ឌិត **សែម គាគរិទ្ធី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៨-ឯកឧត្តមបណ្ឌិត **ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី២ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទទួលបន្ទុកលើការងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

១៩-ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ក្នុងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ជាអាទិ៍ ASEM BRICS និងអង្គការសហប្រតិបត្តិការសៀងហៃ ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២០-ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការសម្របសម្រួលដឹកនាំកិច្ចការសិទ្ធិមនុស្សរបស់កម្ពុជា និងទទួលបន្ទុកជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

២១-ឯកឧត្តមបណ្ឌិត **គី តិច** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការដឹកនាំ និងគ្រប់គ្រងក្រុមមេធាវីរាជរដ្ឋាភិបាល ព្រមទាំងទទួលបន្ទុកអនុវត្តការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី។

**ប្រការ៧** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសមួយរូបៗ មានជំនួយការ ៥ រូប ក្នុងនោះ ២ រូប មានឋានៈស្មើអគ្គនាយក, ១ រូប មានឋានៈស្មើ អគ្គនាយករង និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**ប្រការ៨** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩** : នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៣ ប្រការ៦ និងប្រការ៩*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី ២

## សៀវភៅ

១០. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា. ២០២១. *សៀវភៅស្តីពីសភាកម្ពុជា*, ភ្នំពេញ៖ STC (JSRC) Printing House។



| | | | |
|---|---|---|---|
| ១០២ | លោក សឹម កែវ | ក្រចេះ | |
| ១០៣ | លោកស្រី បេង រ៉េន | ក្រចេះ | |
| ១០៤ | លោក តេង រឿន | ក្រចេះ | |
| ១០៥ | លោក ពោន ពន្និ | ក្រចេះ | |
| ១០៦ | លោក ប៊ូ ថង | ព្រះវិហារ | |
| ១០៧ | លោក វ៉េង យួន | ព្រះវិហារ | |
| ១០៨ | លោក ស៊ិក សំអេង | ព្រះវិហារ | |
| ១០៩ | លោក នូ បេង | រតនគិរី | |
| ១១០ | លោក ទាំ ខ្សែន | រតនគិរី | |
| ១១១ | លោកស្រី ឡាក់ អូន | រតនគិរី | |
| ១១២ | លោក ញ៉ើម សារ៉ន | ស្ទឹងត្រែង | ជំនួស លោក ថង បៃ |
| ១១៣ | លោក ចាន់ យឿន | មណ្ឌលគិរី | |
| ១១៤ | លោក ចាវ ង៉ន | មណ្ឌលគិរី | |
| ១១៥ | លោក ប៊ុន គីង | ស្ទឹងត្រែង | |
| ១១៦ | លោក រង់ ផ្កាមកេសន | កោះកុង | |
| ១១៧ | លោក យ៉ែយ សឹយ | កោះកុង | |

## ខ. សម័យព្រះរាជាណាចក្រកម្ពុជាទី២ (ចាប់ឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៨)

### ខ.១. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អនុលោមតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសស្តីពី ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានកំណត់អំពីការរៀបចំបោះឆ្នោតជាសកលនៅកម្ពុជា។

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រ យ៉ាងតិច ១២០រូប ដែលត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានៈ

- មានសិទ្ធិបោះឆ្នោត
- មានអាយុយ៉ាងតិច ២៥ ឆ្នាំ
- មានសញ្ជាតិខ្មែរតាំងពីកំណើត
- មានលក្ខខណ្ឌមួយចំនួនទៀត កំណត់ក្នុងច្បាប់បោះឆ្នោត ។

### ប.២. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០១៨

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៨ ដែលប្រវត្តិ និងលទ្ធផលដូចខាងក្រោម៖

### ប.៣. អំពីសភាធម្មនុញ្ញ

សភាធម្មនុញ្ញកើតពីការបោះឆ្នោតសកល នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ តាមប្រព័ន្ធសមាមាត្រ មាន ២១ខេត្ត-ក្រុង ជាមណ្ឌលបោះឆ្នោត ដោយមានគណបក្សនយោបាយចំនួន ១៩ ចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោត ដែលមានតំណាងរាស្ត្រសរុប**ចំនួន ១២០រូប** ។

សភាធម្មនុញ្ញមានតួនាទី និងភារកិច្ចរៀបចំសេចក្តីព្រាងរដ្ឋធម្មនុញ្ញ និងអនុម័តរដ្ឋធម្មនុញ្ញ។

ក្រោយពីសេចក្តីព្រាងរដ្ឋធម្មនុញ្ញត្រូវបានសភាធម្មនុញ្ញអនុម័ត និងប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រឹត្យរបស់សម្តេចព្រះបាទ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងចូលជាធរមានរួចមក គឺសភាធម្មនុញ្ញ បានក្លាយទៅជា រដ្ឋសភានីតិកាលទី១ ភ្លាម ។

សភាធម្មនុញ្ញកើតពីការបោះឆ្នោតនៅថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ ចាត់ចែងដោយអ៊ុនតាក់ តាមប្រព័ន្ធ សមាមាត្រ មាន ២១ ខេត្ត-ក្រុង ជាមណ្ឌលបោះឆ្នោត ដោយមានគណបក្សនយោបាយ ចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ១៩ ។

គណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ចំនួន ៤ ៖

- គណបក្សហ៊្វុនស៊ិនប៉ិច ៥៨ អាសនៈ
- គណបក្សប្រជាជនកម្ពុជា ៥១ អាសនៈ
- គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ១០ អាសនៈ
- គណបក្សមូលីណាកា ០១ អាសនៈ

តំណាងរាស្ត្រសរុប**ចំនួន ១២០រូប ក្នុងនោះមានស្ត្រី ០៥រូប ស្មើនឹង ៤,១៦%** ដែលមានរាយនាមដូចតទៅ៖

| ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ | មណ្ឌល | ផ្សេងៗ |
|---|---|---|---|---|
| ១ | ឯកឧត្តម កែ គឹមយ៉ាន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ២ | ឯកឧត្តម ផិត ផន្ទរ | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៣ | ឯកឧត្តម មាន សារិន | ហ៊្វុនស៊ិនប៉ិច | បន្ទាយមានជ័យ | |
| ៤ | ឯកឧត្តម ជោង ទូរ | ហ៊្វុនស៊ិនប៉ិច | បន្ទាយមានជ័យ | |
| ៥ | ឯកឧត្តម មិន សារឿន | ហ៊្វុនស៊ិនប៉ិច | បន្ទាយមានជ័យ | |
| ៦ | ឯកឧត្តម ឡាយ ខែក | ប្រជាធិបតេយ្យ សេរីនិយម ព្រះពុទ្ធសាសនា | បន្ទាយមានជ័យ | |
| ៧ | ឯកឧត្តម ស ខេង | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៨ | ឯកឧត្តម ឈាង វុន | ប្រជាជនកម្ពុជា | បាត់ដំបង | ជំនួស ឯ.ឧ ណាំ ទុំ |
| ៩ | ឯកឧត្តម ជួន ប៊ុនធល | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១០ | ឯកឧត្តម សេរី កុសល | ហ៊្វុនស៊ិនប៉ិច | បាត់ដំបង | |
| ១១ | លោកជំទាវ គី លំអង | ហ៊្វុនស៊ិនប៉ិច | បាត់ដំបង | |
| ១២ | ឯកឧត្តម ផ្លុង សារ៉េត | ហ៊្វុនស៊ិនប៉ិច | បាត់ដំបង | |
| ១៣ | ឯកឧត្តម លី ណារិទ្ធ | ហ៊្វុនស៊ិនប៉ិច | បាត់ដំបង | |
| ១៤ | ឯកឧត្តម ស៊ីន សូប៉េវ្តី | ប្រជាធិបតេយ្យ សេរីនិយម ព្រះពុទ្ធសាសនា | បាត់ដំបង | |
| ១៥ | ឯកឧត្តម ហ៊ិន សែន | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ១៦ | ឯកឧត្តម ម៉ាត់ លី | ប្រជាជនកម្ពុជា | កំពង់ចាម | |

| | | | |
|---|---|---|---|
| ១១៩ | ឯកឧត្តម អ៊ិត សុគន្ធ | ហ្វ៊ុនស៊ិនប៉ិច | តាកែវ |
| ១២០ | ឯកឧត្តម គីម សុខា | ប្រជាធិបតេយ្យ សេរីនិយម ព្រះពុទ្ធសាសនា | តាកែវ |

## ១. ៥. រដ្ឋសភានីតិកាលទី២



រដ្ឋសភានីតិកាលទី២

រដ្ឋសភា នីតិកាលទី២ កើតពីការបោះឆ្នោតសកល នាថ្ងៃទី២៦ខែកក្កដា ឆ្នាំ១៩៩៨ តាមប្រព័ន្ធសមាមាត្រ មាន ២៣ ខេត្ត ក្រុង ជាមណ្ឌលបោះឆ្នោត ( មានក្រុងពីរបង្កើតថ្មី គឺ ក្រុងកែប និងក្រុងប៉ៃលិន) ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ៣៩ ។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភាចំនួន ៣៖

១- គណបក្សប្រជាជនកម្ពុជា ៦៤ អាសនៈ

២- គណបក្សហ្វ៊ុនស៊ិនប៉ិច ៤៣ អាសនៈ

៣- គណបក្សសមរង្ស៊ី ១៥ អាសនៈ

តំណាងរាស្ត្រសរុបចំនួន **១២២រូប ក្នុងនោះមានស្ត្រី ១៥រូប ស្មើនឹង ១២,២៩%** ដែលមានរាយនាមដូចតទៅ៖

| | | | | |
|---|---|---|---|---|
| ១១៩ | ឯកឧត្តម ហេង បូ | ហ៊្វុនស៊ិនប៉ិច | តាកែវ | ជំនួសឯ.ឧ ហៀន វណ្ណរ័ត្ន |
| ១២០ | ឯកឧត្តម ខែក ភ័ន់ឌី | ហ៊្វុនស៊ិនប៉ិច | តាកែវ | |
| ១២១ | ឯកឧត្តម ឡោ សារី | ហ៊្វុនស៊ិនប៉ិច | តាកែវ | ជំនួសឯ.ឧ ឯក សេរីវឌ្ឍ |
| ១២២ | ឯកឧត្តម ហុង សុខហៀង | សម រង្ស៊ី | តាកែវ | |

## ៣.៦. រដ្ឋសភានីតិកាលទី៣



រដ្ឋសភានីតិកាលទី៣

រដ្ឋសភា នីតិកាលទី៣ កើតពីការបោះឆ្នោតសកល នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៣ តាមប្រព័ន្ធ សមាមាត្រ មាន ២៤ខេត្ត ក្រុង ជាមណ្ឌលបោះឆ្នោត (មាន ខេត្តមួយទើបបង្កើតថ្មី គឺឧត្តរមានជ័យ) ដោយមានគណបក្សនយោបាយចូលរួម ឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ២៣។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភា ចំនួន ៣ :

| | |
|---|---|
| ១- គណបក្សប្រជាជនកម្ពុជា | ៧៣ អាសនៈ |
| ២- គណបក្សហ៊្វុនស៊ិនប៉ិច | ២៦ អាសនៈ |
| ៣- គណបក្សសមរង្ស៊ី | ២៤ អាសនៈ |

តំណាងរាស្ត្រសរុប**ចំនួន ១២៣ រូប ក្នុងនោះស្ត្រីមាន ២៤រូប ស្មើនឹង១៩,៥១%** ដែលមានរាយនាមដូចតទៅៈ

## ខ.៧. រដ្ឋសភានីតិកាលទី៤




*រដ្ឋសភានីតិកាលទី៤*

រដ្ឋសភានីតិកាលទី៤ កើតពីការបោះឆ្នោតសកល នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ តាមប្រព័ន្ធសមាមាត្រ មាន ២៤ រាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោត ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ១១ ។

គណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាចំនួន ៤ :

| | |
|---|---|
| ១- គណបក្សប្រជាជនកម្ពុជា | ៩០ អាសនៈ |
| ២- គណបក្សសមរង្ស៊ី | ២៦ អាសនៈ |
| ៣- គណបក្សសិទ្ធិមនុស្ស | ៣ អាសនៈ |
| ៤- គណបក្សហ៊្វុនស៊ិនប៉ិច | ២ អាសនៈ |
| ៥- គណបក្សនរោត្តមរណឫទ្ធិ | ២ អាសនៈ |

តំណាងរាស្ត្រសរុប**ចំនួន ១២៣រូប ក្នុងនោះស្ត្រីមាន២៦រូប ស្មើនឹង២១,១៣%** ដែលមានរាយនាមដូចតទៅ៖

## ១.៧. រដ្ឋសភានីតិកាលទី៥




រដ្ឋសភានីតិកាលទី៥

- រដ្ឋសភា នីតិកាលទី៥ កើតចេញពីការបោះឆ្នោតសកល កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣ តាមប្រព័ន្ធសមាមាត្រ មាន ២៤ រាជធានី.ខេត្ត ជាមណ្ឌលបោះឆ្នោត ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ៨ ។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភាចំនួន២

- គណបក្សប្រជាជនកម្ពុជា : ៦៨ អាសនៈ
- គណបក្សសង្គ្រោះជាតិ : ៥៥ អាសនៈ

តំណាងរាស្ត្រសរុប**ចំនួន ១២៣ រូប ក្នុងនោះស្ត្រីចំនួន ២៥ រូប ស្មើនឹង ២០,១៣%** ដែលមានរាយនាមដូចតទៅ៖

# ឧបសម្ព័ន្ធទី ៣

## រូបភាព

## ១. សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន (រដ្ឋបុរសកម្ពុជា)



- រំដោះប្រជាជនកម្ពុជាចេញពី របបប្រល័យពូជសាសន៍៖ ០៧ មករា ១៩៧៩។
- ស្ថាបនិកសុខសន្តិភាព៖ ២៩ ធ្នូ ១៩៩៨។
- កាន់តំណែងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា៖ អស់រយៈពេល ៣៨ ឆ្នាំ។
- ប្រធានព្រឹទ្ធសភា៖ ៣ មេសា ២០២៤ - បច្ចុប្បន្ន។

# ២. សមាសភាពគណៈរដ្ឋមន្ត្រី នីតិកាលទី ៧








សមាសភាពរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧ នៃរដ្ឋសភា
ប្រភព៖ -ព្រះរាជក្រឹត្យលេខ: នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣
-ព្រះរាជក្រឹត្យលេខ: នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤
ឯកឧត្តម កែវ រ៉េមី ទេសរដ្ឋមន្ត្រី
ឯកឧត្តម គី តិច ទេសរដ្ឋមន្ត្រី
ឯកឧត្តម នៃ ស៊ីណារិទ្ធ ទេសរដ្ឋមន្ត្រី
ឯកឧត្តម ឈាង យ៉ាណារ៉ា ទេសរដ្ឋមន្ត្រី
ឯកឧត្តម ថោង ខុន ទេសរដ្ឋមន្ត្រី
ឯកឧត្តម សុខ ស៊ីផាន់ណា ទេសរដ្ឋមន្ត្រី
ឯកឧត្តម ស្វាយ ស៊ីថា ទេសរដ្ឋមន្ត្រី
ឯកឧត្តម អ៊ី ឈាន ទេសរដ្ឋមន្ត្រី
ឯកឧត្តម អ៊ុក ប្រាជ្ញា ទេសរដ្ឋមន្ត្រី
ឯកឧត្តម អ៊ុច បូររិទ្ធ ទេសរដ្ឋមន្ត្រី
ឯកឧត្តម ប៉ែន ទិបុល ទេសរដ្ឋមន្ត្រី
ឯកឧត្តម ស្រី ថាមរុទ្ធ ទេសរដ្ឋមន្ត្រី




សមាសភាពរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧ នៃរដ្ឋសភា
ប្រភព៖ ព្រះរាជក្រឹត្យលេខ: នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣
ឯកឧត្តម វង្សី វិស្សុត រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
ឯកឧត្តម ស សុខា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ឯកឧត្តម ទៀ សីហា រដ្ឋមន្ត្រីក្រសួងការពារជាតិ
ឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ឯកឧត្តម កែវ រតនៈ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល
ឯកឧត្តម ប៊ិន ត្រឈៃ រដ្ឋមន្ត្រីក្រសួងផែនការ
ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ឯកឧត្តម ជា សុមេធី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន


សមាសភាពរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧ នៃរដ្ឋសភា
ប្រភព៖ ព្រះរាជក្រឹត្យលេខ: នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣
ឯកឧត្តម ថោ ជេដ្ឋា
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
ឯកឧត្តម នេត្រ ភក្ត្រា
រដ្ឋមន្ត្រីក្រសួងព័ត៌មាន
ឯកឧត្តម កើត រិទ្ធ
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ឯកឧត្តម ហួត ហាក់
រដ្ឋមន្ត្រីក្រសួងអធិការកិច្ច
ឯកឧត្តម ជា វ៉ាន់ដេត
រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
ឯកឧត្តម ឈាង រ៉ា
រដ្ឋមន្ត្រីក្រសួងសុខាភិបាល
ឯកឧត្តម ប៉េង ពោធិនា
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
លោកជំទាវ ភឿង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
ឯកឧត្តម សុខ សុខេន
រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ឯកឧត្តម ចាយ បូរិន
រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
លោកជំទាវ អ៊ឹង កន្ថាផាវី
រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
ឯកឧត្តម ហេង សួរ
រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ឯកឧត្តម ហ៊ុន ម៉ានី
រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
ឯកឧត្តម ម៉ៅ ហាវណ្ណាល់
រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
ឯកឧត្តម ឡាំ ជា
រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន



## ៣. គំនូរបំប្រួញស្តីពី «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»



## ៤. ការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ



